# សង្កេតការណ៍

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

# ២៧



ប្រជាជនកម្ពុជាដែលទទួលរងនូវជំងឺតម្កាត់ដោយសារអត់អាហារ និងបញ្ហាផ្សេងៗ ទៀត បានត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួនវិញក្រោយរបបខ្មែរក្រហមដួលរលំ
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org

ខែមករា-កុម្ភៈ ឆ្នាំ២០១៥

# មាតិកា

ខែមករា-កុម្ភៈ ឆ្នាំ២០១៤


១ សេចក្តីសង្ខេបនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១

៤២ តើសំណងអ្វីខ្លះដែលដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងទទួលបានសម្រាប់សំណុំរឿង០០២/០១?



លឹម ជ័យទ័ត្ត និង ទូន ឡៃហុល

ពិនិត្យ និងផ្ទៀងផ្ទាត់ ដោយ ជី ទេរិទ្ធិ




*សកម្មភាពជញ្ជូនដីនៅក្នុងគម្រោងលើកទំនប់ជីកប្រឡាយ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# សេចក្តីសង្ខេបនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០២/០១

**ទូន ឡៃហ៊ុល**

នៅអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ដំណាក់កាលទី១ ដែលផ្តោតជាសំខាន់លើអង្គហេតុស្តីអំពីការជម្លៀសប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកោះហៅដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣១រូប ចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងអង្គហេតុដូចដែលជនជាប់ចោទត្រូវបានចោទប្រកាន់ និងស្តាប់ការទទួលរងព្យសនកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ឡើងថ្លែងសេចក្តីទុក្ខសោក និងទាមទារសំណងចំពោះការទទួលរងព្យសនកម្មទាំងផ្នែកផ្លូវកាយ និងផ្លូវចិត្ត ដែលឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំង៣១រូប រួមមាន ក្លាន វ៉ិត, រម៉ាម យុន, យឹម សុវណ្ណ, អែម អឿន, ជុំ សុខា, ឡាយ បូនី, មុំ សំអឿន, មាស សារ៉ាន់, អោ រី, ចៅ នី, ទឹង សុខា, ពេជ ស្រីផល, គឹម វ៉ាន់ឌី, ដេនីស អាហ្វុងសូ, ពិន យ៉ាថៃ, ស សារិន, នូរ ហ៊ាន់, សូផាន់ សូវណ្ណី, យិន វំដួល, ប៊ូ ឌីណា, ស៊ូ សុទ្ធារី, អូន ផល្លី, សាំង វ៉ាត់, យស ផល, ធុច ផាន់ដារា ស, ចាន់ សុជាតិ, ហូ ចន្ទា, ឆេង អេងលី, បេ សុផានី, សឿន សុវណ្ណឌី, សេង ស៊ីវត្ថា ។

ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃសក្ខីកម្ម និងសេចក្តីថ្លែងទុកសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ ៖

## ១) ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត

ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃទី១០ និងថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត រស់នៅភូមិអ៊ិន ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី ជាជនជាតិកាចក់ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសដើម្បីផ្តល់សក្ខីកម្មទាក់ទងនឹងការទទួលរងព្យសនកម្មនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងថ្លែងនូវសេចក្តីទុក្ខសោកនៅចំពោះមុខអង្គជំនុំជម្រះ និងភាគីក្នុងសវនាការ ជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសក្នុងការទាមទារសំណងនៅចំពោះមុខអង្គជំនុំជម្រះ ។ ក្លាន វ៉ិត មានអាយុ៦៥ឆ្នាំ ធ្លាប់មានតួនាទីជាអនុលេខាស្រុក២១ បន្ទាប់ពីធ្វើជានីរសារហូតដល់ឆ្នាំ១៩៧៦ ។

នៅក្នុងអំឡុងពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត បានរាប់រៀបថា មុនពេលចូលរួមធ្វើបដិវត្តន៍ដំបូង លោកត្រូវបានអ្នកស្គាល់គ្នាប្រាប់ថា បើមិនចូលបដិវត្តន៍ទេនោះនឹងត្រូវស្លាប់ ពីព្រោះខ្មាំងសក្តិភូមិនឹងធ្វើបាប ។ នៅពេលឮដូចនេះ លោកបានសម្រេចចូលរួមនៅក្នុងចលនាបដិវត្តន៍ ។ ចាប់តាំងពីពេលនោះមកដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានឈ្មោះ វ៉ាង និង ឈ្មោះ ស៊ី ចាត់តាំងឲ្យខ្លួនធ្វើជានីរសា ដើម្បីរត់សំបុត្រឲ្យកម្មាភិបាល និងបន្ទាប់មកធ្វើប្រធានភូមិដើម្បីធ្វើការអប់រំប្រជាជន និងផ្គត់ផ្គង់ផ្នែកសេដ្ឋកិច្ចដល់បដិវត្តន៍ ។ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត បានបញ្ជាក់ថា លោកធ្លាប់បានជួបជនជាប់ចោទ អៀង សារី ហើយនៅពេលនោះ អៀង សារី បានបង្រៀនដល់មេភូមិ មេឃុំ កុំឲ្យហៅវៀតណាមថា យួន ព្រោះវៀតណាម ឡាវ និងកម្ពុជា គឺជាបងប្អូនជីដូនមួយ ។ បន្ថែមលើនេះលោក អៀង សារី ថែមទាំងបានប្រកាសប្រាប់ថ្នាក់ស្រុក ថ្នាក់ឃុំ ឲ្យយល់ពីអ្វីជាខ្មាំង និងអ្វីជាសត្រូវទៀតផង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា នៅពេលនោះ អៀង សារី នួន ជា ខៀវ សំផន និង ប៉ុល ពត គឺមានតួនាទីជាគណៈភូមិភាគឦសាន្ត ។ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត បានធ្វើការបញ្ជាក់ជាចុងក្រោយថា មូលហេតុដែលអង្គការជ្រើសរើសយកជនជាតិភាគតិចឲ្យចូលធ្វើបដិវត្តន៍ ដោយសារជនជាតិភាគតិច គឺជាមនុស្សល្ងង់ មិនដឹងអ្វីជាខ្មាំង អ្វីជាបដិវត្តន៍នោះឡើយ ។ នៅចុងបញ្ចប់នៃសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន វ៉ិត ពុំបានថ្លែងអំពីសេចក្តីទុក្ខសោក ឬស្នើសុំ

សំណងនៅចំពោះមុខអង្គជំនុំជម្រះឡើយ ។

### ២) ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១១ និងថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន ដើម្បីផ្តល់សក្ខីកម្មស្តីពីអង្គហេតុ និងការទទួលរងព្យសនកម្មដោយសារឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន ហៅ ខាំភី មានអាយុ៧០ឆ្នាំ រស់នៅភូមិកាចូត ស្រុកអណ្តូងមាស ខេត្តរតនគីរី ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះធ្លាប់មានតួនាទីជាអនុលេខាស្រុក២១ ក្នុងភូមិភាគឦសាន ដែលចាត់តាំងដោយខ្មែរក្រហម រួមជាមួយនឹងមិត្តភក្តិ៩នាក់ផ្សេងទៀត ។ ក៏ប៉ុន្តែ ក្រោយមក៦នាក់ក្នុងចំណោមអ្នកទាំង៩នាក់នោះត្រូវ បានចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខស-២១ ។

នៅក្នុងសវនាការដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន បានរៀបរាប់ថា ការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម គឺដើម្បីស្វែងរកយុត្តិធម៌ជូនមិត្តភក្តិទាំង៦នាក់ដែលបានបាត់ខ្លួន ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពុំបានស្នើសុំសំណង ឬថ្លែងអំពីទុក្ខសោកនៅចំពោះមុខអង្គជំនុំជម្រះទេ ។

### ៣) ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ

ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ កើតនៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៦០ និងមានទីកន្លែងកំណើត នៅភូមិព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ។ បច្ចុប្បន្នកំពុងរស់នៅទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ តូច ស៊ុំ និងម្តាយឈ្មោះ ទូច លី និងមានស្វាមីឈ្មោះ គឹម លាង មានកូនបីនាក់ ។ នៅក្នុងសវនាការថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងផ្តល់ឱកាសឲ្យឡើងថ្លែងអំពីសេចក្តីទុក្ខសោក និងការបាត់បង់របស់ខ្លួននៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខាងក្រោមនេះ ជាសេចក្តីដកស្រង់ទាំងស្រុងនៃពាក្យថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ៖

“នៅក្នុងចន្លោះឆ្នាំ១៩៧៥ និង៧៦ នាងខ្ញុំត្រូវគេវាយធ្វើបាប គេចោទខ្ញុំថាជាប្រជាជន១៧ មេសា ទោះបីជាខ្ញុំឈឺក៏គេឲ្យខ្ញុំធ្វើការទាំងមានជំងឺ ដែលនាងខ្ញុំនៅក្មេង ។ នៅតាមសហករណ៍ដែលនាងខ្ញុំបានចេញពីឆ្នាំ១៩៧៥ ជម្លៀសនាងខ្ញុំចេញពីភ្នំពេញទៅនៅក្នុងភូមិឃុំពោធិ៍បាន ភូមិលេខ៥ ឃុំពោធិបាន ស្រុកកោះធំ ។ ពេលនោះ នាងខ្ញុំទៅរស់នៅអ្នក១៧មេសា អ្នកមូលដ្ឋាន ១៨ មេសា ចោទថានាងខ្ញុំសុទ្ធតែខ្មាំង ប្រើនាងខ្ញុំដោយអត់អាហារ ហូបៗតែគល់ជ្រៃស្ងោរ គ្មានកម្លាំងធ្វើការ ។ នាងខ្ញុំសុខចិត្តលះបង់សេចក្តីឈឺចាប់ និងការស្លាប់ ដើរសន្សំពោត សូម្បីតែពោតក៏គេថា នាងខ្ញុំជាចោរលួចពោត ។ គ្មានបាយហូបពេលធ្វើការ ពេលណាក៏ហូបតែម្សៅជ្រៃ ។ ទឹកភ្នែកខ្ញុំហូរ សុខចិត្តឈឺចាប់ ខ្លោចផ្សាវេទនា ។ រហូតនាំនាងខ្ញុំទៅដាក់នៅកងនារី នាងខ្ញុំឈឺគេវាល់ឲ្យខ្ញុំហូបបាយមួយវែក ។ ឪពុករបស់នាងខ្ញុំដឹងថាខ្ញុំឈឺ សុខចិត្តទៅតាមឲ្យនាងខ្ញុំមកផ្ទះ ខ្ញុំមកអត់បាន១៥នាទី ប្រធានកងនារីតាមឲ្យខ្ញុំទៅវិញ គេចោទថាខ្ញុំកងសេរី គ្មានច្បាប់គ្មានទម្លាប់ ។ សួរថាវិបត្តិផ្លូវចិត្តរបស់ខ្ញុំ? ជិតជាមរហូតដល់សព្វថ្ងៃ ខ្ញុំឈឺចាប់ពេលណាខ្ញុំនឹកឃើញរឿងដែលខ្ញុំចេញទៅភ្នំពេញ គឺខ្ញុំរន្ធត់តក់ស្លុតអស់នូវអ្វីក្នុងខ្លួនរបស់ខ្ញុំ ។ ធ្វើការទាំងយប់ទាំងថ្ងៃ ។ នាងខ្ញុំមនុស្សប្រជាជនដែលល្អសុខចិត្តធ្វើឲ្យខ្លួនអាក្រក់ លួចសន្សំដើម្បីក្រពះរស់នៅក្រុមគ្រួសារ ។

ពេលមុនជម្លៀសខ្ញុំមុនឆ្នាំ១៩៧៦ គេចោទនាងខ្ញុំលួចស្រូវ ថា នាងខ្ញុំអាក្រក់ ឲ្យខ្ញុំទៅច្រូតស្រូវ កន្លែងផ្សេង គេថាខ្ញុំហ្នឹងខិលប្រអូស បានតែងាប់ ។ ខ្ញុំសុខចិត្តស្រក់ទឹកភ្នែកខំធ្វើការដើម្បីដូរនឹងបាយបបរមួយវែក ។ ហើយគេថាឲ្យនាងខ្ញុំថា មិនបាច់ជម្លៀសទៅលើកទី២ទេ នាងខ្ញុំប្តេជ្ញាចិត្តថា បើអត់ឲ្យនាងខ្ញុំទៅជួបម៉ែឪខ្ញុំជម្លៀសលើកទី២ ខ្ញុំសុខចិត្តរត់ សុខចិត្តស្លាប់ ដើម្បីទៅតាមម៉ែឪខ្ញុំ ។

បាត់បង់ទ្រព្យសម្បត្តិអស់គោក្របី ដីស្រែចម្ការ ។ នៅក្នុងឆ្នាំ១៩៧៨ ឪពុករបស់នាងខ្ញុំឈ្មោះ តូច ស៊ុំ ប្អូនជីដូនមួយរបស់ឪពុកខ្ញុំ និងក្មួយប្រុសរបស់ឪពុកខ្ញុំ ព្រមទាំងប្អូនស្រីរបស់នាងខ្ញុំ ខ្មែរក្រហម បានយកទៅវាយចោលនៅមន្ទីរ០៧ ទាំងយប់ដោយចោទថា សុទ្ធតែខ្មាំង ឪពុករបស់នាងខ្ញុំ និងប្អូន ។ ខ្ញុំមិនអាចយំបានដោយឃើញទិដ្ឋភាពនៅផ្ទាល់នឹងភ្នែក គេចងស្លាបសេក ហើយគេ

ស្រែកអាក្រោសនៅតាមថ្នល់ ហើយគេបើកម៉ាស៊ីនថាជាខ្លាំង ។ តើខ្ញុំអ្នក១៧មេសា សុខចិត្តឱនសម្រក់ទឹកភ្នែកនឹងដី អត់ហ៊ាន ងើតងើបមុខនៅចំពោះអង្គម៉ាស៊ីននៅក្នុងសហករណ៍ទាំងមូល ។ ភ័យរន្ធត់ជីវិតខ្ញុំថ្ងៃរស់បានពេលយប់ឡើងជីវិតរបស់ក្រុមគ្រួសារ នាងខ្ញុំភ័យរន្ធត់ យប់ឡើងគេនឹងយកវ៉ៃចោលទៀត ។

ពាក្យស្លោករបស់អង្គការ“ដកស្មៅ ដកទាំងឫស មិនឲ្យទុក” ខ្ញុំរងទុក្ខវេទនារកអ្វីមកប្រៀបផ្ទឹមពុំបាន រន្ធត់ ឈឺចាប់ ដោយខ្លួននៅស្មើរ ហើយឆ្លងកាត់នូវឧបសគ្គគ្រប់ពេលគ្រប់វេលា ។ ភ្នែករបស់នាងខ្ញុំ ពេលដែលឃើញឪពុករបស់នាងខ្ញុំត្រូវកងឈ្លប ប៉ុលពត ចងនៅនឹងមុខ ព្រោះដោយសារតែបាក់បែក ព្រាត់ប្រាស់គ្រួសារ បងប្អូន ឪពុកម្តាយ បន្ទុកនៅលំបាកគ្មានទីពឹង រកស៊ីចិញ្ចឹមប្អូន ប្រុសស្រី និងម្តាយ ដោយខ្លួនឯង ។ ការលំបាកទាំងនេះធ្វើឲ្យនាងខ្ញុំចូលមន្ទីរពេទ្យរុស្ស៊ីផ្នែកវិបត្តិផ្លូវចិត្ត មានអារម្មណ៍ខ្វោយមាន វិបត្តិបញ្ហាបេះដូង និងយល់សុបិនអាក្រក់នៅនឹងភ្នែក ។ ខ្ញុំបាក់បែក បាត់បង់ទ្រព្យសម្បត្តិ ជាច្រើន ព្រោះតែអំឡុងពេលខ្មែរក្រហម ។ ខ្ញុំឈឺចាប់ណាស់ ព្រោះខ្ញុំកើតមកជាតិនេះជួបតែរឿងអភ័ព្វ ជួបតែរឿងវិនាសអន្តរាយក្នុងសង្គម គ្មានការចេះដឹងគ្មានរៀន ជួបតែរឿងវិបត្តិអសីលធម៌ រឿងអាក្រក់នៅចំពោះជីវិតរបស់នាងខ្ញុំ ជួបតែរឿងគ្មានធនធានមនុស្ស ។ តើជីវិតនាងខ្ញុំចង់ចេះដឹង ចង់យល់អំពីសង្គម រៀន ខ្ញុំចង់ថា ខ្ញុំរៀនអ្វីឲ្យល្អ នៅរស់នៅក្នុងសង្គមឲ្យមានជីវិតថ្លៃថ្នូរ ប៉ុន្តែនាងខ្ញុំ ដោយអវិជ្ជា មិនបានរៀនសូត្រ បំណងប៉ងត្រូវរលាយបាត់ ដោយសារស្រមោលអន្តរកាល ទុកនូវវិបត្តិឈឺចាប់ តម្កល់មួយជីវិតរបស់នាងខ្ញុំរហូត ។

ដោយសារវិបត្តិផ្លូវចិត្តខាងលើ នាងខ្ញុំសម្រេចស្វែងទៅរកព្រះធម៌ សម្រេចចិត្តទៅបួសដើម្បីរម្ងាប់នូវវិបត្តិផ្លូវចិត្តដល់ពេលបច្ចុប្បន្ននេះ ។ បានរម្ងាប់ផ្លូវចិត្តមួយទៀត ដោយសារតុលាការកូនកាត់ជាតិ និងអន្តរជាតិជំនុំជម្រះទោសនូវពួកគ្មានសីលធម៌ ។ នាងខ្ញុំមានជំនឿទុកចិត្ត ភាពកក់ក្តៅលើការកាត់ក្តីចំពោះមេដឹកនាំទាំងអស់នាពេលខាងមុខឲ្យស្វែងរកយុត្តិធម៌ជូនជនរួមជាតិទាំងអស់ ដែលមានគ្រោះអាក្រក់នៅក្នុងសង្គម និងខ្ញុំតាងនាមខ្ញុំជាជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ខ្ញុំគ្មានយោបល់អ្វី និងវែងឆ្ងាយទេ ព្រោះនាងខ្ញុំបានសម្រេចចិត្តថា មានតែផ្លូវសុខហើយនិងស្ងប់ ហើយនាងខ្ញុំ មិនអាចមានសង្ឃឹមថា ពេលមុន



ពិធីអង្គមីទ្ទេញមិត្តភាពរវាងប្រទេសកម្ពុជា-វៀតណាម-ឡាវ ក្នុងអំឡុងទសវត្សរ៍៤០ ឬ៥០
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មកនាងខ្ញុំថា មិនសង្ឃឹមថាខ្ញុំប្រឈមមុខនៅចំពោះតុលាការជាតិ និងអន្តរជាតិទេ ។ ប៉ុន្តែនាងខ្ញុំពេលនេះ បានមានមុខមានវត្តមានប្រឈមមុខនូវចំពោះមុខតុលាការជាតិ និងអន្តរជាតិ ។ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះគុណចំពោះតុលាការជាតិ និងអន្តរជាតិ ដែលរកយុត្តិធម៌ឲ្យនាងខ្ញុំ ។ តាងនាមឲ្យប្រជាជនទូទាំងប្រទេស ជាដើមបណ្តឹងរដ្ឋប្បវេណី ព្រោះនាងខ្ញុំមានតែជំងឺផ្លូវចិត្តបៀមទុកជាយូរអង្វែងមកហើយ មិនដឹងថ្លែងវាចារប្រាប់អ្នកណាថា អ៊ីល្អ អ៊ីអាក្រក់ ។ ខ្ញុំដឹងថាប្រជាជនទាំងអស់ ជាជនរងគ្រោះ ប៉ុន្តែតិចនិងច្រើនតែងតែមានហើយ ។ ទិដ្ឋភាពនៅពេល៧៥ រហូតដល់៧៩ គឺឲ្យនាងខ្ញុំយល់ច្បាស់នូវអ៊ីល្អ អ៊ីអាក្រក់រហូតដល់សព្វថ្ងៃនេះ ។ ហើយនាងខ្ញុំសង្ឃឹមថា តុលាការជាតិ និងអន្តរជាតិ ជួយរកយុត្តិធម៌ តើអ៊ីល្អ អ៊ីអាក្រក់ ។ តើវិបត្តិផ្លូវចិត្តរបស់ប្រជាជន និងតំណាងនាងខ្ញុំ តំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បាត់បង់នូវផ្លូវចិត្ត ។ នាងខ្ញុំគ្មានអ្វីថ្លែងច្រើនទេ នាងខ្ញុំថ្លែងតែប៉ុណ្ណឹង ។

## ៤) ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន

នៅថ្ងៃទី២៣ ២៧ និង២៩ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ។ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន មានអាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងផ្លុង ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។ សព្វថ្ងៃរស់នៅភូមិឈូកស ឃុំដូនតីស្រុកពញាក្រែក ខេត្តកំពង់ចាម ប្រកបមុខរបរ ធ្វើស្រែចម្ការ ។ ឪពុកឈ្មោះ អ៊ូច សាអែម និងម្តាយឈ្មោះ អៀប ស្រេម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ធ្លាប់មានប្រពន្ធម្នាក់ឈ្មោះ អ៊ុង ណេង ប៉ុន្តែបានបាត់បង់ជីវិតក្នុងរបបនោះ ។ ពេលបច្ចុប្បន្នមានប្រពន្ធម្នាក់ទៀតឈ្មោះ ស៊ុម អ៊ី និងមានកូនបីនាក់ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានបម្រើការងារជាគ្រូពេទ្យមូលដ្ឋាននៅតំបន់២០ (គ្រូពេទ្យ១៧មេសា) ។

នៅក្នុងអំឡុងពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានអះអាងថា «ខ្ញុំដាក់ពាក្យ[បណ្តឹង]នេះមិនមែនលេងសើចទេ ការពិត គឺការឈឺចាប់ បាត់ម្តាយ បាត់ឪពុក បាត់បងប្អូនអស់ ដោយសារពួកថ្នាក់ដឹកនាំនេះឯង ។ ដូច្នេះខ្ញុំងើបឡើងដើម្បីតាំងជាដើមបណ្តឹងដើម្បីស្វែងទាញរឿងពិត ប្រាប់តុលាការថា រឿងរបស់អ្នកទាំងបីហ្នឹងយ៉ាងម៉េចខ្លះ គឺខ្ញុំសូមនិយាយតែរឿងពិតទេ ត្រង់គេធ្វើយ៉ាងម៉េចជារឿងរបស់គេ ឯខ្ញុំឃើញយ៉ាងណានោះជារឿងរបស់ខ្ញុំ» ។

មុនពេលបញ្ចប់កិច្ចដំណើរការសវនាការស្តាប់សក្ខីកម្ម អង្គជំនុំជម្រះបានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ឡើងថ្លែងអំពីសេចក្តីទុក្ខសោកដែលទទួលរងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងលើកឡើងអំពីសំណងដែលមានបំណងស្នើសុំ ។

មុនពេលចាប់ផ្តើម ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានថ្លែងអំណរគុណចំពោះសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលខិតខំប្រឹងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ ។ ខាងក្រោមនេះ ជាសេចក្តីថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ៖

ខ្ញុំសូមអភ័យទោសទុកជាមុន ទោះបីជាការនិយាយយ៉ាងលំបាកលំបិនយ៉ាងណាក៏ដោយ ខ្ញុំសូមបញ្ជាក់ទុកជាមុនថា ខ្ញុំមានជំងឺមួយ គឺនៅបំពង់ក ។ ដូច្នេះ ហេតុផលទាំងអស់នេះ ទើបវាធ្វើឲ្យខ្ញុំនិយាយហាក់ដូចជា ខ្ញុំមានការភ័យព្រួយ ។ ប៉ុន្តែបំណងនេះ គឺមកសម្តែងការពិត ។ អស់លោក លោកស្រី បងប្អូនជនរួមជាតិជាទីគោរព! ក្នុងឱកាសនេះ គឺខ្ញុំបាទ សូមតែនិយាយពីរឿងពិតៗ ដែលកើតឡើងពីព្រឹត្តិការណ៍ដែលកើតឡើងចំពោះរូបខ្ញុំផ្ទាល់ ។ អ៊ីចឹង អ្វីក៏ដោយ ខ្ញុំសូមនិយាយអំពីបញ្ហាដែលខ្ញុំបាទបានជួបទោះបីជាការជួបនេះដូចគ្នានឹងបងប្អូនក៏ដោយ មិនដូចក៏ដោយ ខ្ញុំចាត់ទុកថា គេហៅថា រឿងរ៉ាវទាំងអស់ដែលកើតឡើងក្នុងអំឡុងពេលនោះ គឺខ្ញុំយល់បានច្បាស់ថា ពិតជាកើតដូចៗហ្នឹងខ្ញុំដែរ ។ តាំងពីតូចក្រុបឆ្ការមកដល់ខ្ញុំប៉ុណ្ណេះ មិនស្គាល់ទេសាលារៀន ខ្ញុំស្គាល់តែការលំបាក គឺកិច្ចការរបស់ខ្ញុំធ្វើជួសលោកឪពុកផង ជួសម្តាយផង ជួសបង ជួសប្អូនផង រហូតដល់ខ្លួនឯងមិនបានរៀន ។ ដូចក្នុងផ្ទាំងឯកសារដែលខ្ញុំបានសរសេរទុកនេះ គឺមិនបានរៀននេះឯង ន័យនេះខ្ញុំមិនសរសេរឲ្យពិរោះស្តាប់ទេ ។ ធាតុពិតគឺខ្ញុំនិយាយអំពីសាច់រឿងរបស់ខ្ញុំផ្ទាល់តែម្តង ការផ្ទាល់នេះវាពាក់ព័ន្ធ ។

នៅក្នុងសេចក្តីថ្លែងនេះ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ពុំបានលើកឡើងអំពីសំណើសុំសំណង និងការទទួលរងព្យសនកម្ម ដោយសាររបបខ្មែរក្រហមទេ

## ៥) ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា

នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ។

ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ និងមានទីកន្លែងកំណើត នៅភូមិត្បូងក្តី ឃុំដំរីពួន ស្រុកព្រៃវែង ខេត្តព្រៃវែង ។ បច្ចុប្បន្នកំពុងរស់នៅភូមិព្រែកដាច់ ឃុំលើកដែក ស្រុកលើកដែក ខេត្តកណ្តាល ។ ដើមបណ្តឹងរដ្ឋប្បវេណីមាន ឪពុកឈ្មោះ ជុំ សារុន និងម្តាយឈ្មោះ យុគ ផន និងមានភរិយាឈ្មោះ គួច កញ្ញា មានកូនបីនាក់ ។

ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា បានរៀបរាប់ថា នៅមុនឆ្នាំ១៩៧៥ លោកបានមករស់នៅម្តុំពោធិ៍ចិនតុង និងឃើញមានការប្រយុទ្ធជារៀងរាល់ថ្ងៃរវាងទាហាន លន់ នល់ និងទាហានខ្មែរក្រហម ដើម្បីដណ្តើមយកទីតាំងកាន់កាប់ ដោយមានការបាញ់ផ្លោង និងមានប្រជាជនរបួស និងស្លាប់ជារៀងរាល់ថ្ងៃ ។ បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់លោកត្រូវបានជម្លៀសទៅដល់ស្រុកកំណើត គឺនៅភូមិត្បូងក្តី ។ នៅទីនោះ ជុំ សុខា ត្រូវបានអង្គការបង្ខំឲ្យជីកទំនប់លើកភ្លឺស្រែ ដកស្ទូង ភ្ជួររាស់ ដោយមិនមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគ ។ នៅពេលឈឺថ្នាំដែលខ្មែរក្រហមយកមកដើម្បីព្យាបាល គឺជាថ្នាំមួយប្រភេទដែលមានរូបរាងដូចជាអាចម៍របស់សត្វទន្សាយ ដោយត្រូវប្រើប្រាស់ដើម្បីព្យាបាលគ្រប់ប្រភេទជំងឺ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ រៀបរាប់ថា អង្គការបានបង្ខំឲ្យលោកធ្វើការមួយថ្ងៃរហូតទៅដល់១២ ឬ១៤ម៉ោង ។

ខាងក្រោមនេះ គឺជាសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ជូនចំពោះអង្គជំនុំជម្រះ ៖

«អ៊ីចឹងខ្ញុំសំណូមពរថា ជាចុងក្រោយ សំណូមពរជាចុងក្រោយ សូមតុលាការធ្វើការផ្តន្ទាទោសពួកមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មយង់ឃ្នងមកលើក្រុមគ្រួសារខ្ញុំ និងប្រជាជនខ្មែរស្លូតត្រង់ទូទាំងប្រទេសកម្ពុជាទៅតាមច្បាប់ឲ្យបានធ្ងន់ធ្ងរ ឲ្យសមនឹងកំហុសរបស់ពួកគេ ។ ហើយចំពោះសំណង ខ្ញុំចង់ស្នើសុំតុលាការទាមទារពីជនជាប់ចោទ និងសូមឲ្យតុលាការស្រាវជ្រាវទ្រព្យសម្បត្តិរបស់ជនជាប់ចោទយកមកសងសមូហភាព ។ ហើយរឿងទាមទារសំណងនេះ ខ្ញុំសូមទុកឲ្យមេធាវីខ្ញុំជាអ្នកចាត់ចែងជំនួស ។ ហើយសំណូមចុងក្រោយ សូមឲ្យប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាអន្តរជាតិចូលរួមគាំទ្រទាំងស្មារតី សម្ភារដល់សាលាក្តីខ្មែរក្រហម ដើម្បីជួយជំរុញដំណើរការក្តីនេះឲ្យបានចប់សព្វគ្រប់ជាស្ថាពរ» ។

## ៦) ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី

នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី ។

ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥០ នៅសង្កាត់លេខ៤ ក្រុងភ្នំពេញ ។ បច្ចុប្បន្នលោកស្រីរស់នៅភូមិត្រពាំងឈូក ផ្លូវ៣៧១ សង្កាត់ទឹកថ្លា ក្រុងភ្នំពេញ និងជាមេផ្ទះ ។ ឪពុកឈ្មោះ ឡាយ គ្រុយ (ស្លាប់) និងម្តាយឈ្មោះ យុត ស៊ី (ស្លាប់) ។ សព្វថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណី មានស្វាមីឈ្មោះ ចាន់ សារ៉ែន និងមានកូន៣នាក់ ។

ខាងក្រោមនេះ គឺជាសេចក្តីថ្លែងទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី នៅអំឡុងពេលនៃការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ៖

«ចាស៎! នាងខ្ញុំសូមអរគុណ ។ ក្នុងនាមនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី នាងខ្ញុំមានការសប្បាយរីករាយ ហើយនេះជាឱកាសមួយដ៏ល្អបំផុត ដែលរយៈពេលជាង៣០ឆ្នាំហើយ ដែលនាងខ្ញុំបានដក់ទុកនូវការឈឺចាប់ពេញនៅក្នុងខួរក្បាលនៅក្នុងបេះដូង និងនៅក្នុងខ្លួនខ្ញុំ ។ ហើយដោយសារមានតុលាការហ្នឹង ទើបនាងខ្ញុំបានឡើងមកសម្តែងនូវការឈឺចាប់ទាំងអស់នេះចាស៎ ។ ចាប់តាំងពីថ្ងៃ១៧ មេសា ឆ្នាំ៧៥ គឺថាខ្ញុំចាប់ផ្តើមមានទុក្ខរហូត គឺថា ទុក្ខនោះទុក្ខធំដែលខ្ញុំមិនដែលជួបប្រទះសោះ គឺថាត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ចោលផ្ទះសម្បែង ព្រាត់ប្រាស់គ្រួសារ ម៉ែឪ

បងប្អូនទាំងកូន ទាំងសរសៃខ្វី ទើបតែឆ្លងទន្លេហើយ២០ថ្ងៃ ដែលនាងខ្ញុំមិនដែលជួបប្រទះ ដែលឪពុកម្តាយចិញ្ចឹមមកបានល្អ ស្រាប់តែត្រូវរបបខ្មែរក្រហមនេះមកបំផ្លាញសេចក្តីសុខនេះ ។ វេទនាណាស់ចេញ ទៅតាមផ្លូវទាំងឈឺ ទាំងជា ជាមួយកូន ជាមួយប្តី ទីបំផុតទៅស្លាប់កូន ស្លាប់ម្តងមួយៗ រហូតពេលដែលខ្ញុំជម្លៀសចេញពីភ្នំពេញ គឺជាទុក្ខសោកនេះ ខ្ញុំបានកប់ទុកយូរហើយ នៅពេលនេះខ្ញុំបានមកសម្តែង ។ នាងខ្ញុំមានសេចក្តីជ្រះថ្លា និងអរព្រះគុណដល់តុលាការនេះណាស់ ។

ហើយជាពិសេស ពេលដែលនាងខ្ញុំជម្លៀស គឺជាជម្លៀសនោះ ជម្លៀសហួសហេតុ ពីភ្នំពេញមកខ្សាច់កណ្តាល ពីខ្សាច់កណ្តាលមកកំពង់ឆ្នាំង ពីកំពង់ឆ្នាំងទៅពោធិ៍សាត់ ។ ទីបំផុតទៅរស់នៅសហករណ៍កោះជុំ ធៀបអន់ជាងសត្វធាតុទៅទៀត រហូតដល់សុំគេដូរបាយជ្រូកមកហូប ។ ទីបំផុតអង្គការសម្រេចចិត្តមិនដឹងជាកាត់ទោសខ្ញុំយ៉ាងម៉េច សម្រេចចិត្តយកខ្ញុំទាំងគ្រួសារយកទៅដាក់គុក ហើយគុកនោះ គឺជាមហាវិនាសកម្ម ។ ដោយសារមិនមែនត្រឹមតែខ្ញុំទេ សូម្បីតែប្រជាពលរដ្ឋទាំងអស់ ដែលមិនមានទោសពៃរ៍អ្វីសោះនោះ ក៏ត្រូវយកទៅសួរចម្លើយ វ៉ៃដកក្រចកជ្រមុជទឹក ចងកញ្ជ្រូវ ដែលគ្នាអត់មានទោសអីសោះ ហើយថែមទាំងប្រាប់ថាឲ្យសារភាពឲ្យត្រឹមមកអ្នកឯងធ្វើខុសអ្វីខ្លះ? ហើយចុះបើគ្នាអត់ខុសអីផង ឲ្យសារភាពថាម៉េច បើសារភាពបន្ធូរបន្ថយ បើមិនសារភាពរិតតែធ្ងន់ ។ ពេលទៅសួរចម្លើយនៅគុកថ្កោលត្រឡប់មកវិញ គឺថាវា ។ មានស្ត្រីម្នាក់នោះប្រាប់ខ្ញុំថា អូនហើយអូន បើបងស្លាប់ទៅល្អជាងនៅរស់ឲ្យគេវ៉ៃសួរចម្លើយ វ៉ៃដកក្រចកបែកឈាមហូររហាម ។ អ៊ីចឹងបានថា គឺថាមហាវិនាសកម្មនេះ ដល់តែធ្វើស្រែពេលទៅធ្វើការក៏វ៉ៃពេលហូបក៏វ៉ៃ ពេលដេកក៏វ៉ៃ ។ ហើយមូលហេតុអីបានវ៉ៃ? គេមិនឲ្យយើងហូបបន្លែ ព្រោះគេថាហូបទៅឈឺបាត់បង់ពលកម្ម ប៉ុន្តែយើងហូបអត់ឆ្អែត ព្យាយាមបេះបន្លែមកលាយដើម្បីសម្រន់នៅក្រពះ ។

ហើយដូចការសម្លាប់អ៊ីចឹង ទើសអីក៏សម្លាប់ដែរ ។ ងាកទៅមើលក្នុងគុកហ្នឹងពេលដែលខ្ញុំមិនទាន់ចេញទៅសមរភូមិមុខ គឺថាងាកទៅឃើញបែកក្បាល ឃើញបែកភ្នែក ឃើញរយៈនេះហើយច្រវាក់មួយណាក៏ជាប់ច្រវាក់ដែរ ពេលដែលចេញមកធ្វើការលើកច្រវាក់ចងនៅលើចង្កេះ! ហើយជាន់ដូចថា ខែប្រូតអ៊ីចឹង ប៉ែនស្រូវអ៊ីចឹង ទៅជាន់ស្រូបណ្តើរ ឲ្យតែហ៊ានថា ខ្វះពី-បីគ្រាប់យកមកញាត់មាត់ ភូស! បែកឈាមរហាម ។ អ៊ីចឹងបានថា ខ្ញុំនេះគឺថាវាធ្ងន់ធ្ងរបំផុត គឺថាបើត្រឹមតែអ្នកសហករណ៍ វានៅគ្រាន់បើទេ ជាប់គុក ក្រោយមកក៏សាងខ្លួនបាន ។ សម្លាប់ឆ្អែតឆ្អន់ប្រហែល ១០ម៉ឺននាក់ហើយ ធ្វើស្រែបានផលល្អ ដីមានជីវជាតិ ហើយប្រគល់ឲ្យអ្នកសហករណ៍ ប្រគល់ដីឲ្យអ្នកសហករណ៍ ទើបបណ្តើរពួកនាងខ្ញុំនឹងរាប់រយនាក់ទៅធ្វើស្រែនៅបឹងគល់ទៀត ។ បឹងគល់



មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទី ស្រ៊ីណា
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថិតនៅឃុំបឹងខ្នា ស្រុក២៣ដដែល ។ ធ្វើស្រែស្ទូងស្រូវបាន ១០០ហិចតា ។ ហើយពេលស្ទូងនោះ គឺថា ដកសំណាបយប់ យប់ឡើងដកសំណាបដល់ម៉ោង១២ ។ ដល់ម៉ោង១២អី ដល់ម៉ោង១១ ។ ម៉ោង១១ ឲ្យចូលកន្លែង ចូលកន្លែងទម្រាំបានសម្រាកម៉ោងដប់ដប់ពីរ ។ ម៉ោងបីត្រូវដុកកញ្ចែប្រេច ឲ្យងើប គឺត្រូវតែងើបមកអង្គុយសំកុក តម្រង់ជួរឲ្យមូសខាំ ។ រដូវនោះជារដូវវស្សា មានឯណាមានបាវទូលសំណាបហ្នឹង ហើយរុំគ្របខ្លួន ។ អ៊ីចឹងមុសខាំរហូតដល់ពេលឃើញអញ្ចាញ ដៃមើលទៅឃើញស្រាងៗ ទើបបណ្តើរឲ្យចេញទៅស្ទូងៗ ។ ដល់តែពេលភ្លឺស្រាងៗ

ឡើងទើបគេបណ្ដើរចេញទៅធ្វើការ ហើយហូបចុកខុះខាតមួយកំប៉ុងហូបបួនប្រាំនាក់ ។ ដល់អីចឹងទៅតើសួរថាកម្លាំងធ្វើការតើមានឯណា? អត់មានកម្លាំងធ្វើការទេ ប៉ុន្ដែទៅទាំងចិត្តទៅទាំងខ្លាចស្លាប់ ។ ហើយពេលទៅធ្វើការហ្នឹង ត្រូវទូលសំណាបទៅខ្លួនឯង ហើយបើហ៊ានថាធ្វើជ្រុះធ្វើអី គឺខ្សែតីវៃដូចគោអីចឹង នាងខ្ញុំក៏ធ្លាប់ត្រូវដែរ វៃខ្សែតី ព្រោះពេលគេវៃហ្នឹង គេមិនមែនគិតថាវៃអ្នកនេះមួយ អ្នកនោះមួយ គឺគេវាត់យកៗតែម្ដង ប៉ះអ្នកណាត្រូវអ្នកហ្នឹង ។



សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី អេលីហ្សាប៊ែត ស៊ីម៉ូណូ ហុត (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទៅស្ទូងអីចឹងដែរ ពេលចុះស្ទូង យើងស្ទូងទៅមានផែនការរបស់គេ ស្ទូងទៅត្រូវមួយហិចតា ហ្នឹងស្ទូងប៉ុន្មាននាក់? ត្រូវប៉ុន្មានម៉ោងឲ្យហើយ? ចាស៎! គឺមានកម្រិតផែនការទាំងអស់ ធ្វើការធ្ងន់មានកម្រិតមានផែនការតែហូបតិច ។ សួរថាយើងទាំងអស់គ្នាទទួលយកបានឬអត់? មិនមែនត្រឹម តែហូបតិចនោះទេ សម្លាប់ស្រួលទៀត ។ ក្រោយមកនាងខ្ញុំស្ទូងបាន១០០ហិចតា ហើយពួកនាងខ្ញុំ ប៉ុន្ដែខ្ញុំសូមលើកកន្លែងនេះបន្ដិចទៀត ។ ពេលដែលបណ្ដើរទៅនោះពីគុកថ្កោល ទៅកន្លែងមន្ទីរកសាងខ្លួនបឹងគល់ហ្នឹង គឺថាបាត់មនុស្សច្រើនទៀត ។ យើងចេះតែដើរទៅតាមថ្នល់រទេះភ្លើងដល់ទៅដល់ណោះ អូ! បាត់អ្នកនេះ បាត់អ្នកនោះ ។ ពេលនោះអាហ្នឹង ទៅដល់ហ្នឹងពួកនិរតីម្ដង ។ អាហ្នឹង បូព៌ាចប់ទៀតហើយទៅខាងហ្នឹងពួកនិរតីទទួលម្ដងសម្លាប់ហ្នឹងពាយ ។ ទៅដល់បឹងខ្នានាងខ្ញុំទៅស្ទូងបាន១០០ហិចតា ។ ១០០ហិចតាហើយ ក៏ប្រគល់ដីហ្នឹងទៅឲ្យពួកសហករណ៍ យើងធ្វើបានផលល្អហើយ អីចឹងគេឲ្យដីហ្នឹងទៅឲ្យអ្នកសហករណ៍គេក៏ បណ្ដើរពួកខ្ញុំយកទៅគុកបឹងគល់ទៀត ។

ពេលនោះទៅដល់គុកបឹងគល់បានដឹងថាចំជាពិបាក ហើយជាកន្លែងចុងក្រោយបង្អស់ដែលពិបាកជាងគុកថ្កោល ដែលពិបាកជាបឹងខ្នាទៅទៀត ។ អ្នកដែលខុស គឺដាក់ខ្នោះជើង ។ ដាក់ខ្នោះជើងហ្នឹង គឺថាអាខ្នោះជើងហ្នឹងដេកតំរៀបគ្នាទៅរុញខ្នោះ ។ ហើយហូបចុកឲ្យតែហូបស្រួលមិនស្រួល ដូចថាមានការធ្វេសប្រហែសអីនាយអាយ គឺវៃតែម្ដង វៃបែកឈាមអស់ហើយ ។ អ្នកដែលជាប់ក្នុងបន្ទប់អ្នកជាប់គុកងងឹត គឺមិនបាច់សម្លាប់ទេ គឺស្លាប់ដោយខ្លួនឯង ព្រោះរដូវប្រាំងក្ដៅណាស់ ខែចែត្រ ដំបូលពីរម៉ែត្រ ហើយគ្មានកម្លាំងទប់ទល់នឹងធាតុក្ដៅ ធាតុត្រជាក់អីទេចាស គឺចាំតែដេកស្លាប់តែម្ដង ។ ហើយបើយើងទៅធ្វើការ យើងមកអត់រួចទេ គឺមិនបាច់មក ដឹងតែស្លាប់នៅហ្នឹងហើយ ។ ដឹងតែស្លាប់នៅគល់ឈើ គឺគ្មានអ្នកណាគ្រាអ្នកណាមកបានទេ! ព្រោះម្នាក់ៗយោងតែខ្លួនអត់រួចផង ។ ហើយនៅពេលនោះនៅទីនោះ នាងខ្ញុំលើកពីខ្លួននាងខ្ញុំចុះ វាឃ្លានពេកដូចជាខ្យង នាងខ្ញុំហូបតែឆៅទេ មិនដែលស្ងោរឆ្អិននឹងគេទេ ព្រោះបើមានភ្លើង គឺគេវៃ ។ ហើយឃ្លានណាស់ គឺថាអាការអត់ឃ្លាននេះហើយ ដែលធ្វើឲ្យមនុស្សភ្លេចអស់ហើយសីលធម៌ ភ្លេចអស់ហើយសុជីវធម៌ ធ្វើអីក៏ដោយឲ្យតែរស់សិន ។

នៅគុកបឹង និងគុកត្រាចក្រោលហ្នឹងក៏ដូចគ្នា ។ ព្រលឹមឡើងបណ្ដើរទៅធ្វើការ កាំភ្លើងប្រុងប្រាងយួរកណ្ដាប់ទៅធ្វើការ ថ្ងៃត្រង់មកហូបបាយនៅការដ្ឋានវិញ ។ ថ្ងៃហូបបាយហើយ ចេញទៅធ្វើការទៀត ធ្វើការហើយត្រឡប់មកការដ្ឋានហូបបាយទៀត ។ យប់ទៅដកសំណាប គឺថាដឹងយ៉ាងម៉េច ខ្ញុំឆ្ងល់របបហ្នឹងក៏អាក្រក់ម្ល៉េះ! ឲ្យគ្នាធ្វើការយប់ជ្រៅហើយ មិនឲ្យគ្នាសម្រាកឲ្យបាន ។ ថាតម្លូវបើភ្លឺបានទៅស្ទូង អាហ្នឹងឲ្យនៅដល់ភ្លឺទៅ ហេតុអីបាន

ដោដុិកព្រៃឲ្យគ្នាមកអង្គុយតម្រង់ជួរ ឲ្យមូសខាំ ហាលរងារ ហាលសន្សើម ហើយសួរថា សុខភាពហ្នឹងវាទៅជាយ៉ាងណា ។

ក្រោយមកទៀត ចុងក្រោយគេក៏បានមកជម្លៀសពួកខ្ញុំនៅក្នុងគុកដដែលហ្នឹង ប៉ុន្តែចុះទៅសហករណ៍ ព្រោះពេលនោះទឹកជំនន់ ទឹកជំនន់ហ្នឹងគេជម្លៀសខ្ញុំឲ្យទៅជួយទប់ទឹកនៅសហករណ៍ ។ គ្រាន់តែដើរទៅដល់សហករណ៍ អ្នកសហករណ៍ស្រែកថា អឺ! ទុកដាក់អ៊ីវ៉ាន់ឲ្យស្រួលបួលវើយ ពួកមន្ទីរកសាងខ្លួនមកពួកហ្នឹងសុទ្ធតែចោរ ។ ពេលនោះពួកខ្ញុំឈឺចាប់ណាស់! ការឈឺចាប់ហ្នឹងមិនដឹងជាថ្លែងប្រាប់អ្នកណាទេ ។ ពេលទៅធ្វើការគេឲ្យយើងនៅក្នុងការដ្ឋាន យើងសម្រាកនៅក្នុងហ្នឹងពេលយប់ តែព្រលឹមឡើងត្រូវរៀបចំឥវ៉ាន់ដាក់លើដំបូល ដូចពិតានការដ្ឋានបាយហ្នឹង ។ ឥវ៉ាន់ទើលើហ្នឹង ដើម្បីថ្ងៃឡើងប្រជាពលរដ្ឋ សហករណ៍ហ្នឹងគេហូបបាយក្នុងការដ្ឋានហ្នឹង ។ អ៊ីចឹងទេ យើងទើឥវ៉ាន់ ទើហើយយើងចេញទៅធ្វើការ ។ ធ្វើការនោះ គឺថាទៅជីកដីដើម្បីលើកទំនប់ទប់ទឹកទន្លេ ទឹកទន្លេសាប ។ ហើយអ្នកសហករណ៍ធ្វើការ មានអ្នកសហករណ៍ មានអ្នកមន្ទីរកសាង ។ អ្នកសហករណ៍ធ្វើការដីគោក គេមកធ្វើថ្ងៃបន្តិចបានគេធ្វើ ។ ធ្វើហើយគេមានពេលសម្រាកហូបបាយ ។ ដល់តែយើងធ្វើនៅក្នុងទឹក គឺចុចដីនៅក្នុងទឹកហើយប្រមុជងើបយកដីហ្នឹង យកដាក់លើទំនប់ដើម្បីទប់ទឹក ។ ដល់តែពេលអ្នកសហករណ៍ម៉ោងបីឡើងគេទូលដំឡូង គេចំហុយដំឡូងឈើ ដំឡូងមី ហ្នឹងយកទៅឲ្យហូប ចំណែកយើង អ្នកមន្ទីរកសាងខ្លួននឹងអត់ទេ ធ្វើរហូតៗដល់ពេលយប់ ដល់ពេលចប់គឺត្រឡប់មកការដ្ឋានបាយគេវិញ បានគេចែកបាយនៅពេលនោះ ។ ពេលនោះហើយដែលគេវៃ មកដល់ព្រលប់ការដ្ឋានតូចមនុស្សត្រូវស្នាក់នៅរាប់រយនាក់ អ្នកទោសអ៊ីចឹងទេអីវ៉ែឥវ៉ាន់ទើនៅលើដំបូលនឹងត្រូវគេយកទៅបាត់របស់អញៗ របស់អញនៅឯណា? ម្ល៉ោះហើយ ចេចចាចគេថា យើងនឹងអត់សណ្ដាប់ធ្នាប់គេវៃ យើងនឹងខ្សែតី វាត់ខ្សែខ្វាច់ ។

អ៊ីចឹង បានខ្ញុំគ្រាន់តែចង់ជម្រាបថា ពេលធ្វើការក៏វៃ ពេលហូបក៏វៃ ពេលដេកក៏វៃ គឺថាវៃ ទាំងអស់ វៃរហូត ។ រហូតដល់មានពេលមួយនោះ គេឲ្យពួកខ្ញុំហ្នឹងទៅទប់ទឹកទន្លេសាប ។ ជីកទប់អ៊ីចឹងទៅ ពួកខ្ញុំបន់អស់ហើយ បន់ម៉ែៗឲ្យធ្លាយទំនប់ហ្នឹងទៅលោកអើយ ព្រោះវេទនាណាស់ ។ ដល់តែពេលខ្យល់មកខ្លាំង គេអត់ឲ្យយើងនៅខាងក្នុងទំនប់ គេឲ្យយើងនៅខាងក្រៅទំនប់ ។ ទៅនៅខាងក្រៅហ្នឹង ព្រោះទឹកទន្លេសាប កាលណាខ្យល់ខ្លាំងគឺរលក ដល់រលកបោកមកឲ្យត្រូវខ្លួនយើង ។ យើងទៅទប់ឲ្យរលកត្រូវខ្លួនយើងវាអត់ធ្លាយទំនប់ហ្នឹងទេ បោកមកចំខ្លួនយើងរលកទៅវិញហើយ ។ អ៊ីចឹងទេពួកខ្ញុំ បន់អស់ហើយចុះនៅត្រាំ លោកគិតមើល ត្រាំតាំងពីព្រឹកដល់ល្ងាច តើវាពិបាកប៉ុនណា វារងារផង វាអត់ឃ្លានផង វាទៀយហត់ផង ។ ម្ល៉ោះហើយ បន់អស់ហើយ ជីបអូចៗ អូយ! ធ្លាយមកលោក! ធ្លាយឲ្យស្រលះទៅ! មានអីពេលមួយនោះធ្លាយមែន ។ ដល់ធ្លាយទំនប់អ្នកដែលនៅមុខទឹកហ្នឹង ក៏ត្រូវស្លាប់ គឺស្លាប់តែម្ដង អត់មានសេសសល់ទេ ។

ហើយលើករឿងមួយទៀត នៅហ្នឹងដែរ ពេលដាំដំឡូង កាលណាទឹកចូលមក គេប្រញាប់ប្រញាល់គាស់ណាស់ ទោះដំឡូងតូចក៏ដោយធំក៏ដោយគេគាស់ហើយ ។ ដល់តែយើងនេះ ជាអ្នកទោសនេះវាឃ្លាន ។ អ៊ីចឹងក៏បានទៅកាយៗ រោងគេចាស់ៗហ្នឹង ខ្វះទៅម៉ោងសម្រាកហ្នឹង ទំនេរទៅរើសដំឡូងហ្នឹង គេចោទយើងថា យើងលួចដំឡូងគេ ។ នាងខ្ញុំធ្លាប់ជាប់ម្ដងដែរ គេយកមកមន្ទីរវិញ ដាក់ខ្នោះជើង ក្រោយមកបានមានអ្នកទៅជួយ បានចុះមកទន្លេដដែលហ្នឹងវិញទៀត ។ ហើយពេលដេក ពេលដេកអត់មានកន្លែងដេកស្រួលបួលទេ នាងខ្ញុំចេះតែសម្រាកឲ្យតែបានទៅ ហើយដល់ពេលទឹកវា ចេះតែឡើងមក ជន្លេនពួនពាំទូកប៉ុនៗនេះ ពួនលើជើង ។ មែនទែនទៅលែងខ្លាចហើយជន្លេន ឈ្លើងក៏អត់ខ្លាច ស្អីក៏អត់ខ្លាចដែរ ក្រៅតែពីជីវិតរស់ ។

អ៊ីចឹងបានថា ជីវិតនេះវាអាក្រក់បំផុតមិនដឹងថាអ្នកដឹកនាំហ្នឹង គេជាមនុស្សសតិសម្បជញ្ញៈ គេហ្នឹងជាមនុស្សដែរឬអត់? ដែលគេយកមនុស្សដូចគ្នាទៅធ្វើបាបរបៀបនេះ ចាស៎! ។ ចុងបញ្ចប់ហ្នឹង យៀកណាមចូលខែ១ បែកគេសប្បាយរីករាយ រាំវង់ឡកកញ្ចេង ប៉ុន្តែជីវិតនាងខ្ញុំបែករហូតដល់ខែ៥ គឺដោយសារពួកប៉ុល ពត ហ្នឹង ពួកអាវខ្មៅហ្នឹង កៀនាងខ្ញុំចុះទៅតទៅទៀត មិនដឹងគេគៀរទៅណា ។ ហើយពួកខ្ញុំអត់ហ៊ានរត់ទេ ចេះតែនឹកឃើញថាខ្ញុំរស់មកដល់ថ្ងៃនេះ គេស្លាប់ហើយ ម៉ែ ញាតិមិត្ត អីអ៊ីចឹង អ្នកមកមន្ទីរខ្ញុំមានបួននាក់ស្លាប់អស់បីនាក់ នៅសល់តែខ្ញុំម្នាក់ ។ អ៊ីចឹង

អត់រត់ទេ ពិបាកស្រណុកអី ខំប្រឹងតទៅទៀតចាស៎ ។ រហូតដល់ខែ៩ ទើបខ្ញុំបានបែក ។ ខ្ញុំឡើងមក ឃុំត្រពាំងជង តំបន់២៣ ខ្ញុំក៏ឡើងមកនៅទីនោះទៅ ។

ហើយចុងក្រោយនេះ គឺបំណងរបស់ខ្ញុំ! ចុងក្រោយហ្នឹងគឺថា ក្រោយពីការរៀបរាប់អំពើទារុណកម្មដ៏មហាវិនាសកម្មដ៏អាក្រក់ដ៏ដូចសត្វធាតុ លើសពីសត្វធាតុទៅទៀតនេះ ខ្ញុំសូមបញ្ចប់ចុះ ។ ហើយខ្ញុំសូមសំណូមពរ ខ្ញុំសំណូមពរ ដូចរបស់ខ្ញុំអ៊ីចឹង គឺថាខ្ញុំបានជម្រាបហើយ នៅក្នុងនេះចាស ថាត្រូវធ្វើអី ត្រូវរកមុខអ្នកណាខ្លះ ព្រោះបើថាខ្មែរដូចគ្នាហេតុអ្វីក៏ចិត្តខ្មៅម្ល៉េះ? ក្រែងលោតែមានបរទេសបន្ថែមលើហ្នឹងទៀត បានជាវាអត់ស្គាល់ខ្មែរដូចគ្នាចាស៎ ។ អ៊ីចឹងបានថា ខ្ញុំចេះតែចង់ដឹង ចង់ឲ្យតុលាការរកមុខធ្វើម៉េចរកឲ្យឃើញទៅ ហើយសំណងគឺថាខ្ញុំសូមឲ្យសាងសង់ស្តូបមួយ ព្រោះដោយសារថា មន្ទីរកសាងខ្លួននៅគុកថ្កោលហ្នឹង វាអត់មានក្នុងការស៊ើបអង្កេតទេ ប៉ុន្តែនេះជាសំណូមពររបស់ខ្ញុំ ទោះបីធ្វើបានក៏ដោយ មិនបានក៏ដោយ ក៏ជាគំនិតរបស់ខ្ញុំផ្ទាល់ ។ ខ្ញុំសូមឲ្យតុលាការជួយផ្តល់ជួយជាគំនិត ឲ្យបានសង់ស្តូបមួយដើម្បីគោរពវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅគុកថ្កោលនេះ ព្រោះកន្លែងថ្កោលនេះ ខ្ញុំដឹងច្បាស់ជាងគេថាស្លាប់ច្រើនណាស់ ។ ចាស៎! ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ ទៅស្លាប់បិទភ្នែកជិត ស្លាប់ដោយអស់ចិត្ត ។ ចាស៎ សូមអស់យោបល់" ។

### ៧) ដើមបណ្តឹងរដ្ឋប្បវេណី មុំ សំអឿន

នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ សំអឿន ។

ដើមបណ្តឹងរដ្ឋប្បវេណី មុំ សំអឿន កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩២៧ នៅទីក្រុងភ្នំពេញ ។ លោកស្រីមានអាយុ៨៤ឆ្នាំ គិតត្រឹមថ្ងៃផ្តល់សក្ខីកម្ម ហើយបច្ចុប្បន្នរស់នៅទីក្រុងភ្នំពេញ ។ ឪពុក ឈ្មោះ សួស មុំ ធ្លាប់ធ្វើជាគ្រូពេទ្យនៅក្នុងព្រះបរមរាជវាំង ម្តាយឈ្មោះ គីម ពុន ។ លោកស្រី មានកូនចំនួន១១នាក់ ប៉ុន្តែនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យលោកស្រីបានបាត់បង់ស្វាមី និងកូន៦នាក់ ។ លោកស្រីធ្លាប់ស្គាល់ អៀង សារី និង ប៉ុល ពត ដោយសារធ្លាប់រៀននៅសាលាព្រះស៊ីសុវត្ថិជាមួយគ្នា ។ ជាងនេះទៅទៀត លោកស្រីធ្លាប់រៀនថ្នាក់ជាមួយ ខៀវ ធីរ៉ាត់ ដែលត្រូវជាបងស្រីបង្កើតរបស់ ខៀវ ធីរិទ្ធ (អៀង ធីរិទ្ធ) ។ ទោះបីជាយ៉ាងណា ស្ទើរពេញមួយរបបខ្មែរក្រហម លោកស្រីពុំបានដឹងថាអ្នកទាំងនេះមានមុខនាទីអ្វីឡើយ គឺទើបតែដឹងនៅពេលរបបខ្មែរក្រហមជិតដួលរលំប៉ុណ្ណោះ ។

បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុកក្មេករបស់លោកស្រីត្រូវយោធាខ្មែរក្រហមចាប់ខ្លួនភ្លាមៗ ហើយនាំយកទៅបាត់រហូត ។ លោកស្រី មុំ សំអឿន បានរៀបរាប់អំពីទុក្ខសោករបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះថា បន្ទាប់ពីបានឆ្លងកាត់របបខ្មែរក្រហម លោកស្រីទទួលរងទុកវេទនាយ៉ាងខ្លាំង ដោយសារបាត់បង់ស្វាមី កូនៗ និងទ្រព្យសម្បត្តិទាំងអស់ ។ បច្ចុប្បន្នលោកស្រីមានសុខភាពធ្លាក់ចុះទ្រុឌទ្រោមយ៉ាងខ្លាំង រស់នៅដោយសារពឹងផ្អែកលើថ្នាំពេទ្យដើម្បីព្យាបាលជំងឺដែលបណ្តាលមកពីការធ្វើការហួសកម្លាំងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ លោកស្រីត្រូវខំប្រឹងប្រែងរកទទួលទានដើម្បីចិញ្ចឹមកូនទាំង៥នាក់ ដែលនៅរស់រានមានជីវិត ។ នៅពេលរំឭកអំពីការព្រាត់ប្រាស់ ការសម្លាប់នៅក្នុងសម័យ ប៉ុល ពត លោកស្រី នៅតែមានអារម្មណ៍ភ័យតក់ស្លុត ពុំអាចទទួលទានដំណេកបានសុខស្រួល និងញ័រខ្លួនជាប្រចាំ ។ ទោះបីជាយ៉ាងណាក្តី លោកស្រី មុំ សំអឿន មិនបានទាមទារសំណងជំងឺចិត្តចំពោះការបាត់បង់នេះឡើយ ប៉ុន្តែបន់ស្រន់សូមកុំឲ្យជួបប្រទះរបបខ្មែរក្រហមសាជាថ្មីម្តងទៀត ។

### ៨) ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់

នៅថ្ងៃទី១៤ និង២២ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដែលជាជនរងគ្រោះដោយសារការជម្លៀសប្រជាជនដោយយោធាខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ ។

ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ កើតនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៨៩ និងមានទីកន្លែងកំណើតនៅឃុំបុសមន ស្រុករំដួល ខេត្តស្វាយរៀង ។ មានឪពុកឈ្មោះ មាស ខាវ និង ម្តាយឈ្មោះ អ៊ុំ ឈាង និងភរិយាឈ្មោះ មាន គឹមលីត ប៉ុន្តែ

បានបាត់ខ្លួននៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បច្ចុប្បន្ន ដើមបណ្តឹងរដ្ឋប្បវេណីរស់នៅទីក្រុងភ្នំពេញ និងបម្រើការជាគ្រូពេទ្យ ។

នៅអំឡុងពេលសវនាការ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានរៀបរាប់ថា នៅរយៈពេលប៉ុន្មានថ្ងៃមុនការចូលមកដល់របស់យោធាខ្មែរក្រហម សភាពការណ៍នៅទីក្រុងភ្នំពេញមានលក្ខណៈពិបាកនឹងរៀបរាប់ ដោយសារតែមនុស្សជាច្រើនស្ថិតនៅក្នុងសភាពភ័យខ្លាច មានប្រជាជនជាច្រើនបានទទួលរងរបួស



ការសម្តែងសិល្បៈក្នុងតំបន់រំដោះរបស់ខ្មែរក្រហមក្នុងខេត្តក្រចេះ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងមនុស្សមួយចំនួនបានស្លាប់បាត់បង់ជីវិតដោយសារតែការបាញ់ផ្លោងរវាងទាហាន លន់ នល់ និងខ្មែរក្រហម ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលកំពុងធ្វើការនៅជាន់ខាងលើនៃអគារនៅបុរីកីឡា លោកបានឃើញផ្សែង និងភ្លើងឆាបឆេះយ៉ាងសន្ធោសន្ធៅនៅម្តុំស្ពានជ្រោយចង្វារ ហើយខ្លួនគិតថា ការប្រយុទ្ធគ្នានេះអាចនឹងចប់នៅក្នុងពេលឆាប់ៗ ។ ចំណែកឯអ្នកជំងឺដែលបញ្ជូនមកកន្លែងរបស់លោក មានចំនួនកាន់តែច្រើនឡើងៗ មានទាំងក្មេងទាំងចាស់ ហើយអ្នកខ្លះបានស្លាប់ ដោយមិនមានបងប្អូនមកយកទៅធ្វើបុណ្យទេ ។ ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បានរៀបរាប់អំពីព្រឹត្តិការណ៍ជាក់ស្តែងដែលលោកមិនអាចបំភ្លេចបាន ដោយសម្រក់ទឹកភ្នែកនៅចំពោះមុខអង្គជំនុំជម្រះ នៅពេលព្យាយាមរំឭកអំពីទិដ្ឋភាពក្មេងស្រីអាយុ៨ឆ្នាំមួយរូបដែលរងរបួសធ្លាយពោះ ដែលលោកបានជួយព្យាបាល ហើយប្អូនរបស់ក្មេងស្រីនោះបានដេកស្លាប់នៅក្បែរខ្លួនរបស់នាង ។ នៅពេលឃើញស្ថានភាពក្មេងស្រីនេះ លោកបានព្យាយាមជួយដេរផ្ចិតពោះ និងព្យួរសេរ៉ូមឲ្យដើម្បីសង្គ្រោះជីវិត ហើយមុខរបស់ក្មេងតូចនោះស្ថិតនៅក្នុងអារម្មណ៍របស់លោកជានិច្ច ដោយសារក្មេងស្រីនោះបានចាប់អាវរបស់លោក ហើយសុំឲ្យលោកជួយនាំយកនាងទៅជាមួយ ខណៈពេលដែលស្ថានភាពក្នុងមន្ទីរពេទ្យមានសភាពកាន់តែច្របូកច្របល់ដោយសារតែខ្មែរក្រហមបង្ខំឲ្យចាកចេញពីទីនោះ ។

ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ បន្តថា លោកមិនដឹងថាតើគួរត្រូវធ្វើបែបណាឡើយ ព្រោះម្យ៉ាងត្រូវគិតដល់ភរិយារបស់ខ្លួនដែលកំពុងមានផ្ទៃពោះ៨ខែនៅឯផ្ទះ និងម្យ៉ាងទៀត គឺអ្នកជំងឺជាច្រើនដែលកំពុងត្រូវការអ្នកព្យាបាល ពេលដែលសភាពការណ៍កំពុងចលាចលកាន់តែខ្លាំង ។ ប៉ុន្តែទីបំផុត លោកសម្រេចចិត្តចាកចេញទៅរកភរិយារបស់ខ្លួន ដោយសារតែលោកគិតថា ខ្មែរ

ក្រហមអាចនឹងជួយព្យាបាលអ្នកជំងឺទាំងអស់ដែលកំពុងរង់ចាំការជួយសង្គ្រោះ នៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះ ។ មាស សារ៉ាន់ បានរៀបរាប់ថា នៅតាមផ្លូវចាកចេញពីមន្ទីរពេទ្យទៅកន្លែងដែលភរិយារបស់លោកស្នាក់នៅ (ម្តុំផ្លូវប៉ាស្ទ័រ) គឺមានការបាញ់ប្រយុទ្ធគ្នាយ៉ាងខ្លាំង ដែលត្រូវបង្ខំចិត្តដើរវាងតាមផ្លូវវត្តមហាមន្ត្រី ប៉ុន្តែនៅតែពុំអាចជួបភរិយារបស់លោក ដោយសារខ្មែរក្រហមបានបង្ខំឲ្យលោកចាកចេញពីទីក្រុងភ្នំពេញរយៈបីថ្ងៃ ព្រោះខ្លាចយន្តហោះរបស់សហរដ្ឋអាមេរិកមកទម្លាក់គ្រាប់បែក ។

ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានឆ្លើយតបទាំងទឹកមុខស្រពោនថា ចាប់តាំងពីថ្ងៃដែលលោកត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មក លោកពុំដែលបានទទួលដំណឹងពីភរិយាដែលមានផ្ទៃពោះ៨ខែទាល់តែសោះរហូតមកដល់ពេលបច្ចុប្បន្ននេះ ។

នៅមុនពេលបញ្ចប់កិច្ចដំណើរការនីតិវិធីសួរដេញដោលអង្គជំនុំជម្រះបានផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ដើម្បីថ្លែងរៀបរាប់ដល់អង្គសវនាការអំពីស្ថានភាពទុក្ខវេទនា ឬការទទួលរងដោយសារឧក្រិដ្ឋកម្ម ដែលកើតឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ខាងក្រោមនេះ គឺជាការថ្លែងរៀបរាប់អំពីទុក្ខសោកដែលបានទទួលរងដោយសាររបបកម្ពុជាប្រជាធិបតេយ្យ និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី មាស សារ៉ាន់ ៖

"ជម្រាបលោកប្រធាន ខ្ញុំថ្លែងអំណរគុណលោកដែល អនុញ្ញាតឲ្យខ្ញុំក្នុងរយៈពេលចុងក្រោយនេះ ។ ខ្ញុំជម្រាបអីចេះថា សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះ ខ្ញុំសង្ឃឹមថាការដែលខ្ញុំនេះ បែកបាក់ប្រពន្ធកូនរបស់ខ្ញុំ ឪពុកម្តាយខ្ញុំ ខ្ញុំសង្ឃឹមថាតុលាការអាចរកការពិតឲ្យខ្ញុំ ។ អាចរកការពិត ខ្ញុំនៅតែសង្ឃឹមថា តុលាការនឹងរកការពិតឲ្យខ្ញុំ ពីព្រោះខ្ញុំរហូតមកដល់ឥឡូវខ្ញុំអត់ៗយល់ហេតុអ្វីខ្មែរក្រហមធ្វើរបៀបហ្នឹង ខ្ញុំអត់យល់ទេ ។ បាទ ខ្ញុំសង្ឃឹមថា តុលាការនឹងរកការពិតឲ្យខ្ញុំ ។ ហើយខ្ញុំសូមអភ័យទោស បើសិនណាការសំណូមពររបស់ខ្ញុំនេះមិនមានការយល់ទាស់ ខ្ញុំសូមឲ្យយកឆ្អឹងទាំងអស់ដែលដាក់តាំងឲ្យគេមើលហ្នឹង យកទៅបូជា ពីព្រោះថាបើសិនណាក្នុងហ្នឹងមានប្រពន្ធខ្ញុំ ខ្ញុំមិនអាចឲ្យគេយកប្រពន្ធខ្ញុំទៅដាក់ក្នុងទ្រុងទុំងសម្រាប់ឲ្យគេមើលទេ ។ សូមៗអភ័យទោសទៅសាលាក្តី បើសិនណាជាការធ្វើបានក៏ធ្វើ បើធ្វើមិនបានខ្ញុំអត់អាចថា ប្រឆាំងតទល់អីអត់ទេ ។ ប៉ុន្តែខ្ញុំសូមថា បើសិនជាអាចធ្វើបាន គឺឆ្អឹងទាំងប៉ុន្មាននៅកន្លែង ដែលដាក់តាំងឲ្យគេមើលសូមយកទៅបូជាតាមប្រពៃណីខ្មែរ ពីព្រោះក្នុងហ្នឹងសុទ្ធតែមនុស្សដែលត្រូវគេសម្លាប់ ។ ហើយសម្លាប់ដោយអ្នកណា? សម្លាប់ដោយអ្នកទាំងអស់នេះ ។ ម្ល៉ោះហើយ ខ្ញុំសូមអភ័យទោសធ្វើជាស្អីមួយបើសិនណាជាលោកធ្វើបាន ។ បើសិនណាជាធ្វើមិនបានទេ អាហ្នឹងខ្ញុំៗអត់ដឹងធ្វើម៉េច ។ ប៉ុន្តែក្នុងចិត្តខ្ញុំ ខ្ញុំសូមថាដាក់បូជាតាមប្រពៃណីខ្មែរ ចេតិយមួយដាក់កន្លែងដែលសមរម្យដែលថាគេ មើលឃើញគ្រប់គ្នា ឲ្យគេមើលឃើញគ្រប់គ្នាថានេះកន្លែងនេះកុំឲ្យយើងពិបាកទៅរក ។ នេះសូមៗទោសដែលខ្ញុំហ៊ាននិយាយដល់ថ្នាក់ហ្នឹង ចំពោះកន្លែងសាលាក្តី ។ រឿងនេះឯង ខ្ញុំៗគិតមើលទៅខ្ញុំបាត់ប្រពន្ធខ្ញុំរហូត មកដល់ពេលនេះខ្ញុំមិនដឹងនៅឯណាផង ។ ខ្ញុំមិនដឹងថាកូនខ្ញុំរស់ ឬស្លាប់ផង ។ ហើយបើសិនណាជា ប្រពន្ធខ្ញុំហ្នឹងស្លាប់ ស្លាប់ហើយទៅនៅក្នុងទ្រុងទុំង ខ្ញុំសូមអភ័យទោស បូជាដាក់នៅកន្លែងមួយដែលសមរម្យ កន្លែងណាមួយមិនមាន មិនខុះកន្លែងទេ ប្រហែលជាមិនខុះកន្លែងទេ ។ ហើយឲ្យគេ គេគង់តែដឹងគ្រប់គ្នា ឧបមាថាចង់បានឲ្យគេ ឲ្យមនុស្សហ្នឹងដឹងថា នេះជារឿង កុំឲ្យកើតមានថ្ងៃក្រោយ ។ មិនអីទេចេតិយប៉ុន្តែខ្ញុំសូមថាកុំឲ្យឃើញឆ្អឹងក្បាលអីចឹង ។ សូមអភ័យទោសៗទាន" ។

## ៩) ដើមបណ្តឹងរដ្ឋប្បវេណី អោ រី

នៅថ្ងៃទី២២ និង២៣ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អោ រី ។

ដើមបណ្តឹងរដ្ឋប្បវេណី អោ រី មានអាយុ៥០ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្បូងដំរី ឃុំកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ មានឪពុកឈ្មោះ អោ និងម្តាយឈ្មោះ ជាត ហើយស្វាមីឈ្មោះ ហ៊ុន ម៉ៅ និងមានកូន៤នាក់ ។

ខាងក្រោមនេះ គឺជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី អោ រី នៅអំឡុងពេលសវនាការ ៖

*“ខ្ញុំសូមនិយាយថា ពីខ្ញុំចេញពីទីក្រុងភ្នំពេញ ខ្ញុំបាត់បង់ផ្ទះសំបែង ទ្រព្យសម្បត្តិ ហើយមកតាមផ្លូវអត់មានអាហារហូបតាមផ្លូវវេទនារហូតទាល់តែទៅដល់ស្រុកកំណើត ។ ទៅដល់ស្រុកកំណើតហើយ នឹកស្មានថាបាននៅជាមួយជីដូនជីតា ។ អកុសលអើ! បានបញ្ជូនខ្ញុំម្តងហើយទៅម្តងទៀត ទាល់តែទៅដល់ខេត្តពោធិ៍សាត់ ។ គេដាក់ទារុណកម្មខ្ញុំ ព្រោះខ្ញុំនៅតូច ខ្ញុំធ្វើការមិនបានជិតដិតនឹងគេ គេវ៉ៃនឹងខ្នងចប ។ គេយកខ្ញុំវែកដី គេយកដងវែកមកសំពងខ្ញុំ កំភួនជើង ឆ្អឹងខ្នង គេថាខ្ញុំនឹងចក្រពត្តិ គេថាខ្ញុំខ្ជិល ។ ខ្ញុំវែកម៉េចនឹងរួច! បើដីពេញៗ ហើយជម្រៅណាណី ខ្ញុំអួសតែបង្គីអួសមិនចង់រួចផង ។ ចំណែកគេឲ្យខ្ញុំទៅស្ទូង ខ្ញុំអត់ចេះស្ទូង គេយកដៃខ្ញុំមកផ្ទាប់នឹងភ្លឺស្រែ វ៉ៃខ្ញុំឡើងចង់ខ្ទេចអស់ ហើយដៃទើបតែមកជាសព្វថ្ងៃនេះទេ ។ ខ្ញុំធ្វើអីក៏មិនកើតដែរ ។ ហើយឲ្យខ្ញុំបាត់បង់ឪពុកម្តាយ បងប្អូន អស់ទាំងពូជ ធ្វើឲ្យខ្ញុំក្លាយជាក្មេងអនាថា អត់មានឪពុកម្តាយ ក្មេងកំព្រា តែលតោលគ្មានគោលដៅ ដើរសុំតែទានគេស៊ី រើសកាកសំណល់គេ ។ សល់ពីរនាក់បងប្អូនដើររើសតាមផ្លូវ លើកដៃសំពះអង្វរសុំគេ សុំឲ្យតែប្អូនហូប ខ្លួនឯងសុខចិត្តអត់ព្រោះប្អូន ។ ហើមជើងប៉ុនៗណាណី ប៉ុនៗដំរី ។ ចំណែកឯខ្ញុំ ណាត្រូវរបួសដើរអួសជើង ខ្ញុំឈឺចាប់ទល់សព្វថ្ងៃនេះ ។ សព្វថ្ងៃណាមួយ បងស្រីទើបតែជួបគ្នា ខ្ញុំស្មានតែបង ខ្ញុំនឹងស្លាប់ គេបញ្ជូនទៅធ្វើការឆ្ងាយនោះបងស្រីដែលត្រូវគ្រាប់នោះឥឡូវគាត់រស់នៅទល់សព្វថ្ងៃ របួសគាត់គ្មានធ្វើអីកើតទេ នៅទល់សព្វថ្ងៃនៅជាមួយនឹងខ្ញុំ គ្មានប្តីគ្មានសីអីទេ ជីវិតខ្ញុំក៏អកុសលម្ល៉េះ ជួបតែទុក្ខលំបាកវេទនា សូមឲ្យលោកប្រធានជួយរកការខុសត្រូវឲ្យខ្ញុំផង ។ ខ្ញុំសូមអគុណ!”*

## ១០) ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី

ថ្ងៃទី២២ និង២៣ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ។ សូមបញ្ជាក់ថា សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី គឺធ្វើឆ្លាស់គ្នាជាមួយនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អោ រី ដោយសក្ខីកម្មរបស់ ចៅ នី ត្រូវបានចាប់ផ្តើមនៅពេលសៀល ។ ហេតុដូច្នេះហើយ ទើបកាលបរិច្ឆេទនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូប នៅចំថ្ងៃ២២ និង២៣ ខែវិច្ឆកា ឆ្នាំ២០១២ ដូចគ្នា ។

ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី មានអាយុ ៥៩ឆ្នាំ មានស្រុកកំណើតនៅភូមិភ្នំពៀ ខេត្តអានយ៉ាង (កម្ពុជាក្រោម) ហើយបច្ចុប្បន្នរស់នៅ ខេត្តតាកែវ ។ នៅមុនឆ្នាំ១៩៧០ ចៅ នី បានមករស់នៅទីក្រុងភ្នំពេញធ្វើជាទាហានក្នុងរបបសាធារណរដ្ឋរបស់សេនាប្រមុខ លន់ នល់ ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលយោធាខ្មែរក្រហមបានចូលកាន់កាប់ទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទាហានខ្មែរក្រហមជម្លៀសចាកចេញពីទីក្រុងភ្នំពេញ ។

មុនពេលបញ្ចប់សវនាការ អង្គជំនុំជម្រះបានផ្តល់វេទិកាជូនដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ដើម្បីថ្លែងអំពីទុក្ខសោកដែលទទួលរងនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ បន្ទាប់ពីទទួលបានការអនុញ្ញាតដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ពុំទាន់ថ្លែងអំពីទុក្ខសោកភ្លាមៗទេ ប៉ុន្តែបានស្នើសុំអង្គជំនុំជម្រះដើម្បីសួរសំណួរទៅកាន់ជនជាប់ចោទ ខៀវ សំផន អំពីការស្លាប់ពូរបស់ខ្លួនឈ្មោះ ចៅ សាវ ។ អង្គជំនុំជម្រះបានអនុញ្ញាតសួរសំណួរទៅជនជាប់ចោទតាមរយៈអង្គជំនុំជម្រះ ដោយដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិសួរសំណួរដោយផ្ទាល់ទៅកាន់ជនជាប់ចោទ ខៀវ សំផន ទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ស្ថានភាពនៃការជម្លៀសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ថា នៅពេលនោះពូរបស់ខ្លួនឈ្មោះ ចៅ សាវ ធ្លាប់មានទំនាក់ទំនងល្អជាមួយ ខៀវ សំផន ហើយនៅពេលជម្លៀស ខៀវ សំផន បានផ្ញើសំបុត្រមួយឲ្យ ចៅ សាវ ត្រឡប់មកទីក្រុងភ្នំពេញវិញ ។ ប៉ុន្តែក្រោយពីវិលត្រឡប់ទៅទីក្រុងភ្នំពេញ ចៅ សាវ ក៏បានបាត់ខ្លួន ។ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណីបានសួរជនជាប់ចោទថា នៅពេលនោះតើជនជាប់ចោទបានជួបពូរបស់ខ្លួនដែរទេ? ហើយពូខ្លួនស្លាប់នៅទីណាដើម្បីឲ្យខ្លួនអាចទៅធ្វើបុណ្យជូន?

ជនជាប់ចោទ ខៀវ សំផន ពុំបានឆ្លើយតបនឹងសំណួរទេ និងបញ្ជាក់ថា គាត់នឹងឆ្លើយតបនៅពេលណាមានភ័ស្តុតាងគ្រប់គ្រាន់ ។ បន្ទាប់ពី ខៀវ សំផន បានបដិសេធពុំឆ្លើយតបនឹងសំណួរដែលលើកឡើង អង្គជំនុំជម្រះបានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី ដើម្បីថ្លែងអំពីទុក្ខសោកដែលទទួលរង ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ នី នៅ ចំពោះមុខអង្គជំនុំជម្រះ ៖

"សូមជម្រាបលោកប្រធាន! ខ្ញុំសោកស្តាយណាស់ដែលសំណួររបស់ខ្ញុំចង់សួររកអីរបស់ខ្ញុំ គាត់មិនមែន....មិនមែនថា ខៀវ សំផន មិនស្គាល់ទេ ។ ខៀវ សំផន ស្គាល់ ចៅ សាវ ច្បាស់ណាស់ គាត់ធ្លាប់ហូបបាយជាមួយគ្នាទៀត គាត់មិនមែនថាបដិសេធមិនដឹងថា សាកសពរបស់គាត់ស្លាប់នៅទីណាទេ ។ គាត់មិនគួរបដិសេធទេ សំខាន់បំផុតគាត់គ្រាន់តែបង្ហាញថា គាត់ស្លាប់នៅកន្លែងណា? ហើយខ្ញុំនឹងយកធាតុរបស់គាត់ យកទៅធ្វើបុណ្យតាមប្រពៃណីខ្មែរវិញតែប៉ុណ្ណឹងទេ ។ អ៊ីចឹង! ទុក្ខសោករបស់ខ្ញុំនៅដដែល ទោះបីបានឡើងតុលាការយ៉ាងណាក៏ខ្ញុំមិនអស់ចិត្តទេ ។ តើឲ្យខ្ញុំថ្លែងទុក្ខនឹងទៅប្រាប់អ្នកណា? បើមកដល់តុលាការហើយ តុលាការគ្រាន់តែឲ្យគាត់ឆ្លើយប្រាប់ថា អ៊ីខ្ញុំស្លាប់ នៅកន្លែងណា? ក្មួយខ្ញុំស្លាប់ ខ្ញុំមិននិយាយទេ ហើយខ្ញុំមិនចង់កំហឹងជាមួយគាត់ទេ ខ្ញុំគ្រាន់តែឲ្យគាត់បង្ហើបរឿង ចៅ សាវ ស្លាប់នៅកន្លែងណា ខ្ញុំនឹងយកធាតុគាត់មកធ្វើបុណ្យតាមប្រពៃណីខ្មែរយើងតែប៉ុណ្ណោះទេ ។ ហើយបើគាត់មិនដែលស្គាល់ ចៅ សាវ ខ្ញុំនឹងយករូបថតឲ្យមើលរូបថត ចៅ សាវ បើលោកភ្លេចមុខ ចៅ សាវ ខ្ញុំយករូបថតឲ្យមើល ហើយលោកអ៊ំ មិនគួរបដិសេធទេ ។ ខ្ញុំមានតែប៉ុណ្ណឹងទេលោកប្រធាន" ។

## ១១) ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា

នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា ។

ដើមបណ្តឹងរដ្ឋប្បវេណីមានឈ្មោះ ទឹង សុខា កើតនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៤៧ នៅភូមិស្វាយតាទាន់ ឃុំតានេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ សព្វថ្ងៃរស់នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាមន្ត្រីចូលនិវត្តន៍ ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ ទឹង គុយ និងម្តាយ លី ប៉ាច ព្រមទាំងមានកូនពីរនាក់ ។

នៅមុនឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា រស់នៅទីក្រុងភ្នំពេញនៅម្តុំវត្តទួលទំពូង ។ មួយថ្ងៃមុនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ មានព្រឹត្តិការណ៍ផ្ទោងគ្រាប់បែក ពេលនោះបងប្អូនដើមបណ្តឹងរដ្ឋប្បវេណីបានរត់ពីទួលគោកមកនៅជុំគ្នា ។ នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សមាជិកក្នុងគ្រួសារបានបំបែកគ្នា ដោយម្តាយក្មេករបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនៅផ្ទះជិតបឹងកេងកង បងប្រុសទៅនៅទឹកល្អក់ ហើយម្នាក់ៗស្ថិតក្នុងសភាពភ័យស្ទន់ស្ទោ ។ ពេលនោះប្អូនស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានផ្ទៃពោះ បានមកនៅផ្ទះរបស់ខ្លួន ប៉ុន្តែក្រោយមកអ្នកទាំងអស់គ្នាបានបែកគ្នា ដោយសារស្ថានភាពនៅពេលនោះមានសភាពច្របូកច្របល់ខ្លាំងពេក ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា នៅចំពោះមុខអង្គជំនុំជម្រះ

"ចាស៎ សូមគោរពលោកប្រធាន សូមអគុណសហព្រះរាជអាជ្ញា ព្រមទាំងលោក លោកស្រី មេធាវីទាំងអស់ដែលបានតាមដានសវនាការនៅក្នុងថ្ងៃនេះ ។ ខ្ញុំមានសេចក្តីត្រេកអរដែលលោកប្រធានតុលាការមេត្តាឲ្យខ្ញុំធ្វើសេចក្តីថ្លែងការណ៍ខ្លះអំពីព្យសនកម្មដែលខ្ញុំទទួលរងនៅចន្លោះឆ្នាំ១៩៧៥ មកដល់ឆ្នាំ១៩៧៩ និងបង្កឡើងដោយរបបខ្មែរក្រហម ។

ខ្ញុំសូមជម្រាបដល់លោកប្រធានថា ពាក្យពេចន៍ទាំងអស់ដែលរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍នេះ សុទ្ធសឹងជាការពិតសុទ្ធសឹងជាពាក្យសច្ចៈ ដោយគ្មានការបំផ្លើសណាមួយឡើយ ។ ផ្ទុយទៅវិញ គឺនាងខ្ញុំទៅវិញទេ ដែលបានព្យាយាមបំភ្លេចចោលនូវរឿងរ៉ាវជាច្រើន ដោយសារថា ពុំនោះសោតទេ វានឹងវែងពេក វាធ្ងន់ធ្ងរពេក សាហាវពេក និងគួរឲ្យខ្មាសអៀនខ្លាំងណាស់ផង ។

វាគឺជាមហាសោកនាដកម្មដែលគួរឲ្យសោកស្តាយ ហើយវាពិតជាពិបាកក្នុងការស្វែងរកពាក្យណាមកដាក់ឲ្យសមល្មមដើម្បីរៀបរាប់ឲ្យសមល្មម ដើម្បីរៀបរាប់អំពីព្រឹត្តិការណ៍ទាំងអស់នោះដែលយើងបានឆ្លងកាត់ ។ វាគឺជារឿងមួយដែលហួសពីការស្រមៃ និងពុំអាចទទួលយកបាន ។ យើងបានខិតខំរស់នៅក្រោយឆ្នាំ១៩៧៩មកទៀត យើងបានជួបជុំសាច់ញាតិរបស់យើងខ្លះ ប៉ុន្តែយើងក៏បានទទួលដំណឹងជាពិសេសអំពីការបាត់បង់បងប្អូនរបស់យើង ដែលត្រូវបានគេសម្លាប់ វាយធ្វើបាប បង្អត់អាហារ និងធ្វើទារុណកម្មនៅទីកន្លែងផ្សេងៗដែលគេជម្លៀសយកទៅទាំងដំណាក់កាលទី១ និងទាំងដំណាក់កាលទី២ ទៅវិញ ។

នៅពេលមានការជម្លៀសពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ មេសា ៧៥ ពេលនោះវាប្រៀបបានទៅនឹងគ្រាប់បែកខ្យល់ផ្ទោង មកបំបែកក្រុមគ្រួសាររបស់អ្នកភ្នំពេញអីចឹង ។ ពួកយើងវង្វេងគ្នា ពួកយើងត្រូវបែកបាក់គ្នាក្នុងរយៈពេលមួយប៉ប្រិចភ្នែក ។ ពួកយើងបែកពីបងប្អូន ពីមិត្តភក្តិ ហើយយើងខ្ញុំបានបាត់បង់នូវទ្រព្យសម្បត្តិទាំងអស់មួយរំពេច ។ យើងបាត់ដំណឹងរបស់ពួកគេរហូតដល់សព្វថ្ងៃនេះ ។

ដំណាក់កាលពី២នៃការជម្លៀស គឺប្រហែលជាខែកញ្ញា ឆ្នាំ ១៩៧៥ ខ្លួនទទេ ឃ្លាតឆ្ងាយ ពីស្រុកភូមិកំណើត ពីញាតិសន្តាន និងពីមិត្តភក្តិជិតស្និទ្ធ ។ គេបានឲ្យពួកយើងទៅនៅក្នុងព្រៃលិចទឹក មិនស្គាល់ទីតាំង ហើយគ្មានអ៊ីហូបទេ គ្មានផ្ទះ គ្មានជម្រក អត់ស្គាល់ភូមិចាស់ណាម្នាក់សោះ ។

កាលពីដំបូង ពួកយើងរស់នៅតាមដងផ្លូវរថភ្លើងនៅគោកត្រាំ ។ ពួកយើងគ្មានសម្ភារដើម្បីកាប់គាស់ព្រៃទេ ។ ពេលនោះចំពេលរដូវភ្លៀង ហើយភ្លៀងធ្លាក់យ៉ាងពេញបន្ទុក ។ យើងគ្មានសិទ្ធិដើរហើរទេ ។ ពួកយើងរស់នៅក្នុងចំណោមអ្នកជម្លៀសដូចៗគ្នា ហើយពួកយើងជាអ្នកអត់ដូចគ្នាទៀត ។ ដូច្នេះពួកយើង ពួកយើងទាំងអស់គ្នាស្លាប់ដោយគ្មានបាយហូប ។ ស្លាប់ដោយជំងឺ គ្មានថ្នាំសង្កូវអ៊ីសោះតែម្តង ។ ដំណាក់កាលនេះ ខ្ញុំកាន់តែមើលឃើញច្បាស់ហើយ គិតថាវាជាវិធីសម្លាប់រង្គាលជាពិសេស គឺសម្លាប់ជនជម្លៀសពីភ្នំពេញដោយយកទៅចាក់ចោលឲ្យលំបាកវេទនា និងទុកឲ្យស្លាប់ក្នុងព្រៃនេះតែម្តង ។

ពួកគេឲ្យយើងស្លាប់ដោយគ្មានចេញឈាម ពួកយើងមានសភាពស្លេកស្លាំង និងស្គមក្រញ៉ង់តែម្តង ។ យើងរស់នៅដូចជាសត្វព្រៃ ស៊ីសត្វម្រើមព្រះ មានពេលខ្លះស៊ីដំឡូងចក់ ឬដើមប្រោះស្វា ស៊ីកល់ត្រកួន ឬសកំប្លោក ។ល ។ ...និយាយឲ្យខ្លី ឲ្យតែជួបអ្វីក៏ហូបឲ្យតែពេញពោះ ស្លឹកថ្មីង ដែលមានរសជាតិជូរបែរជាទៅជាផ្អែម ។ យើងឃ្លានស្ទើរស្លាប់ ភ្នែកប្រែល្អក់មានសភាពដូចសាកសព សំឡេងខ្សោយព្រូវៗ ។ នេះគឺជាមហាគុកឥតជញ្ជាំងមួយ លើសពីសត្វព្រៃនៅក្នុំគាម៉ៅ ដែលគេចិញ្ចឹម គេឲ្យសាច់គេឲ្យអាហារជានិច្ច ។ វាពិតជាសាហាវឃោរឃៅខ្លាំងណាស់ ។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានបាត់បង់កូនស្រី បាត់បង់ឪពុកក្មេក ប្អូនថ្លៃពីរនាក់ ប្តីខ្ញុំធ្វើអត្តឃាត កូនស្រីរបស់ខ្ញុំម្នាក់ទៀត បាត់បង់សំឡេងគឺគរ ។

ដូច្នេះដំណាក់កាលទី២នេះ ការជម្លៀសនេះពិតជាមានការលំបាកខ្លាំងណាស់ ខ្លាំងលើសពីកាលទី១ទៅទៀត ។ ការជម្លៀសទាំងពីរនេះគឺពិតជាមានមហាទុក្ខហួសប្រមាណ ។ ពួកយើងមានសភាពទ្រុឌទ្រោមរាងកាយ កម្លាំងខ្សោយ ទាំងស្មារតី ទាំងកម្លាំង វាជាមហាទុក្ខសោកដែលបានដក់ទុកនៅក្នុងខួរក្បាលរបស់ខ្ញុំ ។ នៅពេលដែលខ្ញុំបាត់បង់កូនស្រី គឺជាពេលខ្លោចផ្សាបំផុតសម្រាប់ខ្ញុំ ស្ទើរតែធ្វើឲ្យខ្ញុំឆ្កួតវង្វេងស្មារតី ។ កូនខ្ញុំបានស្រែកហៅខ្ញុំពីរ



ខៀវ សំផន លើកដៃសំពះសុំអភ័យទោសពីជនរងគ្រោះក្នុងរបបខ្មែរក្រហម (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ាត់ប៉ុណ្ណោះមុននឹងផុត មុននឹងស្លាប់ ។ ពេលដែលខ្ញុំឃើញគេមករើសយកសាកសពកូនស្រីរបស់ខ្ញុំ មិនដឹងជាគេ... ខ្ញុំមិនដឹងជានិយាយអ៊ីកើតឡើយ ខ្ញុំមិនដឹងជារៀបរាប់ប្រាប់ទៅកាន់អ្នកណាឡើយ ពីព្រោះជាការឈឺចាប់របស់...ចំពោះការឈឺចាប់របស់ខ្ញុំនេះ ។ គេដាក់កូនស្រីខ្ញុំក្នុងអង្រឹងតែមួយ ដែលមានខ្មោចប្រាំបីនាក់ ។ ពេលស្វាមីរបស់ខ្ញុំបានធ្វើអត្តឃាត ខ្ញុំសែនរន្ធត់ខ្លាំងណាស់ ព្រោះឃើញសាកសពគាត់ព្យួរនៅឯដំបូលផ្ទះ យូរបន្ទ្រេតក្នុងខ្យល់ ។ ខ្ញុំយំៗដោយគ្មានទឹកភ្នែកហូរ ។ ខ្ញុំចង់យំឲ្យស្រាកស្រាន្តនូវការឈឺចាប់របស់ខ្ញុំខ្លាំងណាស់ ប៉ុន្តែខ្លាចអីនឹងគេដឹង ។ យើងក៏

អាចស្លាប់ទៀត ដោយគេអាចចោទយើងពីរឿងអ្វីមួយ ។ ខ្ញុំរន្ធត់លើសពេលណាៗទៅទៀត ខ្ញុំស្ទើរតែឆ្កួតទៅហើយ ។ ការឈឺចាប់ទាំងអស់នេះបានដក់ជាប់នៅជាមួយខ្ញុំរហូតដល់ថ្នាក់ខ្ញុំខ្លួនឯងផ្ទាល់ ក៏ចង់សម្លាប់ខ្លួនឯងដែរ ខ្ញុំខឹងនឹងខ្លួនឯងដែលអសមត្ថភាពមិនអាចជួយបងប្អូនបាន ។ ខ្ញុំមានការអស់សង្ឃឹមជាខ្លាំង ។ កាលពីមុន ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា "ខ្ញុំត្រូវតែធ្វើយ៉ាងណាដើម្បីមើលថែរក្សាកូនរបស់ខ្ញុំឲ្យបានល្អ" ក៏ប៉ុន្តែនៅទីបំផុតកូនរបស់ខ្ញុំស្លាប់នៅនឹងដៃនៅនឹងភ្នែករបស់ខ្ញុំ ។ ខ្ញុំថែមទាំងបាន សុំប្ដីរបស់ខ្ញុំឲ្យសម្លាប់ខ្ញុំទៀតផង ខ្ញុំមិនចង់រស់នៅក្នុងស្ថានភាព



មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចេក វ៉ាន់លី
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

លំបាកយោរយៅបែបនេះទៀតទេ ។ ប្ដីខ្ញុំបានទិបខ្ញុំ ហើយប្រាប់ខ្ញុំថា "ខ្លួនសុទ្ធតែឆ្អឹង" បានន័យថា បន្តិចទៀតគង់តែស្លាប់ដែរ បែបចង់មានប្រសាសន៍អ៊ីចឹង ។

សូមលោកប្រធានមេត្តាជ្រាប នេះគ្រាន់តែជារឿងសង្ខេបប៉ុណ្ណោះ ។ ដោយសារថា ខ្ញុំមិនអាចរៀបរាប់សាច់រឿងទាំងអស់នេះនៅពេលនេះបានទេ ។ រួមសេចក្ដីមកស្មារតីរបស់ខ្ញុំមានការប៉ះទង្គិចខ្លាំងបំផុត ។ ខ្ញុំពិតជាមិនចង់រស់នៅក្នុងស្ថានភាពឈឺចាប់ម្ដងទៀតទេ ។ ប៉ុន្តែស្លាកស្នាមទាំងអស់នោះមិនអាចរលត់បាត់ពីការចងចាំរបស់ខ្ញុំសោះឡើយ ។ ការចងចាំរបស់មនុស្សមិនមែនដូចជាការលុបសំឡេងពីខ្សែអាត់ដែលយើងអាចលុបបានដោយងាយៗនោះទេ ។ ខ្ញុំនៅតែដេកស្រក់ទឹកភ្នែក ពេលណាដែលខ្ញុំនឹកដល់កូន នឹកដល់ឪពុកម្ដាយដែលបែកគេ ខ្ញុំនៅតែញ័រចំប្រប់ ។ ពេលខ្លះខ្ញុំយំទោះជានៅកន្លែងណាក៏ដោយ ។ ខ្ញុំបានងាកទៅរកធម៌ព្រះពុទ្ធដើម្បីសម្រាលទុក្ខសោករបស់ខ្ញុំ តែបានតែមួយខណៈប៉ុណ្ណោះ ។ បើនិយាយអំពីការបាត់បង់ជាសម្ភារវិញ ខ្ញុំបានបាត់បង់ទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ បូករួមទាំងផ្ទះរបស់ខ្ញុំមួយផង ទាំងអស់មានតម្លៃ៩២៥,១តម្លឹងមាស ។ ខ្ញុំបាត់បង់កូនស្រីរបស់ខ្ញុំ ឪពុកម្ដាយ បងប្អូនសរុបចំនួនប្រាំបីនាក់ ។ បងប្អូនជីដូនមួយសរុបចំនួន២៥នាក់ផុតពូជ ។ ជីទួតមួយសរុបចំនួនប្រាំបីនាក់ ។ មិត្តភក្តិជិតស្និទ្ធសរុបចំនួនប្រាំបីនាក់ ។

ក្រោយពេលចប់របបខ្មែរក្រហម ខ្ញុំស្ទើរតែអស់សមត្ថភាពក្នុងការបំពេញកិច្ចការ ធ្វើការងារតែដដែលៗដោយមិនអាចអភិវឌ្ឍខ្លួនបាន ។

ខ្ញុំនៅតែយល់សប្ដិអាក្រក់ មមើមមាយ ដើមទ្រូងញ័រ ថប់ដង្ហើម អស់សេចក្ដីក្លាហាន ។ ចង់គេង លុះតែមានថ្នាំទើបគេងលក់ ។ ខ្ញុំចង់ឲ្យដំណើរការក្ដីនេះអាចឲ្យមនុស្សជំនាន់ក្រោយចងចាំ និងយល់ឲ្យបានច្បាស់អំពីសម័យនោះ ។

នៅទីបញ្ចប់នេះ នាងខ្ញុំសូមលោកប្រធាននៃអង្គជំនុំជម្រះដ៏ស័ក្តិសិទ្ធិ ជួយផ្ដល់នូវយុត្តិធម៌ឲ្យដល់នាងខ្ញុំ ដល់ក្រុមគ្រួសារនាងខ្ញុំ និងដល់ជនរងគ្រោះទាំងឡាយ ទាំងអ្នកដែលនៅរស់រានមានជីវិត និងទាំងអ្នកដែលបាត់បង់ជីវិតទៅឲ្យគេបានអស់ចិត្ត ឲ្យបានពេញចិត្ត និងឲ្យបានសុខស្ងប់រៀងទៅ ។ សូមអរគុណ ។ សូមជម្រាបលា ។"

### ១២) ដើមបណ្ដឹងរដ្ឋប្បវេណី ពេជ ស្រីផល

នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ពេជ ស្រីផល ។

ដើមបណ្ដឹងរដ្ឋប្បវេណី ពេជ ស្រីផល កើតនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៥២ នៅភូមិស្វាយប៉ោ ឃុំស្វាយប៉ោ ស្រុកត្រពាំងជង ខេត្តពោធិ៍សាត់ ។ សព្វថ្ងៃមានតួនាទីជាជំទប់ទី១ ឃុំត្រពាំងជង ។ លោកស្រីមានឪពុកឈ្មោះ ពេជ និល និងម្ដាយ កែ

គឹមអ៊ី ព្រមទាំងមានកូនពីរនាក់ ។

នៅមុនឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល រស់នៅទួលគោក មានស្វាមីធ្វើជាពេទ្យទាហានក្នុងរបបសាធារណរដ្ឋរបស់សេនាប្រមុខ លន់ នល់ នៅមន្ទីរពេទ្យកាល់ម៉ែត ។ នៅមុនឆ្នាំ១៩៧៥ ស្ថានភាពនៅទីក្រុងភ្នំពេញមានសភាពវឹកវរ ប្រជាជនជាច្រើននាំគ្នារត់មករស់នៅក្នុងទីក្រុង ទំនិញឡើងថ្លៃ និងមានការផ្ទុងគ្រាប់នាំឲ្យមានមនុស្សរបួសនិងស្លាប់ជាច្រើននាក់ ។ ចំណែកស្ថានភាពនៅមន្ទីរពេទ្យកាល់ម៉ែតមានអ្នកជំងឺជាច្រើន ។

នៅពេលទាហានខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា លោកស្រី និងប្រជាជនផ្សេងទៀតបានចេញមកស្រែកអបអរដោយលើកទង់ស ដើម្បីទទួលយោធាខ្មែរក្រហម ។ ពេលនោះទាហានខ្មែរក្រហមបានប្រកាសតាមមេក្រូឲ្យប្រជាជនចេញពីទីក្រុងឲ្យអស់ដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់អាមេរិក ។ ការចាកចេញនេះមានរយៈពេលត្រឹមតែ៣ថ្ងៃតែប៉ុណ្ណោះ ។ នៅពេលធ្វើដំណើរដល់មន្ទីរពេទ្យរុស្ស៊ីមានអ្នកជំងឺជាច្រើននាក់ ក៏ត្រូវបានតម្រូវឲ្យចាកចេញពីមន្ទីរពេទ្យដែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកថា នៅពេលជម្លៀសនោះ កូនទី១របស់លោកស្រីបានស្លាប់ដោយសារលោកស្រីខ្វះសសៃខ្វីពុំមានទឹកដោះបំបៅកូន ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា មានពេលមួយលោកស្រីបានទៅលួចបាយនៅកន្ទ្វែងចុងភៅ ហើយត្រូវបានអង្គការដឹង និងត្រូវចាប់ខ្លួនយកទៅធ្វើទារុណកម្មដោយតម្រូវឲ្យបោកស្រូវមួយយប់មួយពាន់កណ្តាប់ និងរែកដីមួយយប់២០០អម្រែករហូតដល់សន្លប់ ។ ប៉ុន្តែ ខ្មែរក្រហមបានយកទឹកមកជះឲ្យភ្ញាក់ ។ ក្រោយមក ខ្មែរក្រហមបាននាំយកលោកស្រីទៅសម្លាប់នៅទួលថ្ម ប៉ុន្តែនៅពេលនោះ លោកស្រីបានជួបជាមួយ តាមាន ដែលបានប្រាប់ឲ្យលោកស្រីលួចរត់គេចពីការសម្លាប់នោះ ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពេជ ស្រីផល នៅចំពោះមុខអង្គជំនុំជម្រះ ៖

“ចាស៎ នាងខ្ញុំសូមគោរពលោកប្រធានតុលាការជាទីគោរព! សូមគោរពលោក លោកស្រី ចៅក្រមនៃអង្គអង្គជំនុំជម្រះជាទីគោរព! សូមគោរពអង្គសវនាការទាំងមូលជាទីគោរព! នាងខ្ញុំសូមអនុញ្ញាត បង្ហាញអំពីការឈឺចាប់ ព្យសនកម្មដែលនាងខ្ញុំបានទទួលក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ កន្លងមកនេះ ។ នាងខ្ញុំថ្ងៃនេះក៏មានសំណាងដែរ ដែលបានយកទុក្ខសោកទាំងនោះយកមកបង្ហាញនៅចំពោះមុខ អ.វ.ត.ក ចាស៎ ។ នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីឲ្យបានជ្រាបថា ក្នុងរបប៣ឆ្នាំ ៨ខែ នៅពេលដែលនាងខ្ញុំត្រឡប់មកវិញ គឺគ្មានសេសសល់អ្វីទេ ក្រៅពីការឈឺចាប់! ភាពភ័យខ្លាច ភាពបាក់ស្បាត ការបាត់បង់នូវស្មារតីសតិបញ្ញា ដែលជះឥទ្ធិពលមកលើនាងខ្ញុំរហូតមកដល់ឥឡូវនេះនៅតែចងចាំមិនភ្លេចទេនូវឧក្រិដ្ឋកម្មនានាដែលបានបង្កវិនាសកម្មដល់គ្រួសារនាងខ្ញុំ ដល់រូបនាងខ្ញុំ ដល់បងប្អូនរួមជាតិខ្មែរទាំងអស់ដែលជាជនរងគ្រោះ ។

នាងខ្ញុំសូមជម្រាបថា នៅក្នុងសម័យនោះប្អូនប្រុសរបស់នាងខ្ញុំដែលទើបតែអាយុ១៨ឆ្នាំ ដោយសារតែភាពអត់ឃ្លាន បានទៅលួចល្ពៅគេមកហូបមួយ ត្រូវបានទិសគេដាក់មកថាកម្មេចគឺយកទៅសម្លាប់ចោលតែម្តង ។ តើឈឺចាប់កម្រិតណា? ចំណុចមួយទៀត ឪពុក ប្អូនស្រី ប្អូនប្រុស មិនបានសម្លាប់មែន ក៏ប៉ុន្តែស្លាប់ដោយសារធ្វើការងារធ្ងន់ អត់ចំណីអាហារ អត់ថ្នាំ ។ ចំណុចដែលធ្វើឲ្យនាងខ្ញុំចងចាំមិនអាចភ្លេចបាននោះ គឺនារី១៩នាក់ ដែលរស់នៅក្នុងសហករណ៍ ព្រហស្បតិ៍ក្បាល ត្រូវបានគណៈតំបន់ឈ្មោះ ភួន គាត់ចាប់រំលោភមួយយប់មួយៗដាក់វេនគ្នា ព្រោះនារីទាំងអស់នោះ ជាកងពិសេស ហើយរំលោភទាំងអស់គ្រប់១៩ដល់ចូលវេនមកដល់នារីទី២០ គឺជាមិត្តសម្លាញ់របស់ខ្ញុំ អត់ធ្វើអីនាងកើតចាស ម៉ោង១២យប់នាងត្រឡប់មកវិញ នាងរ៉ាយរ៉ាប់សាច់រឿងទាំងអស់នោះប្រាប់ខ្ញុំ ។ តើក្នុងនាមជាស្ត្រីជនរងគ្រោះដែលត្រូវគណៈតំបន់រំលោភតើឈឺចាប់ប៉ុនណា? បើគិត មកដល់ឥឡូវនេះ បើគិតមកដល់ច្បាប់យើងឥឡូវនេះវិញ តើគេកាត់ទោសយ៉ាងម៉េច? រំលោភតែមួយក៏គ្រប់ដែរ មិនចាំបាច់ដល់២០ទេ ។ អាហ្នឹងគឺជាការឈឺចាប់ គឺឆ្លុះបញ្ចាំងឲ្យខ្ញុំឃើញឥទ្ធិពលទាំងអស់នោះ ដែលធ្វើឲ្យខ្ញុំឈឺចាប់មិនអាចបំភ្លេចបាន ។

ហើយក្នុងនេះដែរ ក៏នាងខ្ញុំសូមជម្រាបអស់លោក លោកស្រីថា ការឈឺចាប់ទាំងអស់នោះ វាមិនអាចសុខទៅបាន ធ្វើយ៉ាង

*ម៉េចក៏មិនអាចភ្លេចបានដែរ ក៏ប៉ុន្តែមានសំណូមពរ មានសំណូមពរ ថា សុំឲ្យ អ.វ.ត.ក ហ្នឹងមេត្តាផ្តល់ជាសំណង ។ សំណងសមូហភាព ខាងខ្ញុំទទួលហើយក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី តែសូមឲ្យ ចេញជារូបរាង តើជាស្តូប ឬជាមន្ទីរសុខភាពផ្លូវចិត្ត ដើម្បីឲ្យ ពួកយើងខ្ញុំទាំងអស់គ្នា ដែលជាជនរងគ្រោះ ទាំងប្រជាជនខ្មែរ ទាំងដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង បានទៅធ្វើពិធីគោរពបូជា ទៅ តាមបុណ្យប្រពៃណីជាតិ ដូចជា ភ្ជុំបិណ្ឌ ឬក៏ចូលឆ្នាំ ។ ហើយ ដើម្បីឲ្យយើងទាំងអស់គ្នានេះបានស្ងប់អារម្មណ៍ ធូរស្រាលនៅ ក្នុងចិត្ត ។*

*ហើយចំណុចសំខាន់មួយទៀតនោះ នាងខ្ញុំដឹងថា អ្នកណា ដែលប្រព្រឹត្តត្រូវតែទទួលទោស ។ ដូច្នេះ សូមឲ្យលោកប្រធាន លោកជួយរកយុត្តិធម៌ឲ្យជនរងគ្រោះទាំងអស់ មិនចាំបាច់នាងខ្ញុំទេ បើរកឲ្យជនរងគ្រោះទាំងអស់ នាងខ្ញុំក៏ស្ថិតនៅក្នុងចំណោមនៃជន រងគ្រោះទាំងអស់នោះដែរ ។ សូមឲ្យលោក ទាំងអស់ដែលបាន ប្រព្រឹត្តនៅក្នុងរបបគេហៅថា របបមនុស្សឃាតនោះ, របប៣ឆ្នាំ ៨ខែ, របបកម្ពុជាប្រជាធិបតេយ្យ ដែលពួកគាត់មានដែនការបង្ក វិនាសកម្មឲ្យប្រជាពលរដ្ឋស្លាប់យ៉ាងរង្គាល ។ ហើយក៏សូមឲ្យ លោកប្រធានតុលាការ លោកផ្តន្ទាទោសឲ្យបានតឹងរ៉ឹងជាទីបំផុត ហើយដឹងថាអ្នកធ្វើខុស គឺត្រូវតែមានទោស ។ ចាស! នាងខ្ញុំសូម អរគុណ» ។*

## ១៣) ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី

*នៅថ្ងៃទី៥ និងទី៦ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលា ដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។*

*ដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី កើតនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៦២ នៅស្រុកអង្គរជ័យ ខេត្តកំពត ។ សព្វថ្ងៃរស់នៅឃុំ ត្រែងទ្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងមានមុខរបរបម្រើ ការឲ្យក្រុមហ៊ុន ។ ឪពុកឈ្មោះ កែម អ៊ែល ម្តាយឈ្មោះ អ៊ឹ យឿន និងប្រពន្ធឈ្មោះ ឈួន ស្រីមុំ និង មានកូន៦នាក់ ។*

*នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលខ្មែរក្រហមចូល មកដល់ទីក្រុងភ្នំពេញ ឪពុកមាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវ បានទាហានខ្មែរក្រហមបាញ់សម្លាប់ក្នុងសំលៀកបំពាក់ជាទាហាន បារាំ ។ ក្រោយមក យោធាខ្មែរក្រហមពីរនាក់ស្លៀកសម្លៀក បំពាក់ខ្មៅបានជិះម៉ូតូប្រកាសឲ្យប្រជាជនចាកចេញ ពីទីក្រុង ភ្នំពេញរយៈពេលបីថ្ងៃ ។ នៅពេលនោះលោក និងក្រុមគ្រួសារ របស់ឪពុកមារបានធ្វើដំណើរចេញមកតាមផ្លូវជាតិលេខ៦ ក្នុង ស្ថានភាពមនុស្សច្រើនកកកុញពិបាកធ្វើដំណើរ ។ មានអ្នកជំងឺ ជាច្រើនយួរសេរ៉ូមជាប់នឹងដៃ ។ មានយោធាខ្មែរក្រហមឈរនៅ តាមដងផ្លូវក្នុងឯកសណ្ឋានពណ៌ខ្មៅ និងកាន់កាំភ្លើងគ្រប់ដៃ ។ នៅពេលជម្លៀសដើមបណ្តឹងរដ្ឋប្បវេណី គឹម វ៉ាន់ឌី បានឃើញ យោធាខ្មែរក្រហមបាញ់សម្លាប់បុរសម្នាក់ ដោយសារតែបុរស នោះបានសុំអនុញ្ញាតដើរបកក្រោយទៅរកកូន ប៉ុន្តែត្រូវបានខ្មែរ ក្រហមបាញ់សម្លាប់តែម្តង ។*

*ដើមបណ្តឹងរដ្ឋប្បវេណី វ៉ាន់ឌី រៀបរាប់ថា នៅពេលជម្លៀស ទៅដល់ខេត្តកំពត ដែលជាស្រុកកំណើត លោកបានមើលឃើញ អំពីការបែងចែករវាងប្រជាជនថ្មី ឬប្រជាជន១៧មេសា និង ប្រជាជនមូលដ្ឋាន ។ ចំណែកឯ ឪពុកម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ជូនឲ្យទៅកាប់ដី ធ្វើស្រែនៅស្រុកបាំឡេឡៃ ដោយម្នាក់ៗត្រូវកាប់ដីទំហំ១០ម៉ែត្របួនជ្រុង ។ មានថ្ងៃមួយ ខ្មែរក្រហមបានឆែកឃើញរូបថតឪពុកខ្លួនគឺនុយឯកសណ្ឋានជើង ទឹកឈរថតនៅលើកប៉ាល់ ។ នៅថ្ងៃបន្ទាប់ ឪពុករបស់ដើមបណ្តឹង រដ្ឋប្បវេណីត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើការនៅភូមិឡាំដាំនៅ ខេត្តកោះកុង ។ បន្ទាប់មក ឈ្លបខ្មែរក្រហមបានមកសួរចម្លើយ អំពីប្រវត្តិគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី វ៉ាន់ឌី បានប្រាប់ឈ្លបខ្មែរក្រហមថា ឪពុក របស់ខ្លួនមានមុខរបរជាអ្នកធាក់ស៊ីក្លូ ប៉ុន្តែឈ្លបទាំងនោះបាន និយាយថា លោកនិយាយកុហក និងបានចាប់ខ្លួនយកទៅដាក់ ច្រវ៉ាក់ជើងព្រមទាំងវាយធ្វើទារុណកម្មអស់រយៈពេលមួយ សប្តាហ៍ ។ ថ្ងៃមួយមានឈ្លបពីរនាក់កាន់កាំភ្លើងគ្រប់ដៃ បានមក ចាប់ឪពុករបស់លោកយកទៅសម្លាប់ ហើយម្តាយរបស់លោក ត្រូវបានបញ្ជូនទៅធ្វើការនៅទំនប់ ព្រែកផ្តៅទាំងសរសៃខ្ចី ។ បីខែ ក្រោយមក ប្អូនរបស់លោកដែលទើបនឹងកើតនោះក៏បានស្លាប់ បាត់ទៀត ។*

*ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និង*

សំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី គីម វ៉ាន់ឌី នៅចំពោះមុខអង្គជំនុំជម្រះ ៖

“សូមថ្លែងអំណរគុណចំពោះលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យខ្ញុំ និងថ្លែងទុក្ខវេទនាដែលខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំបានទទួល ។ ក្នុងរបបខ្មែរក្រហម តទៅនេះ ខ្ញុំសូមរៀបរាប់ជូនលោកប្រធានលោក លោកស្រីចៅក្រមអំពីទុក្ខវេទនាដែលរូបខ្ញុំ និងក្រុមគ្រួសារខ្ញុំបានទទួលរងទុក្ខរងទោសនៅក្នុងរបបខ្មែរក្រហមសូមលើកអំពីទុក្ខវេទនាផ្លូវកាយ ។ រូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំត្រូវចាកឆ្ងាយពីផ្ទះសម្បែង ដីធ្លី ទ្រព្យរបស់ និងចំណេះដឹងរបស់ខ្ញុំក៏ដូចជាប្រជាជនដទៃទៀតដែរ ។ ដោយសារតែខ្មែរក្រហមនេះហើយ បានធ្វើឲ្យ បានធ្វើទារុណកម្មលើរូបខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំចាកឆ្ងាយពីផ្ទះសម្បែង ។ បង្ខំឲ្យរូបខ្ញុំក្រុមគ្រួសារខ្ញុំធ្វើការធ្ងន់ធ្ងរហួសកម្លាំងបង្អត់អាហារ មិនឲ្យហូបឆ្អែតក៏ដូចជា ប្រជាពលរដ្ឋដទៃទៀតដែរ ។ ធ្វើឲ្យបងប្អូនស្រីរបស់ខ្ញុំ និងសាច់ញាតិរបស់ខ្ញុំជាច្រើននាក់ស្លាប់ដោយសារតែបង្អត់អាហារយ៉ាងវេទនា ។ ពួកគេបានសម្លាប់ឪពុក បងប្រុស ឪពុកមា ម្តាយមីង ព្រមទាំងសាច់ញាតិជាច្រើនទៀត ដោយអយុត្តិធម៌គួរឲ្យអាសូរជាទីបំផុត ។ សព្វថ្ងៃនេះ ធ្វើឲ្យម្តាយរបស់ខ្ញុំក្លាយជាស្ត្រីមេម៉ាយ រីឯរូបខ្ញុំក្លាយជាកូនកំព្រារហូតមកដល់សព្វថ្ងៃនេះ ។ ពេលខ្ញុំគិត ពេលខ្ញុំអង្គុយគិតម្តងៗ រឿងហ្នឹងវាហាក់បីដូចជានៅថ្មីៗ ធ្វើឲ្យអារម្មណ៍របស់ខ្ញុំពុះកញ្ជ្រោល ខ្ញុំចូលបម្រើជួរកងទ័ពដើម្បីសងសឹកតែលទ្ធផលវាមិនបានវាមិនអាចធ្វើទៅបាន ។ ធ្វើឲ្យខ្ញុំត្រូវនិរទេសខ្លួន ដើម្បីលក់កម្លាំងពលកម្មបានប្រាក់បន្តិចបន្តួចទុកសម្រាប់ចិញ្ចឹមជីវិតរហូតដល់សព្វថ្ងៃ ទម្រាំថ្ងៃអស្តង្គតរបស់ខ្ញុំ ។ សូមលោកប្រធាន លោកលោកស្រី ចៅក្រមមេត្តាជួយរកភាពយុត្តិធម៌ ដាក់ទោសទណ្ឌឲ្យសមនឹងអ្វីដែលរូបខ្ញុំបានបាត់បង់សាច់ញាតិ ក៏ដូចជាអ្នកដទៃដែលមានរឿងដូចខ្ញុំឲ្យបានស័ក្តិសម ដែលលោកប្រធាន លោកលោកស្រី ចៅក្រមធ្វើទៅបាន ។

ជាចុងបញ្ចប់ សូមថ្លែងអំណរគុណដល់លោកប្រធាន លោកលោកស្រីចៅក្រម ពុកម៉ែ បងប្អូន ដែលមានវត្តមាននៅទីនេះឲ្យជួបតែសេចក្តីសុខគ្រប់ពេលវេលា ។ សូមអរគុណ សូមអរព្រះគុណ» ។

## ១៨) ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងស៊ូ

ថ្ងៃទី១១ និងថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់ សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងស៊ូ ។

ដើមបណ្តឹងរដ្ឋប្បវេណី ដេនីស អាហ៊ុងស៊ូ កើតនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៤៨ ក្នុងទីក្រុងភ្នំពេញ ។ សព្វថ្ងៃរស់នៅភាគខាងត្បូងនៃប្រទេសបារាំង ជាមន្ត្រីចូលនិវត្តន៍នៅក្រសួងការបរទេសរបស់បារាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុក ឈ្មោះ ម៉ូរីស លូស្យាង ជាជនជាតិបារាំង និងម្តាយឈ្មោះ ទ្រួង ធីឡេ និងស្វាមីឈ្មោះ រ៉ូប៉ែ អែកម៉ាន ជាជនជាតិចិន ។

នៅថ្ងៃទី១៧ ខែមេសា បន្ទាប់ពីទាហានខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញ ស្ថានទូតបារាំងបាន ប្រកាសឲ្យប្រជាជនបារាំងចាកចេញ ប៉ុន្តែលោកស្រីសម្រេចចិត្តពុំព្រមចាកចេញ ដោយសុខចិត្តនៅជាមួយស្វាមី និងកូននៅស្រុកខ្មែរ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា ស្វាមីរបស់លោកស្រីមានការទុកចិត្ត ទៅលើទាហានខ្មែរក្រហមណាស់ដោយគិតថាសន្តិភាពនឹងកើតមាន ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹង រដ្ឋប្បវេណី ដេនីស អាហ៊ុងស៊ូ នៅចំពោះមុខអង្គជំនុំជម្រះ ៖

“សូមអរគុណច្រើនលោកប្រធាន ។ ខ្ញុំចង់ប្រកាសនៅថ្ងៃនេះថា ក្នុងរយៈពេលនោះ ខ្ញុំបានទទួលរងនូវការឈឺចាប់យ៉ាងខ្លាំងជីវិតខ្ញុំនេះគឺថា ធ្លាប់តែនៅក្នុងប្រទេសដែលមានសន្តិភាពបានធ្លាក់ ចូលទៅក្នុងឋាននរក គឺឋាននរកប្រចាំថ្ងៃតែម្តង ។ ហើយគេដកហូតយើង អ្វីៗរបស់យើងគ្រប់បែបយ៉ាង គេដកហូតយើងចេញពីផ្ទះ គេរឹបអូសបំផ្លាញចោលនូវអ្វីៗដែលយើងបានកសាងជីវិតរយៈពេល៣០ឆ្នាំនោះត្រូវបានបំផ្លាញ ខ្ទេចខ្ទីឲ្យក្លាយជាផេះផង់ ។ ខ្ញុំនៅតែមានព្យសនកម្មជាច្រើនមកលើខ្ញុំ យើងមិនមានការថែទាំខាងផ្នែកពេទ្យ មិនមានគ្រូពេទ្យ យើងទទួលរងនូវការខ្វះខាតអាហារ មិនមានអនាម័យ ខ្ញុំកើតនូវជំងឺជាច្រើន ជំងឺដែលសំខាន់បំផុតសម្រាប់ខ្ញុំនោះ គឺខ្ញុំបានកើតរបេង ។ ប្រសិនបើកងទ័ពវៀតណាមមិនមកទាន់នោះទេ នោះគឺថាខ្ញុំស្លាប់បាត់ទៅហើយ គឺថាខ្ញុំបានព្យាបាលនៅមន្ទីរពេទ្យ សាំងអង់ទាន់ គឺថាខ្ញុំកើតជំងឺ

គ្រុនចាញ់ទៀត ។ ជំងឺទាំងពីរនេះហើយ ដែលខ្ញុំនៅតែមានស្លាក ស្នាមជាប់ជានិច្ច ។ ខ្ញុំនៅមានស្នាមនៃជំងឺគ្រុនចាញ់ ហើយជំងឺនេះ ដូចជានៅជាប់ខ្ញុំជាមួយខ្ញុំជានិច្ច ។ ហើយនៅពេលដែលយើង មានជំងឺគ្រុនញាក់ នៅពេលដែលគ្រុនចាញ់ ហើយគេទាញអូស យើងចេញពីផ្ទះឲ្យយើងចេញទៅធ្វើការនៅក្នុងស្រែ នៅក្រោម កម្តៅថ្ងៃហែងនោះ គឺថាខ្ញុំចង់សួរអស់លោកទៅមើលថា តើ លោកប្រធាន លោកមេធាវី លោក លោកស្រីចៅក្រមគិតទៅ មិនចាំបាច់ខ្វល់ពីកូនទេ ពួកវាមិនមែនជាកូនរបស់អ្នកឯងទៀតទេ ពីព្រោះថាពួកវាបានបំពាក់បំប៉នមនោគមវិជ្ជាអស់ហើយ ។ ហើយ នៅពេលដែលកូនរបស់ខ្ញុំជិតស្លាប់នោះ គឺថាបាយមួយកូនចាន ក៏ខ្ញុំមិនអាចផ្តល់ឲ្យកូនស្រីខ្ញុំនោះបានដែរ ។ កូនស្រីខ្ញុំ ស្លាប់ដោយ អត់បាយសូម្បីតែមួយកូនចាន ។ ខ្ញុំឈឺចាប់ខ្លាំងណាស់ ។ ខ្ញុំទទួល រងនូវព្យសនកម្មខ្លាំងណាស់ ហើយខ្ញុំអាចរៀបរាប់បានច្រើនផ្សេង ទៀត ។ អ្វីដែលពួកនោះបានធ្វើ តើសព្វថ្ងៃនេះគេបានដាក់ទោស


ប្រជាជនកម្ពុជាត្រឡប់ទៅលំនៅដ្ឋានវិញក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩ (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

មើលថា តើខ្ញុំលំបាកវេទនាប៉ុណ្ណា ។ ខ្ញុំទទួលរងនូវការឈឺចាប់ ទាំងផ្នែករាងកាយ ទាំងផ្នែកផ្លូវចិត្ត មិនអាចរៀបរាប់នូវអ្វីដែល បានកើតឡើង ឲ្យអស់នោះទេ ។ ជាដំបូងនោះ គឺការជម្លៀស គេបណ្តេញយើងឲ្យចេញពីផ្ទះ គេមិនស្តាប់យើងទេ គេឲ្យយើង ចេញ បើថាមិនចេញទេ គឺថាយើងមិនអាចនៅបានទៀតទេ នៅ ពេលដែលគេបណ្តេញយើងចេញពីផ្ទះទៅដល់ស្រុកស្រែ ហើយ គេឲ្យយើងធ្វើការជាទម្ងន់ ហើយគេសើចចំអកយើងទៀត ព្រោះ គេហៅខ្ញុំថាយាយបារាំង គេសើចចំអកចំពោះខ្ញុំ គេដកយកកូន ពីខ្ញុំចេញ មិនឲ្យនៅជាមួយខ្ញុំ ហើយមិនប្រាប់ខ្ញុំថាយកទៅណា ទៀត ។ គេគ្រាន់តែប្រាប់ថាអង្គការនឹងមើលថែកូនរបស់អ្នកឯង ហើយ មិនមែនជាកូនរបស់អ្នកឯងទេ គឺជាកម្មសិទ្ធិរបស់អង្គការ ពួកអ្នកប្រព្រឹត្តទាំងអស់នេះហើយឬនៅ? សព្វថ្ងៃនេះ ខ្ញុំនៅតែ មានអារម្មណ៍ឈឺចាប់ ប៉ុន្តែខ្ញុំត្រូវតែខំរស់នៅដើម្បីកូនរបស់ខ្ញុំ ខ្ញុំត្រូវតែប្រឹងរឹងមាំរឹងប៉ឹងឲ្យមានសុខភាពល្អ ។ ពួកគេបង្ខំឲ្យយើង ធ្វើការ ហើយអស់លោកគិតមើល ថាបើសិនជាអស់លោកជាខ្ញុំ វិញនោះ តើត្រូវធ្វើយ៉ាងម៉េច ដើម្បីចាកចេញពីស្ថានភាពបែប នេះ? ហើយបើសួរខ្ញុំថាមានព្យសនកម្មអ្វីខ្លះនោះ គឺយើងគិត មើលទៅថាភាពសាហាវឃោរឃៅ ការធ្វើទារុណកម្មការវាយ ទាត់ធាក់ ហើយគ្រាន់តែយើងលួចស្ករត្នោតបន្តិចនោះ គេយក យើងទៅហាលថ្ងៃ ។ ហើយឲ្យគេមើលមេរៀនយ៉ាងម៉េចៗនោះ គឺគេធ្វើបាបយើង គេមិនគោរពសិទ្ធិមនុស្សទាល់តែសោះ ។ គេ សម្លាប់មនុស្សស្រេចតែនឹងចិត្ត ។ យើងមិនមែនជាមនុស្សទេ

គេចាត់ទុកដូចជាសត្វធាតុ គឺគេលែងគិតយើងជាមនុស្សហើយ គេគិតថាយើងជាសត្វតែប៉ុណ្ណោះ ។ ខ្ញុំនៅតែនិយាយម្តងហើយម្តងទៀតថា នៅពេលនោះ គឺថាគ្រោះអត់ឃ្លាននោះ គេគ្រោងផែនការដើម្បីធ្វើម៉េចឲ្យប្រជាជនអត់ឃ្លានស្លាប់ឲ្យមានតែដៃទទេ ។ ហើយគេបានប្រាប់ថា បើសិនជាអត់បាយនោះ ម៉េចក៏ពួកយើងមិនស្លាប់ យើងក៏អត់បាយដែរ កុំចេះតែថាយើងអត់បាយស្លាប់នោះ ។ គេមិនបានថែទាំព្យាបាលយើងទេ ពេលយើងឈឺគ្មានថ្នាំសង្កូវសម្រាប់ឲ្យយើងព្យាបាលទេ គឺគេសម្លាប់យើង ។ គេរៀបចំផែនការ ដើម្បីសម្លាប់យើងដោយការបង្អត់បាយយើងតែម្តង ។ សព្វថ្ងៃនេះខ្ញុំសុបិន្តអាក្រក់រហូតនៅពេលយប់ គឺថាសុបិន្តមកលងខ្ញុំ ។ ខ្ញុំមិនអាចឈានជើងចូលមកប្រទេសកម្ពុជាទៀតទេ ទោះខ្ញុំស្រលាញ់កម្ពុជា តែខ្ញុំមិនអាចមកទេអស់រយៈពេលជាង៣០ឆ្នាំមកហើយ ។ ខ្ញុំមិនអាចលើកជើងឈានចូលទឹកដីកម្ពុជា បានទេ ព្រោះថាវាធ្វើឲ្យខ្ញុំនឹកឃើញសុបិន្តអាក្រក់ទាំងឡាយដែលខ្ញុំបានឆ្លងកាត់ ដែលខ្ញុំបានទទួលរង ។ ខ្ញុំក៏ដូចជាប្រជាជនកម្ពុជាដែរ គឺថាយើងមិនអាចទទួលរងទ្រាំទ្រនូវអំពើទាំងអស់នេះបានទេ ។ វាមានទំហំធំធេងណាស់ មិនមែនមានតែខ្ញុំម្នាក់ឯងទេ គឺថាមានមនុស្សរាប់លាននាក់ដែលទទួលរងនូវការឈឺចាប់ ។ ពួកគេឈឺចាប់ទាំងអស់គ្នា ។ ហើយថ្ងៃនេះ បើសិនជាអ្នកណាអាចរៀបរាប់ការឈឺចាប់បាន ពួកគេនឹងមានការធូរស្រាលហើយ ។ ខ្ញុំមិនអាចកសាងនូវជីវិតថ្មីបានទេ ដោយសារតែរឿងទាំងអស់នេះ ។ ឥឡូវនេះខ្ញុំនៅសល់តែកូនប្រុសម្នាក់គត់ ហើយកូនប្រុសរបស់ខ្ញុំហ្នឹងក៏មានបញ្ហាតក់ស្លុតរន្ធត់ ជាប់ជានិច្ចព្រោះថា គេធ្វើទារុណកម្មវា ដូច្នេះវានៅតែរន្ធត់នឹកឃើញរឿងនោះឡើង វាមានការប៉ះទង្គិចផ្លូវចិត្តយ៉ាងខ្លាំង ។ ដូច្នេះអ្នកដែលបានប្រព្រឹត្តនូវអំពើទាំងអស់នោះ សូមឲ្យទទួលរងនូវកាត់ទោសឲ្យបានយុត្តិធម៌បំផុត ។ លោកប្រធាន សូមអរគុណលោកប្រធាន ហើយសូមអរគុណដល់តុលាការទាំងមូលផងដែរ» ។

## ១៥) ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ

នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ ជាជនរងគ្រោះដែលបានបាត់សមាជិកគ្រួសារទាំងអស់ដោយសាររបបខ្មែរក្រហម និងជាអ្នកនិពន្ធសៀវភៅ «ជីវិតកូនថ្ងៃកូនត្រូវតែរស់» និង «មនោគមវិជ្ជាមហាឃាតករ» ។ ។

ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ កើតនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៤ មានស្រុកកំណើត នៅក្នុងស្រុកខ្សាច់កណ្តាល ខេត្តកំពង់ស្ពឺ ។ សព្វថ្ងៃលោកជាវិស្វករចូលនិវត្តន៍ រស់នៅក្នុងប្រទេសបារាំង ។ ដើមបណ្តឹងរដ្ឋប្បវេណី មានឪពុកឈ្មោះ ឆោ ម្តាយឈ្មោះ ស៊ីវលន និងប្រពន្ធឈ្មោះ ម៉ាលីកា និង មានកូនប្រុសបីនាក់ ។ ចាប់ពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ មុនពេលខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ លោកគឺជាវិស្វករនៅក្រសួងសាធារណៈការ ។ លោកបានទទួលសញ្ញាបត្រវិស្វករនៅឆ្នាំ១៩៦៥ នៅសាលាបច្ចេកទេសមួយក្នុងទីក្រុងម៉ុងរេអាល់ ប្រទេសកាណាដា ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ និងក្រុមគ្រួសារបានចាកចេញពីផ្ទះនៅពីមុំទឹកល្អក់មកស្នាក់នៅមុំផ្សារស៊ីឡូបជាមួយបងប្អូនជីដូនមួយ ។ នៅពេលមកដល់ផ្សារស៊ីឡូប លោកបានទទួលដំណឹងថា ប្រជាជននៅក្នុងទីក្រុងទាំងអស់ត្រូវឲ្យចាកចេញពីទីក្រុង ។ បន្ទាប់ពីទទួលបានដំណឹងនេះ លោកបានចាកចេញពីផ្សារស៊ីឡូបដើម្បីទៅស្នាក់នៅវត្តខណ្ឌលោម ដោយសារនៅទីនោះមានសម្តេចព្រះសង្ឃរាជ ហួត តាត ត្រូវជាជីតារបស់លោកគង់នៅទីនោះ ។ បន្ទាប់ពីស្នាក់នៅក្នុងវត្តបានមួយយប់ លោក ពិន យ៉ាថៃ និងក្រុមគ្រួសារ បានបន្តដំណើរតាមផ្លូវមន្ទីរពេទ្យទៅដល់ស្រុកកោះធំ និងបានស្នាក់នៅកន្លែងមួយឈ្មោះថា ឈើខ្មៅ ។

រយៈពេលបីខែក្រោយមកខ្មែរក្រហមបានប្រកាសថា «មានអ្នកណាចង់ទៅស្រុកកំណើតទេ? ស្រុកកំណើតអ្នកណានៅខេត្តកំពត និងនៅកំពង់ស្ពឺ អាចចេញដំណើរបាន» ។ នៅពេលឮដូច្នោះ លោក និងក្រុមគ្រួសារដែលមានសមាជិកទាំងអស់១៨នាក់បានលើកដៃ ដោយសារមានស្រុកកំណើតស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ។ ប៉ុន្តែខ្មែរក្រហមពុំបានដឹកប្រជាជនទាំងនោះទៅតាមទិសដៅ ដែលបានរំពឹងទុកឡើយ ដោយសារផែនការរបស់អង្គការ គឺដឹកអ្នកទាំងនោះទៅដាក់នៅខេត្តតាកែវ ។ បន្ទាប់ពីស្នាក់នៅទីនោះ បាន២សប្តាហ៍ ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ និងគ្រួសារ រួម

ជាមួយប្រជាជនផ្សេងទៀតត្រូវបានអង្គការបញ្ជូនឲ្យទៅបាត់ដំបងវិញ ។ ការធ្វើដំណើរនៅពេលនោះ គឺត្រូវជិះរថយន្តដូចពេលជម្លៀសមុនៗដែរ ដោយនៅក្នុងរថយន្តនីមួយៗមានមនុស្សប្រហែលមួយរយនាក់ ។ ដោយសារការធ្វើដំណើរនោះ ពុំមានពេលសម្រាក ដូច្នេះមានប្រជាជនខ្លះបានបន្ទោរបង់នៅលើរថយន្ត ។ នៅពេលធ្វើដំណើរមកដល់ខេត្តពោធិ៍សាត់ រថយន្តទាំងនោះបានបត់ចុះពីលើផ្លូវជាតិលេខ៥សំដៅទៅកាន់ស្រុកភ្នំក្រវាញ និងបន្តរហូតទៅដល់វាលវែង ទើបខ្មែរក្រហមអនុញ្ញាតឲ្យប្រជាជនចុះ ហើយស្នាក់នៅទីនោះតែម្តង ។ ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ រៀបរាប់ថា វាលវែង គឺជាតំបន់នៅតាមជើងភ្នំ ពុំមានផ្ទះសម្បែង ។ នៅទីនោះពុំមានអាហារហូបចុកគ្រប់គ្រាន់ គ្មានថ្នាំព្យាបាល និងមានការកាប់សម្លាប់មនុស្សជាច្រើន ។ ប្រជាជនជាច្រើននាក់បានស្លាប់ និងបាត់ខ្លួនជាបន្តបន្ទាប់ ក្នុងនោះក៏មានសមាជិកក្រុមគ្រួសាររបស់លោកចំនួន៨នាក់ដែរ ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពិន យ៉ាថៃ នៅចំពោះមុខអង្គជំនុំជម្រះ ៖

*“បាទ! សូមអគុណលោកប្រធាន ។ សូមគោរពលោកប្រធានអង្គជំនុំជម្រះ សូមគោរពលោក លោកស្រីចៅក្រម ។ សូមគោរពអង្គសវនាការទាំងមូល ។*

ខ្ញុំដឹងហើយ យើងដឹងហើយថា មនុស្សយើងស្លាប់ច្រើនណាស់! តើគ្រួសារប្រជាជនថ្មីណាដែលគ្មានអ្នកស្លាប់? មានគ្រួសារច្រើនណាស់ដែលបានស្លាប់ទាំងពូជតែម្តង ដូចជាគ្រួសារប្អូនប្រុសខ្ញុំ ដែលមានគ្នាប្រាំនាក់ និងគ្រួសារប្អូនស្រីខ្ញុំដែលមានគ្នាបីនាក់ជាដើម ។

ក្នុងចំណោមគ្រួសារតូចរបស់ខ្ញុំ ដែលមានគ្នាប្រាំនាក់ ខ្ញុំ ប្រពន្ធខ្ញុំ និងកូនបីនាក់ ហើយនឹងគ្រួសារធំរបស់ខ្ញុំ ដែលមានគ្នា ១៨នាក់ដែលខ្ញុំបានជម្រាបតាំងពីដើម ពេលដែលខ្ញុំនិយាយពីការជម្លៀសប្រជាជនយើងតាំងពីភ្នំពេញមកនោះ ដែលនៅជាប់គ្នារហូត១៨នាក់ហ្នឹង ។ ទាំងអស់ហ្នឹងស្លាប់អស់នៅតែខ្ញុំម្នាក់ទេ ។ ខ្ញុំម្នាក់គត់ដែលបានរស់រានមានជីវិត ហើយដែលបានមានឱកាសមកជម្រាបជាសក្ខីកម្មជូនអង្គសវនាការនៅពេលនេះ ។

ដូច្នេះជាបឋម ខ្ញុំសូមសម្តែងសេចក្តីសោមនស្សសាទរចំពោះការបង្កើតឲ្យមានអង្គជំនុំជម្រះ ពិសេសនេះ ដែលបានឲ្យឱកាសខ្ញុំជាអ្នករងគ្រោះមកជម្រាបព័ត៌មានទាំងអស់ដែលខ្ញុំបានរស់នៅក្នុងរបបខ្មែរក្រហម ហើយនិងអ្វីខ្លះដែលខ្ញុំបាត់មិនមែនតែសម្ភារផ្ទះសម្បែងទេ បាត់ធំបំផុត គឺវិជ្ជាជីវៈរបស់យើង ការរស់នៅធម្មតារបស់យើងអស់រលីង ។ អស់ទាំងកូន ទាំងប្រពន្ធ ទាំងម៉ែ ទាំងឪ ទាំងបងប្អូន ។ ថ្វីត្បិតតែមានការយឺតយ៉ាវ និងការមានការខ្វះខាត ឬរកាំរកូសខ្លះៗកន្លងមក ខ្ញុំយល់ថា អង្គជំនុំជម្រះវិសាមញ្ញនេះមានសារៈសំខាន់ជាប្រវត្តិសាស្ត្រ សម្រាប់ស្វែងរកការពិត និងយុត្តិធម៌ ជូនប្រជាជនខ្មែរយើង ។ ជាពិសេស ដោយអង្គជំនុំជម្រះនេះបានដំណើរការដោយតម្លាភាព និងមានមធ្យោបាយគ្រប់គ្រាន់មកដល់ពេលនេះ ដើម្បីបំពេញកិច្ចការរបស់ខ្លួនក្រោមចក្ខុ និងការពិនិត្យតាមដានរបស់អ្នកអង្កេតការណ៍ជាតិ និងអន្តរជាតិទូទៅ ។ នៅពេលនេះ ខ្ញុំមានសំណូមពរតែមួយគត់ គឺធ្វើយ៉ាងណា ឲ្យការកាត់ក្តីបានដល់ទីដៅយ៉ាងឆាប់បំផុត ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ ទាំងខ្ញុំ ទាំងគេឲ្យបានជាស្ថាពរ ។ ដើម្បីសម្រេចគោលបំណងនេះ ខ្ញុំសូមធ្វើការអំពាវនាវដោយស្មោះ និងដោយទទូចដល់អស់លោកជាជនជាប់ចោទទាំងបីនាក់ ដែលធ្លាប់ជាអ្នកបដិវត្តន៍ដ៏ឆ្នើម មានមនសិការនយោបាយ ដ៏មោះមុត សូមលោកប្រកាន់ការទទួលខុសត្រូវខ្ពស់ក្នុងប្រវត្តិសាស្ត្រយើងដោយស្ម័គ្រចិត្ត ធ្វើស្វ័យទិតៀនចំពោះការដឹកនាំអង្គការបដិវត្តន៍ក្នុងរយៈពេលដែលអស់លោកនៅកាន់អំណាចទាំងស្រុង ។

បើអស់លោកជាជនជាប់ចោទ សុខចិត្តធ្វើការស្វ័យទិតៀនអស់លោកនឹងឃើញច្បាស់នូវលទ្ធផលជាក់ស្តែងឥតប្រកែកបានតាមរយៈភ័ស្តុតាងរាប់មិនអស់ដូចជា រណ្តៅរួមកប់ខ្មោចដែលមានទូទាំងប្រទេស និងសក្ខីកម្មរបស់ជនរងគ្រោះរាប់មិនអស់ដែរនៃមហាឧក្រិដ្ឋកម្មរបស់អង្គការបដិវត្តន៍ ។ អង្គការបដិវត្តន៍បានបំផ្លាញ កម្ទេចចោលជីវិតមនុស្សរាប់សែនលាននាក់ដែលជាជាតិខ្មែរដូចគ្នា ដោយឥតប្រយោជន៍ ដើម្បីអភិវឌ្ឍគំនិតនៃមនោគមន៍វិជ្ជាកុម្មុយនីស្តដែលមានទ្រឹស្តីពិរោះស្តាប់ តែមនុស្សធម្មតាមិនអាចទទួលយកបាន ។ ការដឹកនាំរបស់អង្គការបដិវត្តន៍ បានបំផ្លាញ

ប្រទេសមួយដែលមានសោភ័ណភាព និងសម្បូរសប្បាយដោយសម្បត្តិធម្មជាតិឲ្យចុះក្រីក្រ គោកយ៉ាក ហើយប្រជាពលរដ្ឋទាំងអស់ក៏បានត្រូវទទួលមហាវិនាសកម្មគ្រប់ប្រភេទហួសពីការស្មាន ។

កំហុសធំបំផុតមួយរបស់អង្គការបដិវត្តន៍ គឺការលើកតម្កើងហួសហេតុចំពោះការអនុវត្តមនោគមវិជ្ជាសមូហភាពនេះ ជាជាងការយកចិត្តទុកដាក់រិះរកសុភមង្គលជូនប្រជាជនឯង ដែលជាភារកិច្ចចម្បងបំផុតរបស់អ្នកដឹកនាំប្រទេសជាទូទៅ ។

អស់លោកមិនអាចប្រកែកថា មិនដឹងមិនឮនោះទេ ព្រោះអង្គការប្រកាសខ្លួនឯងថាអង្គការ មានត្រចៀកគ្រប់ទិសទី មានភ្នែកដូចភ្នែកម្នាស់នៅក្នុងប្រទេសកម្ពុជាយើងទាំងមូល ។ បន្ទាប់ពីធ្វើការទិតៀននេះ អស់លោកជនជាប់ចោទទាំងបីគួរតែសារភាពកំហុស និងឧក្រិដ្ឋកម្មទាំងឡាយនោះដោយសុទ្ធចិត្ត និងដោយស្មោះស្ម័គ្រឲ្យសមជាអ្នកបដិវត្តន៍គំរូ ដែលហ៊ានទទួលខុសត្រូវទាំងស្រុងចំពោះអំពើមិនគប្បីដែលខ្លួនបានប្រព្រឹត្ត ។ ហើយនៅទីបំផុតក្រោយពីបានសារភាពរួចហើយ អស់លោកច្បាស់ជាមិនជិនទាស់ទេនឹងការសម្តែងការសុំទោសជាឧឡារិកដល់វិញ្ញាណក្ខន្ធជនរងគ្រោះទាំងអស់ ដែលបានទទួលមរណៈភាព និងជនរងគ្រោះជាច្រើនទៀតដែលកំពុងរស់នៅសព្វថ្ងៃនេះ ។ បើអស់លោកធ្វើដូច្នេះបានអង្គជំនុំជម្រះនឹងអាចបញ្ចប់ក្នុងរយៈពេលខ្លីខាងមុខនេះ ដោយគោលដៅរកការពិត ហើយគោលដៅរកការពិត និងយុត្តិធម៌ជូនប្រជាជនខ្មែរយើងក៏នឹងត្រូវបានសម្រេចជាស្ថាពរក្នុងពេលនោះដែរ ។

៣៨ឆ្នាំបានកន្លងបាត់ទៅហើយ តាំងពីសោកនាដកម្មដ៏ធំធេងបានកើតឡើងនៅស្រុកខ្មែរយើង ។ យើងភាគច្រើនក៏កាន់តែចាស់ជរាគ្រប់គ្នាដែរ តើយើងត្រូវធ្វើអ្វីមួយដើម្បីឲ្យអារម្មណ៍យើងបាត់ទុក្ខកង្វល់ ឲ្យបានស្ងប់ស្ងាត់ចិត្តក្នុងប៉ុន្មានឆ្នាំចុងក្រោយនៃជីវិតយើងនោះ? ខ្ញុំមានជំនឿយ៉ាងមុតមាំថា បើសេចក្តីអំពាវនាវរបស់ខ្ញុំនេះត្រូវបានអស់លោកទាំងបីទទួលយកទៅធ្វើការរិះគិតញែក ពិចារណាឲ្យបានជ្រាលជ្រៅ រួចធ្វើការសម្រេចជាវិជ្ជមាន យើងជនរងគ្រោះច្បាស់ជាអាចបានធូរចិត្តខ្លះដែរ ។

អនុស្សាវរីយ៍ជូរចត់ទាំងឡាយ កំហឹងការសោកស្តាយវិប្បដិសារីនានាច្បាស់ជារលត់ និងរសាយទៅបន្តិចម្តងៗពីសតិអារម្មណ៍យើងគ្រប់គ្នា ។ ហើយការផ្សះផ្សាទៀតក៏អាចសម្រួលនិងពង្រឹកថែមទៀតដើម្បីអនាគតកូនចៅយើង និងមាតុភូមិយើង



យុវនារីខ្មែរក្រហមកំពុងធ្វើការក្នុងរបបខ្មែរក្រហម (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជានិច្ចតទៅ ។ សូមអរគុណ» ។

## ១៦) ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន អតីតអ្នកបើកបររថយន្តជូនគណៈប្រតិភូបរទេស ។

ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន កើតថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៥៧ នៅភូមិត្រពាំងក្រពើ ឃុំរៀវ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ បច្ចុប្បន្នរស់នៅផ្ទះលេខ៨៩ ភូមិទី៥ សង្កាត់វាលវង់ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ ស សេន ម្តាយឈ្មោះ សាន សារឿន ប្រពន្ធឈ្មោះ ម៉ម សារ៉ុន មានកូនចំនួន៥នាក់ ។

ស សារិន បានចូលរួមក្នុងចលនាបដិវត្តន៍នៅអាយុ១៣ឆ្នាំ គឺចំពេលដែលសម្តេចព្រះបាទ នរោត្តម សីហនុ ប្រកាសអំពាវនាវឲ្យចូលព្រៃដើម្បីប្រឆាំងនឹងរបប នល់ នល់ បន្ទាប់ពីព្រះអង្គត្រូវបានលោកសេនាប្រមុខ លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ សារិន បានចូល រួមក្នុងចលនានេះតាមការណែនាំរបស់ ទន់ គ្រី ជាមេបញ្ជាការយោធាតំបន់២១ ហើយបានចូលពេញសិទ្ធិ នៅក្នុងខែសីហា ឆ្នាំ១៩៧៣ គឺចំពេលដែលមានការអំពាវនាវឲ្យយុវជនទាំងអស់ចូលរួមវាយផ្តាច់យកទីក្រុងភ្នំពេញ ។ នៅពេលចូលដំបូង សារិន មានតួនាទីជាអ្នកសម្តែងសិល្បៈ ដោយទទួលបន្ទុកផ្សព្វផ្សាយមាគ៌ា និងគោលនយោបាយរបស់រណសិរ្សរួបរួមជាតិ ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ត្រូវបានបញ្ជូនទៅមន្ទីរក-៧ដើម្បីដាំបន្លែមួយរយៈមុនពេលត្រូវបញ្ជូនទៅធ្វើការនៅមន្ទីរក-១២ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ ។

ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន អះអាងថា អតីតខ្មែរក្រហមជាច្រើន ពុំសប្បាយចិត្តឡើយ នៅពេលដែលតុលាការនាំយកមេដឹកនាំរបស់ពួកគេមកកាត់ទោសដូច្នេះ និងថា អ្នកទាំងនោះអាចនឹងមិនសប្បាយចិត្ត នៅពេលដែលលោកផ្តល់សក្ខីកម្មប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បញ្ជាក់ថា ប្រសិនបើអង្គជំនុំជម្រះនៅតែមានបំណងចង់ឲ្យលោកផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងកិច្ចប្រជុំរបស់បក្សកុម្មុយនីស្តកម្ពុជា លោកស្នើសុំឲ្យរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិចាត់វិធានការការពារសន្តិសុខសម្រាប់រូបលោករហូតអស់មួយជីវិត ដោយស្នើសុំកងកម្លាំងប្រដាប់អាវុធ ចំនួន៤នាក់ ការពាររហូតដល់គាត់អស់ជីវិត ។ រាល់ការចំណាយផ្សេងៗ ដូចជាប្រាក់បៀវត្ស បាយទឹកសម្រាប់អ្នកការពារទាំងនោះ គឺជាបន្ទុករបស់រដ្ឋ ។

អង្គជំនុំជម្រះបានបដិសេធចំពោះសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ដោយបញ្ជាក់ថា «...សំណើរបស់លោកដែលបានសុំឲ្យអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាផ្តល់កិច្ចការពារសន្តិសុខសម្រាប់រូបលោកចាប់ពីពេលនេះ រហូតដល់អស់មួយជីវិតនោះ គឺមិនមានហេតុផលសមស្របទេ ។ អង្គជំនុំជម្រះសូមជម្រាបផងដែរថា អង្គជំនុំជម្រះគ្មានយុត្តាធិការសម្រេចតាមសំណើរបស់លោកបែបនេះទេ ។ អង្គជំនុំជម្រះក៏មិនសម្រេចផ្តល់នូវវិធានការផ្សេងៗទៀតជូនលោកដែរ ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចបញ្ចប់ការស្តាប់សក្ខីកម្មរបស់លោកត្រឹមនេះ...» ។

សូមបញ្ជាក់ថា មុននឹងចេញសេចក្តីសម្រេចនេះ អង្គជំនុំជម្រះបានសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បញ្ជាក់អំពីភាពត្រឹមត្រូវនៃប្រតិចារិកដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចម្លងចេញពីខ្សែអាត់ថតសំឡេង ដែលបានថតនៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើសម្ភាសន៍ជាមួយលោក ។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បានបញ្ជាក់ថា ប្រតិចារិកនោះ គឺពិតជាត្រឹមត្រូវតាមអ្វីដែលលោកបានផ្តល់បទសម្ភាសន៍ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ជាងនេះទៅទៀត គាត់មានជំនឿជាក់ទៅលើការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។

## ១៧) ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី ។

ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី កើតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៤០ នៅភូមិកន្ទួតធំ ឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ។

ឪពុកឈ្មោះ ស៊ូ យឹម និង ម្តាយឈ្មោះ កូវ សុគន្ធ ស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ដើមបណ្តឹងរដ្ឋប្បវេណីបច្ចុប្បន្នមិនទាន់មានគ្រួសារទេ ។

នៅក្នុងថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខណៈដែល ស៊ូ សុទ្ធាវី កំពុងរស់នៅក្នុងស្ថាគអូឡាំពិក ជាមួយមិត្តភ័ក្តិដែលជាភេទទីពដូចគ្នា សុទ្ធាវី និងមិត្តភ័ក្តិត្រូវខ្មែរក្រហមភ្ជង់នឹងកាំភ្លើង រួចបញ្ជាឲ្យចាកចេញពីកន្លែងស្នាក់នៅ ដោយមិនផ្តល់ពេលវេលាសម្រាប់រៀបចំឥវ៉ាន់នោះឡើយ ។ ស៊ូ សុទ្ធាវី បានបញ្ជាក់ថា នៅពេលនោះខ្មែរក្រហមបានបាញ់សម្លាប់មិត្តភ័ក្តិរបស់គាត់ចំនួន៤នាក់ស្លាប់ភ្លាមៗ ។ អ្នកទាំងនោះរួមមានឈ្មោះ សារ៉ាយ, ឌី, រដ្ឋា និងដល្លា ។ បន្ទាប់មក សុទ្ធាវី ត្រូវខ្មែរក្រហមបញ្ជូនចេញពីទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ១ ជាមួយប្រជាជនជាច្រើនទៀត ។ ពេលទៅដល់ស្ពានព្រះមុនី វង្ស ស៊ូ សុទ្ធាវី បានឃើញខ្មែរក្រហមបាញ់សម្លាប់ប្រជាជន ដែលពុំព្រមទៅតាមគោលដៅដែលគេបានកំណត់ ។ នៅតាមផ្លូវ ស៊ូ សុទ្ធាវី បានឃើញខ្មែរក្រហមចាប់រំលោភមិត្តភ័ក្តិរបស់គាត់យ៉ាងឃោរឃៅ ។ នៅពេលធ្វើដំណើរ ស៊ូ សុទ្ធាវី មានការតក់ស្លុតជាខ្លាំង ដោយសារបានឃើញសាកសពប្រជាជនសាមញ្ញ ទាហាន លន់ នល់ រួមទាំងព្រះសង្ឃស្លាប់ជាច្រើននៅតាមផ្លូវ និងមានអ្នកត្រូវរបួស និងអ្នកជំងឺទ្រហោយំជាច្រើន ។

ស៊ូ សុទ្ធាវី បានរៀបរាប់ទៀតថា នៅក្នុងរបបខ្មែរក្រហម រាងកាយរបស់គាត់មានសភាពទ្រុឌទ្រោម និងស្គមយ៉ាងខ្លាំង ដោយសារពុំមាន អាហារ ទឹក គ្មានពេលសម្រាក គ្មានថ្នាំព្យាបាលជំងឺ គ្រប់គ្រាន់ និងត្រូវធ្វើការជាទម្ងន់ ។ លើសពីនេះទៀត គាត់ទទួលរងការចាប់រំលោភជាច្រើនលើក និងទទួលរងការប្រើអំពើហិង្សាដោយវាយបំបាក់ឆ្អឹងថ្គាម ព្រមទាំងដាក់ច្រវ៉ាក់ជើងបន្សាំងក្នុងគុករហូតធ្វើឲ្យស្នងជើងស្តាំមានដំបៅរលួយយ៉ាងខ្លាំង ហើយថ្គាម និងខ្នងជើងរបស់គាត់នៅតែបង្កបញ្ហា ដែលធ្វើឲ្យឈឺចាប់រហូតដល់ពេលបច្ចុប្បន្ន ។

ស៊ូ សុទ្ធាវី បានបញ្ជាក់ថា ការផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះមានសារសំខាន់ណាស់ ព្រោះគាត់បានរង់ចាំអស់រយៈពេល៣០ឆ្នាំ មកហើយក្នុងបំណងស្វែងរកយុត្តិធម៌ និងពុំចង់ឲ្យក្មេងៗជំនាន់ក្រោយយកគំរូតាមខ្មែរក្រហម ព្រមទាំងចង់បង្ហាញជនរួមជាតិខ្មែរ និងអន្តរជាតិឲ្យដឹងថាជនរងគ្រោះនៃរបបខ្មែរក្រហមទទួលរងការឈឺចាប់មានទំហំប៉ុណ្ណា រហូតដល់ពេលបច្ចុប្បន្ននេះ ។ នៅចុងបញ្ចប់នៃសវនាការ ស៊ូ សុទ្ធាវី ស្នើសុំបង្កើតបណ្ណាល័យសម្រាប់ដាក់តាំងឯកសាររបបខ្មែរក្រហម និងស្តូបសម្រាប់គោរពបូជា ដើម្បីជាសំណងសម្រាប់ជនរងគ្រោះ ។

សូមបញ្ជាក់ថា នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ក្រោយពីដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុទ្ធាវី អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សេចក្តីថ្លែងទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីរូបផ្សេងទៀត រួមមាន ទី១ លោក អួន ដល្លី ទី២ លោកស្រី សាំង រ៉ាត់ និងទី៣ លោក យស ដល ។

## ១៨) ដើមបណ្តឹងរដ្ឋប្បវេណី អួន ដល្លី

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី អួន ដល្លី ។ អួន ដល្លី មានអាយុ ៤៨ឆ្នាំ កើតនៅភ្នំពេញ ។ បច្ចុប្បន្នរស់នៅស្រុកពញាឮ ខេត្តកណ្តាល និងជាយោធិនចូលនិវត្តន៍ ។ ឪពុកឈ្មោះ អុន (ស្លាប់), ម្តាយឈ្មោះ មាន (ស្លាប់) និងប្រពន្ធឈ្មោះ ពេជ ណម ។ អួន ដល្លី ព្រមទាំងគ្រួសារត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ ។ អួន ដល្លី ធ្វើដំណើរអស់រយៈពេល១៥ថ្ងៃ ទើបទៅដល់ភូមិព្រែកភ្លោ ខេត្តព្រៃវែង ។ ឪពុករបស់ អួន ដល្លី ត្រូវបានខ្មែរក្រហមហៅត្រឡប់ទៅវិញ ហើយបាត់ខ្លួនរហូត ។ ដោយដឹងពីដោកនាដកម្មរបស់ប្តី ម្តាយរបស់ អួន ដល្លី បានឲ្យ អួន ដល្លី ទៅរស់នៅជាមួយនឹងជីដូន ។ បន្ទាប់ពីទៅរស់នៅជាមួយនឹងជីដូនបានមួយរយៈ អួន ដល្លី ទទួលដំណឹងថាម្តាយ និងប្អូនៗរបស់គាត់ ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលទាំងអស់ ។

នៅឆ្នាំ១៩៧៧ អួនដល្លី បងប្អូនជីដូនមួយ និងជីដូនត្រូវបានខ្មែរក្រហមបញ្ជូនទៅស្រុកមោងឫស្សី ។ នៅទីនោះ អួន ដល្លី បានឃើញប្រជាជនជាច្រើនស្លាប់ដោយសារតែភាពអត់ឃ្លាន ហើយនៅក្នុងចំណោមអ្នកស្លាប់ទាំងនោះក៏មានបងប្អូនជីដូនមួយ និងជីដូនរបស់គាត់ដែរ ។ ដូច្នេះ គាត់ត្រូវរស់នៅតែម្នាក់ឯង និងទទួលរងការវាយធ្វើបាប ។ អួន ដល្លី បញ្ជាក់ថា គាត់ទទួល

វេទនាការឈឺចាប់នៅក្នុងចិត្តយ៉ាងខ្លាំង ដោយសារតែខ្មែរក្រហមបានបំបែកឪពុកម្តាយ និងបងប្អូន បណ្តោយឲ្យគាត់រស់នៅដោយគ្មានទីពឹង ។ ដោយសារមូលហេតុនេះ ទើបជំរុញឲ្យគាត់ចូលបម្រើកងទ័ពនៅក្រោយពេលរបបខ្មែរក្រហមបានដួលរលំ ។ អូន ផល្លី បានរៀបរាប់ថា ៖

“បាទ! ក្រោយមកដោយសារតែទុក្ខសោកនេះហើយ បានជាធ្វើឲ្យខ្ញុំស្ម័គ្រចិត្ត ធ្វើជាកងទ័ព នាំឲ្យរងរបួសពិការ និងគ្រុនចាញ់ជាបន្តបន្ទាប់ បណ្តាលឲ្យមានជំងឺប្រចាំកាយរហូតដល់បច្ចុប្បន្ន ។ ហើយកាលនោះខ្ញុំរស់នៅតែក្នុងបន្ទាយទេ យកបន្ទាយធ្វើជាភូមិកំណើតរហូតដល់មានមិត្តភ័ក្តិរួមអាវុធ ក្នុងអង្គភាពជាមួយគ្នាគេបានយកមកនិយាយលេង ក៏ដូចជាចំអកមើលងាយដល់រូបខ្ញុំថាខ្ញុំមិនដឹងឪពុកម្តាយឈ្មោះអី ស្រុកកំណើតនៅឯណា ដោយសារតែខ្ញុំមិនដែលទៅផ្ទះនឹងគេម្តងសោះក្នុងមួយឆ្នាំ ។ រីឯចំណែកគេគ្រប់គ្នាវិញ គេបានធ្វើដំណើរពី ៤ទៅ៥ដងក្នុងមួយឆ្នាំគេបានទៅលេងផ្ទះ ។ ខ្ញុំមានការឈឺចាប់ណាស់ ។ ខ្ញុំលាក់លៀមបៀមទុក្ខរហូត ខ្ញុំមិនប្រកាន់នឹងគេទេ ។ គ្មានពាក្យអ្វីឆ្លើយតបនឹងគេទេ ដោយសារតែខ្ញុំចង់លាក់លៀមបៀមទុក្ខនូវប្រវត្តិរបស់ខ្ញុំ ។ តើហេតុអ្វី? មកពីខ្ញុំចេះតែមានអារម្មណ៍គិតថា ស្រមោលអតីតកាលនៅតែតាមលងខ្ញុំ ទើបខ្ញុំលាក់លៀម ។ នេះជាលើកទីមួយហើយ ដែលជាទំព័រជីវិត ជាប្រវត្តិសាស្ត្រដែលខ្ញុំត្រូវបានលាតត្រដាងទៅកាន់ពិភពលោក ។

ជាចុងក្រោយនេះខ្ញុំសូមសំណូមពរឲ្យតុលាការជួយស្វែងរកយុត្តិធម៌ អ្នកដែលបានបាត់បង់ជីវិត ក្នុងរបបនេះ ជាពិសេសគ្រួសាររបស់ខ្ញុំផ្ទាល់ និងស្វែងរកយុត្តិធម៌សម្រាប់អ្នកដែលរស់រានមានជីវិតដូចជារូបខ្ញុំ និងប្រជាជនកម្ពុជាទូទាំងប្រទេស ហើយខ្ញុំសូមអង្វរកដល់អ្នកដឹកនាំជំនាន់នេះ ឬក៏ជំនាន់ក្រោយៗទៀតក្តី និងមានអ្នកដឹកនាំគ្រប់ជាតិសាសន៍នៅក្នុងពិភពលោក ទោះជាមានជំនឿប្រពៃណី សាសនាខុសគ្នាប៉ុណ្ណាក្តី សូមឲ្យបញ្ចប់ការឈឺចាប់ភាពវេទនា ភាពខ្លោចផ្សានេះទៅ ព្រោះជាក់ស្តែង ខ្ញុំជាសក្ខីភាពស្រាប់ ខ្ញុំបានជួបប្រទះអ្វីគ្រប់បែបយ៉ាង ។ ឈឺចាប់ណាស់ ហើយការឈឺចាប់នេះ ក៏អាចទៅសង្គ្រាមលោកបានដែរ ព្រោះតែខ្ញុំអស់លើង បានខ្ញុំចង់ឲ្យពិភពលោកនេះខ្ទេចរលាយ ។ កុំឲ្យការឈឺចាប់នេះរីកធំធាត់ដុះដាលរហូតដល់សង្គ្រាមលោក ។ សូមរួមគ្នាបញ្ចប់ទៅ ពិភពលោកទាំងឡាយអើយ ។ ការឈឺចាប់ទាំងឡាយនេះ ការរស់នៅ ការតែលតោលឯកោម្នាក់ឯងនេះ បៀមទុក្ខនេះគឺពិបាកទ្រាំណាស់ ។ ទោះជាយើងមានការហូបចុក ស៊ីចាយយ៉ាងណាក្តី ក៏យើងនៅតែមានអារម្មណ៍ឈឺចាប់ក្នុងចិត្តរហូតព្រោះដោយសារតែយើងគ្មានអ្វីពឹងផ្អែក ថែមទាំងគ្មានកូនទៀតដោយសារតែខ្ញុំមានជំងឺ ។ កាលនោះខ្ញុំបានសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមួយ កន្លែងទៅមួយកន្លែងឃើញតែគេមានឪពុកម្តាយបងប្អូន ប្រពន្ធកូនមើលថែទាំចេញចូលបម្រើទឹកក្តៅ ទឹកត្រជាក់ ។ រីឯមើលមកខ្លួនឯងប្រឹងត្រដររស់ទៅតាមយថាកម្មរបស់ខ្លួន ។ គ្មាននរណាដឹងដោយសារតែខ្ញុំចង់លាក់លៀមនូវជីវប្រវត្តិជីវិតរបស់ខ្ញុំអស់រយៈពេលជាង៣០ឆ្នាំ ។ សូមបញ្ចប់” ។

## ១៩) ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សាំង រ៉ាត់ ។ សាំង រ៉ាត់ មានអាយុ៧២ឆ្នាំ កើតនៅភូមិព្រៃស្វា ឃុំជំរះពេន ស្រុកសំរោង ។ សព្វថ្ងៃរស់នៅខេត្តកំពង់ស្ពឺ ។ ម្តាយឈ្មោះ គីម ឪពុកឈ្មោះ សាំង និងស្វាមីឈ្មោះ ភួន (ស្វាមីទី២) ។ សាំង រ៉ាត់ មានកូនចំនួន ១នាក់ ។

សាំង រ៉ាត់ ត្រូវខ្មែរក្រហមជម្លៀសចេញពីខេត្តកំពង់ស្ពឺទៅស្រុកមោងឫស្សី ខេត្តបាត់ដំបង នៅចុងឆ្នាំ១៩៧៥ ជាមួយស្វាមីដើម និងកូន៤នាក់ ។ សាំង រ៉ាត់ បញ្ជាក់ថា នៅពេលធ្វើដំណើរ គឺមានការលំបាកជាខ្លាំង ព្រោះពុំមានឡានតូចហើយដឹកមនុស្សច្រើន និងពុំមានអាហារហូបឡើយ ។ នៅចុងឆ្នាំ១៩៧៦ កូនៗទាំង៤នាក់ និងស្វាមីរបស់គាត់បានស្លាប់បន្តបន្ទាប់នៅចំពោះមុខដោយសារការអត់អាហារ ។ ក្នុងរយៈពេលតែ២យប់ប៉ុណ្ណោះ គាត់បានបាត់បង់កូនចំនួន៤នាក់ ព្រមទាំងស្វាមី នៅពេលនោះ សាំង រ៉ាត់ ពុំហានយំឡើយ ព្រោះខ្លាចខ្មែរក្រហមចោទថាជាខ្មាំង ។ ក្រោយពេលប្តី និងកូនបានស្លាប់ សាំង រ៉ាត់ ទទួលបានរបបអាហារប្រសើរជាងមុនបន្តិច ប៉ុន្តែជីវភាពរស់នៅរបស់គាត់នៅតែជួបការលំបាកវេទនា ហើយបានធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ខ្មែរ

# ដើមបណ្តឹងរដ្ឋប្បវេណី ទាំង ៣១រូប ក្នុងសំណុំរឿង ០០២/០១














































អែម អឿន
ជុំ សុខា
ឡាយ បូនី
មុំ សំអឿន
ពេជ្រ ស្រីផល
គីម វ៉ាន់ឌី
ដេនីស អាហ្វុងសូ
ពិន យ៉ាថៃ
យស ផល
ធុច ផាន់ដារា ស
ចាន់ សុជាតិ
ឆេង អេងលី
ប៉ូ ឌីណា
បេ សុផានី
សឿន សុវណ្ណឌី
សេង ស៊ីវុត្ថា

ក្រហមបានបញ្ជូន សាំង រ៉ាត់ ទៅព្យាបាលនៅមន្ទីរពេទ្យមួយនៅវត្តចាស់ ។ សាំង រ៉ាត់ បញ្ជាក់ថា អ្នកជំងឺដែលត្រូវបញ្ជូនឲ្យទៅព្យាបាលនៅមន្ទីរពេទ្យនោះគឺត្រូវស្លាប់ទាំងអស់ ។ ជាក់ស្ដែង គាត់បានឃើញបុគ្គលិកពេទ្យរបស់ខ្មែរក្រហមឲ្យថ្នាំទៅអ្នកជំងឺ ហើយអ្នកជំងឺនោះស្លាប់ភ្លាមៗបន្ទាប់ពីលេបថ្នាំនោះ ។ ក្រោយមកគាត់ទទួលបានថ្នាំនោះដូចគ្នា ។ ឃើញដូច្នេះ គាត់គេចចេញពីការលេបថ្នាំ ហើយកុហកបុគ្គលិកពេទ្យនោះថា គាត់បានលេបរួចហើយ ។ ក្រោយមក សាំង រ៉ាត់ ត្រូវបានគេបញ្ជូនទៅធ្វើការងារជាទម្ងន់ដូចមុនវិញ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ សាំង រ៉ាត់ បានត្រឡប់មករស់នៅស្រុកកំណើតវិញ ប៉ុន្តែត្រូវរស់នៅតែម្នាក់ឯង ។ សាំង រ៉ាត់ បញ្ជាក់ថា រូបគាត់មានការឈឺចាប់យ៉ាងខ្លាំង និងគ្មានពេលស្រាកស្រាន្តឡើយ ។ នៅចុងបញ្ចប់ សាំង រ៉ាត ស្នើសុំឲ្យតុលាការជួយរកយុត្តិធម៌ជូនក្រុមគ្រួសាររបស់គាត់ ដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។

## ២០) ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល

នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្ដាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ។ យស ផល មានអាយុ ៥៨ឆ្នាំ កើតនៅគោកញ៉ែរ ឃុំព្រៃស្វឹក ស្រុកទ្រាំង ខេត្តតាកែវ ។ បច្ចុប្បន្នរស់នៅភូមិ គោកឃ្មោង ឃុំរនាម ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ យស សួង (ស្លាប់) ម្ដាយឈ្មោះ យុន សន និងប្រពន្ធឈ្មោះ យិន សុភាព មានកូនចំនួន ៨នាក់ ។

នៅក្នុងរបប លន់ នល់ យស ផល បម្រើការងារជាមន្ត្រីនគរបាល ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ផល ត្រូវខ្មែរក្រហមប្រាប់ឲ្យចេញពីទីក្រុងភ្នំពេញរយៈពេលបីថ្ងៃ ដើម្បីរៀបចំទីក្រុង ។ ផល ធ្វើដំណើរចេញតាមស្ពានជ្រោយចង្វារ កាត់តាមកំពង់ចម្លងព្រែកក្ដាមរហូតដល់ស្រុកដ្ងាវ ។ យស ផល បានរៀបរាប់ថា នៅពេលធ្វើដំណើរគាត់បានឃើញសាកសពទាហាន និងមន្ត្រីនគរបាលនៃរបប លន់ នល់ ជាច្រើនស្លាប់នៅតាមផ្លូវ ។ ប្រជាជនទាំងក្មេងទាំងចាស់ត្រូវបានបង្ខំឲ្យធ្វើដំណើរ ទោះបីមានសុខភាពទ្រុឌទ្រោមយ៉ាងណាក៏ដោយ ។ នៅក្នុងអំឡុងពេលនៃការជម្លៀសនេះដែរ យស ផល បានឃើញឡានចិនធំៗចំនួន៣គ្រឿង បើកបរដោយខ្មែរក្រហម ដឹកមនុស្សចេញទៅតាមព្រែកក្ដាម តើយខាងកើតឆ្ពោះទៅស្រុកដ្ងាវ ។ ប៉ុន្តែពុំដឹងថាខ្មែរក្រហមយកទៅធ្វើអ្វីឡើយ ។ ប្រជាជនដែលជម្លៀសទៅដល់ស្រុកដ្ងាវត្រូវបានតម្រូវឲ្យធ្វើប្រវត្តិរូប ។ ក្នុងការធ្វើប្រវត្តិរូបនេះ យស ផលពុំហ៊ានប្រាប់អំពីប្រវត្តិពិតរបស់ខ្លួនឡើយ ដោយប្រាប់គេថា ខ្លួនជាភ្នាក់ងារបម្រុងរដ្ឋការ ។ យស ផល បានឃើញខ្មែរក្រហមបញ្ជូនអតីតអ្នកដែលមានស័ក្តិចាប់ពីសក្តិ១ឡើងទៅ ម្ដងមួយៗ យកទៅបាត់រហូត ហើយគាត់មានការភ័យខ្លាចយ៉ាងខ្លាំងនៅពេលដែលខ្មែរក្រហមសួរនាំអំពីប្រវត្តិការងាររបស់គាត់ ។ ជាពិសេស នៅពេលនឹកឃើញអំពីការសម្លាប់ទាហាន និងមន្ត្រីនគរបាលនៃរបប លន់ នល់ នៅតាមផ្លូវ ។ សាច់ញាតិទាំងអស់របស់ យស ផល បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ យស ផល បានបញ្ជាក់ជូនអង្គជំនុំជម្រះថា សម្រាប់រូបគាត់ផ្ទាល់ គឺថាបច្ចុប្បន្ននេះ គាត់នៅតែមានអារម្មណ៍ឆាប់ភ័យតក់ស្លុត ញ័រដៃញ័រជើង ចុកទ្រូង ដែលបណ្ដាលមកពីរបបខ្មែរក្រហម ។ ខាងក្រោមនេះជាសេចក្ដីថ្លែងទុក្ខសោក និងសំណើដែល យស ផល ថ្លែងនៅចំពោះមុខអង្គជំនុំជម្រះ ៖

*"បាទ! ថ្ងៃនេះខ្ញុំសូមអរគុណ ។ ខ្ញុំបានរង់ចាំធ្វើសក្ខីកម្មអស់ជាង៣០ឆ្នាំមកហើយ ។ ខ្ញុំពាំទុក្ខព្រួយពេញដើមទ្រូងពេញខ្លួន ។ ខ្ញុំមិនដឹងនិយាយការពិតហ្នឹង យកស្ដែងហ្នឹងកន្លែងណាទេ ។ អីចឹងមានតែស្ដែងនៅមុខតុលាការ សូមឲ្យតុលាការជួយរកយុត្តិធម៌ឲ្យខ្ញុំ ហើយខ្ញុំក៏បានរីករាយតាមហ្នឹងដែរ ។ ខ្ញុំជាជនក្រីក្រទៅហើយ វាបាត់បង់អស់ហើយគ្មានសល់អីទេ ។ កម្ទេចតាំងពីរបស់ទ្រព្យ កម្ទេច តាំងពីមាមីង ឪពុកម្ដាយ និងអ្វីៗទៀត ។ ប៉ុន្តែខ្ញុំសូមសំណូមពរ សុំស្តូបដើម្បីតម្កល់អដ្ឋិធាតុបងប្អូនជនរួមជាតិ ឪពុកម្ដាយ ញាតិសន្ដានខ្ញុំទី១ ។ ទី២ ខ្ញុំសូមបណ្ណាល័យ ដែលមានឯកសារសម្រាប់ដាក់ឲ្យក្មេងៗ និងប្អូនៗជំនាន់ក្រោយយកទៅសិក្សាឲ្យយល់ពីរបបខ្មែរក្រហម ហើយទីពី ខ្ញុំបាទសូមប័ណ្ណព្យាបាលជំងឺដោយមិនយកកម្រៃ ។ សូមអរគុណ"* ។

## ២១) ដើមបណ្ដឹងរដ្ឋប្បវេណី ធុច ផាន់ដារ៉ា ស

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលា

ដំបូងបានបើកសវនាការ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ធុច ផាន់ដារា ស ជាជនរងគ្រោះម្នាក់នៅក្នុងរបបខ្មែរក្រហម ។

ដើមបណ្តឹងរដ្ឋប្បវេណី ធុច ផាន់ដារា ស កើតនៅថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៤៧ មានស្រុកកំណើតនៅទីក្រុងភ្នំពេញ បច្ចុប្បន្នរស់នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ លោកស្រី ផាន់ដារា ស បញ្ជាក់ថា នៅពេលឃើញខ្មែរក្រហមចូលដល់ទីក្រុងភ្នំពេញភ្លាម លោកស្រីក៏ដូចជាប្រជាជនផ្សេងទៀត មានការសប្បាយរីករាយយ៉ាងខ្លាំង ព្រោះគិតថាប្រទេសនឹងមានសន្តិភាព ។ ពេលនោះ ប្រជាជនជាច្រើន រួមទាំងម្តាយរបស់លោកស្រី បានកាន់ទង់ជ័យសគ្រវី ហើយស្រែកថា «យើងលែងមានសង្រ្គាមទៀតហើយ» ។ ក្រោយមកបន្តិច យោធាខ្មែរក្រហមស្រែកឲ្យប្រជាជនចេញពីផ្ទះ ដោយប្រាប់ថា អង្គការត្រូវការរៀបចំទីក្រុងឲ្យបានស្អាត និងដើម្បីគេចពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ ពេលនោះ លោកស្រីមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះយោធាខ្មែរក្រហមបានបង្ហាញទឹកមុខយ៉ាងកាចសាហាវ ។ ភ្លាមៗនោះគ្រួសាររបស់លោកស្រី ផាន់ដារា ស រួមមានឪពុកម្តាយ និងកូនក្មេងចំនួន ៤នាក់ ត្រូវធ្វើដំណើរចេញពីផ្ទះយ៉ាងប្រញ៉ាប់ប្រញ៉ាល់ ដោយពុំបានយកទ្រព្យសម្បត្តិទៅតាមច្រើនឡើយ មានតែអង្ករ និងថ្នាំសង្កូវបន្តិចបន្តួចប៉ុណ្ណោះ ។

នៅពេលធ្វើដំណើរ ផាន់ដារា ស បានឃើញសាកសពជាច្រើននៅតាមផ្លូវ ហើយពេលនោះ គាត់កាន់តែមានការភ័យខ្លាចកាន់តែខ្លាំង ។ យោធាខ្មែរក្រហមស្រែកសម្លុតយកនាឡិកាពីប្រជាជន ដែលកំពុងធ្វើដំណើរក្រោយមកមានស្នូរបាញ់កាំភ្លើង ប៉ុន្តែលោកស្រីពុំហ៊ានឈប់នៅមើលឡើយ ហើយពេលនោះ លោកស្រីកាន់តែមានការភ័យខ្លាច ។ យោធាខ្មែរក្រហមប្រាប់ឲ្យប្រជាជនធ្វើដំណើរទៅមុខរហូត ប៉ុន្តែពុំប្រាប់ថាត្រូវទៅទីណាឡើយ ។ ក្នុងអំឡុងពេលនោះ មានស្រ្តីឆ្លងទន្លេនៅតាមផ្លូវ អ្នកជំងឺព្យួរសេរ៉ូមជាប់ដៃ កូនក្មេង និងមនុស្សចាស់ជាច្រើន បានធ្វើដំណើរដោយថ្មើរជើងក្រោមពន្លឺក្តៅហែង ដែលគួរឲ្យអាសូរបំផុត ។

ធ្វើដំណើរជាច្រើនថ្ងៃ ផាន់ដារា ស បានទៅដល់ភូមិអង្គរមាស ។ អ្នកភូមិបានខ្សឹបប្រាប់គាត់ឲ្យបំផ្លាញអត្តសញ្ញាណបណ្ណលិខិតស្នាមផ្សេងៗ និងប្តូរឈ្មោះ ផាន់ដារា ស ដាក់ឈ្មោះផ្សេង ។ ចាប់ពីពេលនោះមក ផាន់ដារា ស បានប្តូរឈ្មោះមក ធែល វិញ ។ នៅក្នុងភូមិនេះបានមួយរយៈពេលខ្លី ផាន់ដារា ស ត្រូវបានខ្មែរក្រហមជម្លៀសទៅដល់ខេត្តកំពង់ឆ្នាំង បន្តទៅបាត់ដំបង ចុងក្រោយទៅដល់ភ្នំដើងទិញ ។ នៅទីនោះពុំមានអ្វីទាំងអស់ ប្រជាជនដែលទៅដល់ទីនោះត្រូវសង់ខ្ទមនៅខ្លួនឯង ហើយទទួលបានរបបអាហារតែបន្តិចបន្តួចប៉ុណ្ណោះ ។ ប្រជាជននៅទីនោះ មានការលំបាកជាខ្លាំង ។ ឪពុករបស់គាត់ត្រូវបានខ្មែរក្រហមតម្រូវឲ្យធ្វើការដោយអូសនង្គ័លជំនួសគោក្របី ។ ថ្ងៃមួយក្រុមគ្រួសាររបស់ ផាន់ដារា ស ត្រូវបានខ្មែរក្រហមនាំទៅដល់បឹងកន្ទួត ដើម្បីសួរចម្លើយ ។ ពេលនោះ តាផន ដែលជាមេកងបានសួរម្តងហើយម្តងទៀតថា តើ ផាន់ដារា ស មានស្វាមីជាមន្ត្រីរាជការជាន់ខ្ពស់ជាឧត្តមសេនីយ៍ ឬជាគ្រូពេទ្យដែរឬទេ? ប៉ុន្តែ ផាន់ដារា ស បានលាក់ប្រវត្តិប្តីរបស់គាត់ដែលជាគ្រូពេទ្យដោយប្រាប់ថា ជាប្រជាជនសាមញ្ញ និងលក់គ្រឿងទេសបន្តិចបន្តួច ។

នៅចុងបញ្ចប់ ក្នុងនាមជាបញ្ញាជន និងជាអ្នកដែលកាន់ព្រះពុទ្ធសាសនាដូចគ្នា លោកស្រី ផាន់ដារា ស ស្នើឲ្យ ខៀវ សំផន លើកដៃសំពះ និងបួងសួងទៅដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមឲ្យទទួលបានទៅដល់សុខគតិភព ។ យល់ស្របតាមសំណើនេះ ខៀវ សំផន លើកដៃសំពះ និងថ្លែងថា «ខ្ញុំបានរួមចំណែក ដែលខ្ញុំមិនដឹងថា បងប្អូនសាច់ញាតិ លោកស្រីបានត្រូវជួបនឹងទុក្ខលំបាកវេទនា ហើយបងៗ ប្អូនៗជាច្រើនត្រូវជួបប្រទះ រួមទាំងបងប្អូនកសិករ មូលដ្ឋានផងដែរ ជួបប្រទះនឹងទុក្ខសោកវេទនាជាច្រើន ។ ខ្ញុំរន្ធត់ចិត្តណាស់ ហើយរួមព្រមជាមួយនេះ ខ្ញុំមិនភ្លេចដល់វិញ្ញាណក្ខន្ធរបស់យុទ្ធនារី ដែលលូនទៅរំដោះភ្នំពេញ ក្រោមគ្រាប់បែក បេ-៥២ ក្រាលព្រំ ។ អ្នកស្លាប់ក៏ស្លាប់ទៅ អ្នកនៅក៏ចេះតែខំរុលទៅឲ្យជិតកងទ័ព លន់ នល់ ដើម្បីកុំឲ្យគ្រាប់បែកយន្តហោះ បេ-៥២ វាទម្លាក់ត្រូវ ។ ទៅកៀកឲ្យជាប់ លន់ នល់ ។ ដូច្នេះបងប្អូនប្រយុទ្ធតស៊ូនេះ ក៏មានពលីជីវិតច្រើនណាស់ ។ ខ្ញុំសូមលើកដៃសំពះគោរពដោយសុភាពរាបសាដល់វិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារីទាំងអស់នេះ ក៏ដូចជា

*វិញ្ញាណក្ខន្ធបងប្អូនយើងទាំងអស់ ដែលត្រូវបានពលីជីវិតទៅក្នុងសភាពការណ៍ប្រទេសយើង ដែលវាត្រូវជួបប្រទះអស់ពីសង្គ្រាមអាមេរិក វាជាប់នឹងសង្គ្រាមវៀតណាម ។ និយាយរួមកម្ពុជាប្រជាធិបតេយ្យ គ្មានទាន់បានស្គាល់សន្តិភាពមួយរយៈពេលណាមួយទេ ។ អានេះខ្ញុំសូមគោរពដល់វិញ្ញាក្ខន្ធបងប្អូនទាំងអស់» ។*

សូមបញ្ជាក់ថា បន្ទាប់ពីលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ធុច ដាន់ដារា ស អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបផ្សេងទៀតនៅក្នុងថ្ងៃ (ជាមួយគ្នា) គឺ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ។ ដើមបណ្តឹងរដ្ឋប្បវេណីទាំងបីរូបនោះរូបមាន ទី១ លោកស្រី ចាន់ សុជាតិ ទី២ លោកស្រី ចេង អេងលី និងទី៣ លោកស្រី ហូ ចន្ធា ។

## ២២) ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ដើម្បីស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ ។

ដើមបណ្តឹងរដ្ឋប្បវេណា ចាន់ សុជាតិ អាយុ៥៦ឆ្នាំ មានស្រុកកំណើតកើតនៅទីក្រុងភ្នំពេញ ។ បច្ចុប្បន្នរស់នៅភូមិចំការចេក សង្កាត់ដុះព្រៃ ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ ចាន់ ស៊ីន ម្តាយឈ្មោះ អ៊ុយ យ៉ែម ស្វាមីឈ្មោះ ឌៀ យ៉ន និងមានកូនចំនួន៥នាក់ ។

ថ្លែងជូនអង្គជំនុំជម្រះទាំងក្តីទុក្ខហោយយ៉ាងខ្លាំង ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ បានរៀបរាប់ថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅវេលាម៉ោងប្រហែល៩ព្រឹក យោធាខ្មែរក្រហមបានស្ពាយកាំភ្លើងចូលដល់ក្នុងផ្ទះរបស់លោកស្រី ហើយស្រែកឲ្យចាកចេញពីផ្ទះទាំងអស់ ដើម្បីឲ្យអង្គការរៀបចំទីក្រុងភ្នំពេញឲ្យបានស្អាត៣ថ្ងៃក្រោយចាំត្រឡប់មកវិញ ។ ពេលនោះ លោកស្រីមានការភ័យខ្លាចជាខ្លាំង ហើយប្រញាប់ប្រញាល់នាំបងប្អូនទាំង១៣នាក់ និងឪពុកម្តាយចាកចេញពីផ្ទះ ដោយប្រមូលសម្ភារប្រើប្រាស់សម្រាប់ប្អូនតូចៗចំនួន ៤នាក់ ដែលកំពុងនៅបៅប៉ុណ្ណោះ ។

នៅតាមផ្លូវព្រះមុនីវង្ស ដើមបណ្តឹងរដ្ឋប្បវេណីឃើញប្រជាជនជាច្រើនធ្វើដំណើរយ៉ាងកកកុញ ដោយអ្នកខ្លះដេកនៅលើគ្រែរុញមានសេរ៉ូមជាប់ដៃ មានទាំងក្មេងទាំងចាស់ដើរប្រជៀតគ្នា ហើយខ្លះទៀតដេកស្លាប់នៅតាមដងផ្លូវ ។ លោកស្រីធ្វើដំណើរទៅដល់ស្រុកកៀនស្វាយ ហើយស្នាក់នៅ និងធ្វើការនៅទីនោះអស់រយៈពេល៦ខែ ។ នៅទីនោះពុំមានរបបអាហារគ្រប់គ្រាន់ឡើយ គឺទទួលបានតែរបបអង្ករ និងពោតបន្តិចបន្តួចប៉ុណ្ណោះ ចំណែកត្រីសាច់ផ្សេងៗពុំបានទទួលឡើយ ។ ប្អូនស្រីម្នាក់របស់លោកស្រី សុជាតិ បានស្លាប់បាត់បង់ជីវិតដោយសារដាច់ទឹកដោះ ។

បន្ទាប់មក ខ្មែរក្រហម បានជម្លៀសក្រុមគ្រួសាររបស់លោកស្រីទៅដល់ខេត្តពោធិ៍សាត់ ដោយខ្មែរក្រហមតម្រូវឲ្យធ្វើការជាទម្ងន់ ត្រូវកាប់ឆ្ការព្រៃឈើ និងជីកប្រឡាយ៥ម៉ែត្រគូបក្នុងមួយថ្ងៃ ដោយពុំមានរបបអាហារគ្រប់គ្រាន់ ។ ប្រជាជនដែលធ្វើការនៅជួរមុខទទួលបានបបរមួយវែក ដែលមានជាតិអង្ករខ្លះ ប៉ុន្តែអ្នកដែលធ្វើការមិនកើតដូចជា ឪពុកម្តាយ និងប្អូនៗរបស់លោកស្រី ទទួលបានបបរសុទ្ធតែកន្ទក់ និងខ្ទុត លាយជាមួយក្រកួន ។ ប្អូនៗ និងឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណីឈឺគ្រប់ៗគ្នា ហើយស្លាប់ជាបន្តបន្ទាប់ដោយសារអត់អាហារបរិភោគ ។ ក្រោយមកម្តាយរបស់លោកស្រីឈឺជាទម្ងន់ ហើយលោកស្រីស្នើសុំទៅមើលម្តាយមួយព្រឹក ប៉ុន្តែប្រធានកងពុំអនុញ្ញាត ដោយស្រែកទាំងគំហកថា *«មិត្តឯងពេទ្យ? មិត្តឯងទៅម៉ែមិត្តឯង ម៉ែមិត្តឯងជា?»* ។ ចាប់ពីនោះមកដើមបណ្តឹងរដ្ឋប្បវេណី លែងបានជួបមុខម្តាយរបស់គាត់ជារៀងរហូត ។ ចំណែកបងរបស់លោកស្រីក៏បានស្លាប់ជាបន្តបន្ទាប់ ។ ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ ដែលមានសមាជិកទាំងអស់១៥នាក់ នៅសល់តែរូបលោកស្រីម្នាក់តែប៉ុណ្ណោះ ។

ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ សុជាតិ បានបញ្ជាក់ថា លោកស្រីមានគោលបំណងស្វែងរកយុត្តិធម៌ជូនសមាជិកគ្រួសារទាំង១៤នាក់ និងប្រជាជនកម្ពុជាដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម និងសូមឲ្យជនជាប់ចោទដែលកំពុងត្រូវបានចោទប្រកាន់ សារភាពទោសកំហុស និងសូមទោសចំពោះប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិតនៅក្នុងរបបនោះ ។ នៅជិតចុងបញ្ចប់នៃការសវនាការ

អង្គជំនុំជម្រះបានផ្តល់ឱកាសជូនលោកស្រី ចាន់ សុជាតិ សួរសំណួរមួយចំនួនទៅជនជាប់ចោទ ខៀវ សំផន និង នួន ជា ។

ឆ្លើយតបនឹងសំនួររបស់លោកស្រី ចាន់ សុជាតិ ដែលសួរថា «ហេតុអ្វីបានជារបបខ្មែរក្រហម ប្រព្រឹត្តអំពើឃោរឃៅចំពោះប្រជាជនខ្លួនឯង ហើយធ្វើដើម្បីអ្វី?» ខៀវ សំផន បានថ្លែងនូវការសោកស្តាយ ដោយបញ្ចូលនូវការបដិសេធនូវតួនាទីជាថ្នាក់ដឹកនាំ ដែលមានអំណាចចេញគោលនយោបាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខៀវ សំផន បានលើកឡើងថា “សូមគោរពអង្គសវនាការទាំងមូល! សូមជំរាបលោកស្រី ចាន់ សុជាតិ ។ ខ្ញុំស្តាប់លោកស្រីមានប្រសាសន៍អំពីទុក្ខសោកវេទនាដែលលោកស្រីបានជួបប្រទះស្លាប់បាត់បង់ឪពុកម្តាយដែលជាទីស្រលាញ់ ។ ខ្ញុំរន្ធត់ចិត្តណាស់ ។ ខ្ញុំស្តាប់យ៉ាងនេះទៅនឹកថា អ្នកដែលធ្វើបាបលោកស្រី និងសាច់ញាតិលោកស្រីយ៉ាងនេះ មិនមែនជាមនុស្សធម្មតាទេ ជាស្តេចត្រាញ់ គេហៅថាស្តេចត្រាញ់សង្គ្រាមគ្មានធម៌មេត្តាដល់មនុស្ស មិនគិតដល់អាយុជីវិតមនុស្ស មិនគិតដល់អ្នកធ្លាប់ធ្វើ ឬមិនធ្លាប់ធ្វើ ។ ទុកពេលវេលាឲ្យម្នាក់ៗមានពេលវេលាសម្រាប់ខ្លួន ខំពីមិនធ្លាប់ទៅជាធ្លាប់ ។ ការពិតវាត្រូវធ្វើយ៉ាងនេះ? ? ។ ប៉ុន្តែបើយើងបន្ទំពេល ឈឺអីទៅបន្ទត់បាយថា ធ្វើពុតអាហ្នឹងមនុស្សអីចឹងជាមនុស្ស ហៅថាស្តេចត្រាញ់ឃោរឃៅ ។ មនុស្សដែលឃោរឃៅដល់កម្រិតហ្នឹង ខ្ញុំមិនរួមជាមួយទេ ។ ពិតមែនតែខ្ញុំមិនមែនជាអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យ សម្រេចអំពីនយោបាយដែលនាំឲ្យលោកស្រី សាច់ញាតិលោកស្រី ជួបប្រទះនឹងទុក្ខសោក វេទនាក៏ដោយ ក៏សូមលើកដៃអភ័យទោស សូមទោសលោកស្រី សូមទោសបងប្អូនរួមជាតិទាំងអស់ ។ ដូចខ្ញុំបានជម្រាបពីព្រឹកមិញ ដែលត្រូវបានរងគ្រោះដោយអំពើឃោរឃៅព្រៃផ្សៃនេះ ខ្ញុំយល់ឃើញថា មិនមែនជាមនុស្សធម្មតាទេ ជាស្តេចត្រាញ់សង្គ្រាម ជាសក្តិភូមិ ។ បាទ! សូមអស់!» ។

បន្ទាប់ពីជនជាប់ចោទ ខៀវ សំផន បញ្ចប់ការឆ្លើយតប ជនជាប់ចោទ នួន ជា បន្ថែមថា “...កម្ពុជាប្រជាធិបតេយ្យមិនមានមាគ៌ានយោបាយទៅសម្លាប់ប្រជាជនឯង ទៅបន្ទត់បាយ បន្ទត់ទឹកប្រជាជនឯងនោះទេ ។ ម្នាក់ៗសុខចិត្តលះបង់មកតស៊ូដើម្បីរំដោះជាតិ រំដោះប្រជាជនផុតពីចក្រពត្តិអាមេរិក ដល់ប្រទេសមួយទៀតគឺយួនឈ្លានពានកម្ពុជា ។ ដូច្នេះ កម្ពុជាប្រជាធិបតេយ្យត្រូវទទួល



នីរសារខ្មែរក្រហម (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

តស៊ូរំដោះជាតិចេញពីចក្រពត្តិឈ្លានពាន ហើយពីយួនដែលមានមហិច្ឆតាឈ្លានពាន វាទីលេបទឹកដីយើង ។ ដូច្នេះ ក្នុងឱកាសនេះ ខ្ញុំសូមគោរពម្តងទៀតនូវវិញ្ញាណក្ខន្ធរបស់អ្នកស្នេហាជាតិទាំងអស់ ជាពិសេសរបស់លោកស្រី សុជាតិ ។ ខ្ញុំបានបញ្ជាក់ពីលើកមុនម្តងហើយ ត្រង់នេះខ្ញុំសូមបញ្ជាក់ម្តងទៀតថា កម្ពុជាប្រជាធិបតេយ្យមានបំណងល្អចំពោះប្រជាជន ។ ដូចខ្ញុំម្នាក់ៗលះបង់តស៊ូ ដើម្បីជាតិ ដើម្បីប្រជាជនរបស់ខ្លួន...» ។

## ២៣) ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម ហើយបច្ចុប្បន្នកំពុងរស់នៅប្រទេសបារាំង ។

ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅទីក្រុងប៉ារីស ប្រទេសបារាំង ។ ឪពុកឈ្មោះ ឆេង សេងកែវ ម្តាយឈ្មោះ សុខ អេង ស្វាមីឈ្មោះ ឆាយ ហុកផេង និងមានកូនចំនួន ៥ នាក់ ។ លោកស្រី ឆេង អេងលី បានថ្លែងពីប្រទេសបារាំងតាមរយៈប្រព័ន្ធសោតទស្សន៍អំពីការរងទុក្ខវេទនាដែលបានជួបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅចំពោះអង្គជំនុំជម្រះ ។

លោកស្រី ឆេង អេងលី បានរៀបរាប់ថា ទោះបីព្រឹត្តការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានកន្លងផុតជាង៣០ឆ្នាំក៏ដោយក៏លោកស្រីមិនអាចបំភ្លេចបានឡើយ ព្រោះជាព្រឹត្តិការណ៍ដ៏សាហាវយង់ឃ្នងដែលលោកស្រីបានឃើញផ្ទាល់ភ្នែក ។ នៅពេលកំពុងធ្វើដំណើរចេញពីទីក្រុងភ្នំពេញ លោកស្រី បានឃើញយោធាខ្មែរក្រហមចាប់ហែកជើងទារកម្នាក់ដែលកំពុងយំ និងវាយលើទ្រូងម្តាយរកបោជាពីរ ។ លោកស្រីមានការតក់ស្លុតជាខ្លាំង ដោយពុំនឹកស្មានដល់ ។ នៅតាមផ្លូវជាតិលេខ១ លោកស្រីឃើញមនុស្សស្លាប់ជាច្រើន ហើយនៅតាមទន្លេមានសាកសពអណ្តែតជាបន្តបន្ទាប់ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហម ប្រជាជនរស់នៅដោយគ្មានសេរីភាព ត្រូវធ្វើការជាទម្ងន់ របបអាហារមិនគ្រប់គ្រាន់ ទទួលបានបបររាវៗបីវែកក្នុងមួយពេល ។ ពេលឈឺគ្មានថ្នាំព្យាបាល ហើយពេលឈឺខ្លាំងមានតែថ្នាំអាចម៍ទន្សាយតែប៉ុណ្ណោះ ។ ប្រជាជនម្នាក់ៗពុំហ៊ាននិយាយស្តី ។

លោកស្រី បានរំឭកដល់ស្ត្រីម្នាក់ឈ្មោះ មុយ ដែលរស់នៅជាមួយគ្នាត្រូវបានខ្មែរក្រហមសម្លាប់ ដោយសារស្ត្រីនោះនិយាយថា មិនដឹងប្អូនស្រីទាំងពីររបស់គាត់ទៅដល់ទីណា ។ ឆេង អេងលី បានរៀបរាប់ ព្រឹត្តិការណ៍នោះថា នៅពេលយប់មួយ ស្ត្រីឈ្មោះ មុយ នោះបាននិយាយអំពីការព្រួយបារម្ភអំពីសុខទុក្ខប្អូនស្រីទាំងពីររបស់គាត់ ស្រាប់តែភ្លឺឡើងស្រាងៗ យោធាខ្មែរក្រហមបាននាំស្ត្រីនោះចេញទៅ ហើយឲ្យជីករណ្តៅទំហំប៉ុនខ្លួនស្ត្រីនោះ និងមានជម្រៅប្រហែល ៥០សង់ទីម៉ែត្រ ។ នៅពេលស្ត្រីនោះកំពុងជីករណ្តៅទាំងអស់កម្លាំង ខ្មែរក្រហមសួរថា «ម៉េចហើយ?» នេះជាពាក្យដែល ឆេង អេងលី បានចាំយ៉ាងច្បាស់ ។ បន្ទាប់មកខ្មែរក្រហមរុញទម្លាក់ស្ត្រីនោះចូលក្នុងរណ្តៅហើយកប់ទាំងរស់ ព្រមទាំងពោលពាក្យថា «ហ្នឹងហើយជូនទៅជួបបងប្អូន» ។ លោកស្រីនៅតែចាំព្រឹត្តិការណ៍នោះនៅជាប់នឹងភ្នែក និងមានការតក់ស្លុតជាខ្លាំង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ព្រឹត្តិការណ៍ដែលលោកស្រីបានឃើញទាំងអស់ និងស្ថានភាពដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ធ្វើឲ្យលោកស្រីពុំអាចបំភ្លេចបាន និងនៅតែមានអារម្មណ៍ភ័យខ្លាច មានអារម្មណ៍ឆាប់ភ័យ នៅពេលមើលខ្សែភាពយន្តណាដែលមានភាពរន្ធត់ ។

ដើមបណ្តឹងរដ្ឋប្បវេណី ឆេង អេងលី ពុំបានទាមទារសំណងអ្វីឡើយ អ្វីដែលលោកស្រីចង់បាន គឺសុំឲ្យតុលាការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជាដែលបានស្លាប់ និងទទួលរងទុក្ខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

## ២៤) ដើមបណ្តឹងរដ្ឋប្បវេណី ហួ ចន្ថា

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ការថ្លែងទុក្ខសោក និងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហួ ចន្ថា ។

ដើមបណ្តឹងរដ្ឋប្បវេណី ហួ ចន្ថា មានអាយុ៦០ឆ្នាំ កើតនៅឃុំកំពង់សីធ្ន ស្រុកបាភ្នំ ខេត្តព្រៃវែង ។ បច្ចុប្បន្នរស់នៅភូមិពកឫស្សី ឃុំពកឫស្សី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។ ឪពុកឈ្មោះ ហួ ហាង ម្តាយឈ្មោះ កោក ងៅ ប្តីឈ្មោះ ឌួន សារឹម មានកូនចំនួន៥ នាក់ ។

នៅចំពោះមុខអង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណី ហួ ចន្ថា

បានរៀបរាប់អំពីដំណើរជីវិត ដែលលោកស្រីបានឆ្លងកាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងទុក្ខសោកនានាដែលលោកស្រីបានទទួលរង ហើយបន្សល់ទុកមកដល់សព្វថ្ងៃនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណី ហូ ចន្ទា បានរៀបរាប់ថា នៅក្នុងរបប លន់ នល់ ក្រុមគ្រួសាររបស់គាត់មានជីវភាពធូរធារបន្តួរ ហើយបងរបស់គាត់សុទ្ធតែជាមន្ត្រីរដ្ឋការរបស់របប លន់ នល់ ។ ចំណែកប្តីរបស់គាត់ ធ្វើជាគ្រូបង្រៀន ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ហូ ចន្ទា ឮស្នូរកាំភ្លើងនៅម្តុំពោធិ៍ចិនតុង និងនៅជុំវិញទីក្រុងភ្នំពេញ ហើយគិតថាជាថ្ងៃអវសាននៃរបប លន់ នល់ ។ លុះដល់ម៉ោង ប្រហែលជា៨ព្រឹក ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកស្រី ហូ ចន្ទា ឃើញប្រជាជនជាច្រើន រួមទាំងប្តីរបស់គាត់ឈរលើកទង់ជ័យស ហើយស្រែកអបអរសាទរ ដោយគិតថាសង្គ្រាមត្រូវបញ្ចប់ហើយសន្តិភាពនឹងកើតមាន ។ ទោះបីដូចនេះក្តី យោធាខ្មែរក្រហមដែលចូលមកទីក្រុងភ្នំពេញនោះពុំបានសម្តែងទឹកមុខទទួលយកការទទួលស្វាគមន៍របស់ប្រជាជនឡើយ ។ ប៉ុន្មានម៉ោងក្រោយមក យោធាខ្មែរក្រហមទាំងនោះស្រែកដោយបាញ់កាំភ្លើងឡើងទៅលើជាច្រើនគ្រាប់ឲ្យប្រជាជនចេញពីផ្ទះ ព្រោះអង្គការត្រូវរៀបចំទីក្រុងឲ្យបានស្អាត ។ ក្នុងអំឡុងពេលនោះ ហូ ចន្ទា ភ័យស្លន់ស្លោពុំដឹងយកអ្វីតាមខ្លួន ព្រោះសុទ្ធតែរបស់មានតម្លៃ ។

ហូ ចន្ទា ធ្វើដំណើរចេញពីទីក្រុងតាមផ្លូវពោធិ៍ចិនតុង ។ នៅតាមផ្លូវមានមនុស្សធ្វើដំណើរណែនណាន់តាន់តាប់ មានទាំងក្មេង ចាស់ អ្នកជំងឺ ។ កុមារយំទ្រហឹងរកឪពុកម្តាយ ។ ទាហាន លន់ នល់ ដេកស្លាប់នៅតាមផ្លូវ ដែលគួរឲ្យអាសូរបំផុត ។ ហូ ចន្ទា ធ្វើដំណើរអស់រយៈពេល១៥ថ្ងៃទើបទៅដល់ស្រុកពកឫស្សី ។ ប្រជាជនម្នាក់ៗមានការអស់សង្ឃឹមជាខ្លាំង ដោយសារនៅទីនោះពុំមានអ្វីទាំងអស់ មានតែព្រៃដុះទ្រុបទ្រុល ។ ទៅដល់ទីនោះបានមួយរយៈប្អូនថ្លៃរបស់ ហូ ចន្ទា ឈ្មោះ ស៊ិន ត្រូវគេហៅ ទៅប្រជុំរៀនសូត្រ ហើយបាត់ខ្លួនរហូត ។ លោកស្រីត្រូវបានប្រមាថថា “ជានារី១៧ មេសា ទន់ជ្រាយ គ្មានចិត្តតស៊ូ” ។ ប្រជាជនត្រូវតម្រូវឲ្យធ្វើការហួសកម្លាំងដោយទទួលបានរបបអាហារមិនគ្រប់គ្រាន់ ។

ម្តាយ និងប្អូនៗទាំង ៥នាក់របស់លោកស្រី ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ដោយចោទថា មានមាសច្រើន ហើយមិនយកដាក់សហករណ៍រួម ។ ចំណែកឪពុកត្រូវស្លាប់ដោយសារគ្មានថ្នាំព្យាបាល ។ បងប្រុសឈ្មោះ ហូ ហានី អតីតទាហានអាកាសចរណ៍នៅរបប លន់ នល់ ដែលរៀននៅប្រទេសថៃ បានត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយមានការអំពាវនាវរបស់ អៀង សារី ក្រោយមកត្រូវយោធាខ្មែរក្រហមចាប់យកសម្លាប់ចោល ។ ចំណែកបងស្រីទី២ ឈ្មោះ ហូ ឃឹម មានផ្ទៃពោះ៤ខែ និងកូន៣នាក់ រួមទាំងម្តាយក្មេកត្រូវបានដាក់ឲ្យឈរជាជួរ ហើយខ្មែរក្រហមវាយនឹងដងចបសម្លាប់ម្តងមួយៗគួរឲ្យតក់ស្លុតជាទីបំផុត ។ បន្ទាប់ពីបងថ្លៃឈ្មោះ នង គីមអេង ត្រឡប់មកពីធ្វើការវិញដឹងថាប្រពន្ធ កូន និងម្តាយ ត្រូវខ្មែរក្រហមសម្លាប់ ក៏ទាញកាំបិតដើម្បីទៅសម្លាប់ជនដៃដល់វិញ ។ ប៉ុន្តែជាអកុសល ដោយខ្មែរក្រហមមានគ្នាច្រើន គាត់ក៏ត្រូវខ្មែរក្រហមកាប់សម្លាប់ ដេកក្នុងថ្លុកឈាម ។ បងប្រុសទី៣ឈ្មោះ ហូ លឹម ត្រូវខ្មែរក្រហមចោទថាមានទ្រព្យសម្បត្តិមិនដាក់ចូលជាមួយគេ ។ ក្រោយមក ហូ លឹម ត្រូវខ្មែរក្រហមនាំខ្លួនទៅដោយប្រាប់ថា ទៅគាស់គល់ឈើ ។ នៅពេលឮដំណឹងនេះ ប្រពន្ធរបស់ គាត់ឈ្មោះ ស្រីមុំ និងកូន៤នាក់ បានទៅអង្វរសុំឲ្យដោះលែងប្តី ប៉ុន្តែត្រូវខ្មែរក្រហមសម្លាប់ទាំងគ្រួសារ ។

នៅចុងបញ្ចប់នៃសេចក្តីថ្លែងទុក្ខ ហូ ចន្ទា ស្នើសុំឲ្យតុលាការស្វែងរកយុត្តិធម៌ជូនសមាជិកក្រុមគ្រួសារ និងសាច់ញាតិរបស់លោកស្រីទាំង២២នាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ថែមលើនេះ លោកស្រីអំពាវនាវឲ្យសហគមន៍អន្តរជាតិផ្តល់ជំនួយដល់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលសុទ្ធសឹងតែមានវ័យចំណាស់ និងគ្មានទីពឹង ។

## ២៥) ដើមបណ្តឹងរដ្ឋប្បវេណី នួរ ហ៊ិន់

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី នួរ ហ៊ិន់ ។

ដើមបណ្តឹងរដ្ឋប្បវេណី នួរ ហ៊ិន់ មានអាយុ៧៩ឆ្នាំ មានទីកន្លែងកំណើតនៅភូមិផ្សារថ្កូវ ឃុំកំពង់សឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។ បច្ចុប្បន្នរស់នៅរដ្ឋតិចសាស់ សហរដ្ឋអាមេរិក ។ ដើមបណ្តឹងរដ្ឋប្បវេណី មានឪពុកឈ្មោះ នួរ ចាន់ និងម្តាយឈ្មោះ

អាន ភឿវ និងមានកូនចំនួន៨នាក់ ។

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ ជាជនរងគ្រោះមួយរូបក្នុងចំណោមជនរងគ្រោះជាច្រើនរូប ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ហ៊ិន់ បានរៀបរាប់អំពីព្រឹត្តិការណ៍នៅពេលនោះថា ការជម្លៀសប្រជាជនចេញពីភ្នំពេញ ជាទិដ្ឋភាពថ្មីមួយដែលប្រជាជនកម្ពុជាពុំធ្លាប់ជួបប្រទះ ។ នៅពេលនោះ មនុស្សច្រើនកុះករត្រូវធ្វើដំណើរចាកចេញនៅក្រោមកម្តៅ ថ្ងៃខែចែត្រ ដោយអ្នកខ្លះពុំមានស្បែកជើង និងអ្នកផ្សេងទៀតត្រូវបង្ខំចិត្តយកស្រទបចេក ឬក្រណាត់កន្ទបខោអាវមករុំជើងដើម្បីធ្វើដំណើរ ។ ក្នុងអំឡុងពេលនោះ មានអ្នកខ្លះបាត់កូន ខ្លះបាត់ប្តី ខ្លះបាត់ប្រពន្ធ ។

ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ ត្រូវបានជម្លៀសតាមផ្លូវជាតិលេខ១ ឆ្ពោះទៅទឹកដីខេត្តព្រៃវែង និងស្វាយរៀង ។ នៅអំឡុងពេលនៃការជម្លៀស ដើមបណ្តឹងរដ្ឋប្បវេណីបានបាត់កូនស្រីម្នាក់ ដែលមានអាយុពី៩ ទៅ១០ឆ្នាំ ។ នៅពេលជម្លៀស កូនស្រីរបស់លោករស់នៅជាមួយក្រុមគ្រួសាររបស់ប្អូនថ្លៃដែលត្រូវបានជម្លៀសទៅខេត្តកំពង់ស្ពឺ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ លោកបានទទួលដំណឹងថា កូនស្រីរបស់លោក និងក្រុមគ្រួសាររបស់ប្អូនថ្លៃត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារគ្រាន់តែប្រើពាក្យថា «កូនខ្ញុំអក្កាល់ជាទៅបើឲ្យថ្នាំអាចម៍ទន្សាយអ៊ីចឹង» ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសន្និតថា កូនស្រីរបស់លោកពិតជាត្រូវបានសម្លាប់ដោយខ្មែរក្រហម ព្រោះថាប្រសិនបើកូនស្រីរបស់គាត់នៅរស់ នាងនឹងវិលត្រឡប់មករកជីដូនជីតា និងឪពុកម្តាយវិញ ។ ដោយសារនៅពេលនោះនាងមានអាយុ១០ឆ្នាំ អាចស្គាល់ពីទីលំនៅបាន ។ រីឯក្រុមគ្រួសារប្អូនស្រីបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានកូនចំនួន៥នាក់ រស់នៅខេត្តស្វាយរៀង ត្រូវខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ ក្នុងឆ្នាំ១៩៧៨ បន្ទាប់មកអ្នកទាំងនោះបាត់ដំណឹងរហូតមកដល់ពេលបច្ចុប្បន្ន ។

ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ បង្ហាញអំពីអារម្មណ៍ទុក្ខសោក ការស្តាយស្រណោះ និងសោកសង្រេងជាខ្លាំង ដោយពុំមានវិធីណាអាចយកមកផ្សះផ្សាស្នាមរបួសផ្លូវចិត្ត ដែលបានបាត់បង់កូន ប្អូន ក្មួយ បានឡើយ ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នូវ ហ៊ិន់ នៅចំពោះមុខអង្គជំនុំជម្រះ ៖

“ខ្ញុំបាទផ្ទាល់ ជាគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំបាទ ខ្ញុំបាទគិតថាអង្គការកាលនោះជាអង្គការខ្មៅ លោកចង់ឲ្យប្រជាពលរដ្ឋកម្ពុជារស់រានមានជីវិតនៅក្នុងឥស្សរភាព នៅក្នុងបូរណភាពទឹកដី លោកគិតថា លោកចង់ឲ្យម្នាក់ៗមានមួកពាក់ ចង់ឲ្យម្នាក់ៗមានស្បែកជើងមួយគូពាក់ ប៉ុន្តែសម្ភារទាំងពីរនេះទំហំមានតែមួយទេ ហើយទំហំតូចយកទៅប្រគល់ឲ្យអ្នកដែលទទួលក្បាលធំ ជើងធំ ។ ដើម្បី



មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន ពៅ
(បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទទួលមួករបស់អង្គការឲ្យយកទៅពាក់លើក្បាលរបស់ខ្លួនបាន ទាល់តែខ្លួនចាំងក្បាលរបស់ខ្លួនសិន បានពាក់មួកនោះត្រូវ ព្រោះមួកវាតូច ។ ស្បែកជើងក៏ដូចគ្នាដែរ ស្បែកជើងតូច ជើងវាធំ ស៊ីកម៉េចនឹងត្រូវទាល់តែបង្ខំចិត្ត ចាំងជើងរបស់ខ្លួន ដើម្បីទទួលយកស្បែកជើងមួយគូនោះ ។ អ៊ីចឹងទេ ខ្ញុំគិតថានោះជាគំនិតតែមួយគត់ គឺអំណាចផ្តាច់ការអ្នកណាទាំងអស់ត្រូវតែធ្វើតាមទាំងអស់ ។ ពិបាកវេទនាប៉ុនណា ព្រាត់ប្រាស់កូន ប្រពន្ធប៉ុនណា ទុក្ខសោកប៉ុនណា សុខចិត្តទៅទ្រាំអត់ទប់ទឹកភ្នែកកុំឲ្យហូរ ។ ឃ្លាន

ណាស់ក៏មិនហ៊ានថា ក្តៅណាស់ត្រជាក់ណាស់ក៏មិនហ៊ានថា ។ ដូច្នេះ ទាំងអស់គ្នាស្ងោកៗទាំងអស់រាបដូចកន្ទេល ។ នេះជាគំនិត ខ្ញុំបាទ សង្កេតឃើញ ហើយធ្វើការកត់សម្គាល់យ៉ាងដូច្នេះ ។ ហើយមួយទៀត ខ្ញុំគិតថា ទិសស្ងោកដែលអង្គការបានលើកឡើងកាលនោះ ខ្ពស់ហួសហេតុពេក ។ អង្គការមហាអស្ចារ្យ! បងប្អូនទាំងអស់ដែលមកធ្វើសក្ខីកម្មនៅទីនេះ ឃើញតែការបំផ្លិចបំផ្លាញ ស្លាប់ជីវិត បាត់បង់គ្រួសារ អស្ចារ្យៗក្នុងការពិឃាត ក្នុងការកម្ទេច ។ នេះជាគំនិតរបស់ខ្ញុំយល់ ហើយលោតផ្លោះហ្នឹងមិនដឹងលោតផ្លោះយ៉ាងម៉េច ហើយអង្គការភ្នែកម្នាស់យ៉ាងម៉េច បើអស់លោកជាពិសេសមេដឹកនាំខ្មែរក្រហមទាំងពីររូប លោកបានមានប្រសាសន៍



មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច សុវណ្ណារី
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អម្បាញ់រួចហើយ លោកបានសារភាពថា លោកមិនបានទទួលដឹងព្ធអំពីភារកិច្ចខ្លះទៀត ដែលមិនមែនជាភារកិច្ចរបស់អស់លោក ខ្ញុំបាទជឿជាក់ថាអ៊ីចឹងមែនចុះ ។ ប៉ុន្តែគួរកត់សម្គាល់ថា ជារឿងមួយដែលយើងគិតថា យើងធ្វើឲ្យស្រុករីកចម្រើន ប៉ុន្តែផ្ទុយទៅវិញស្រុកយើងត្រូវបានលិចលង់ តើវាលិចលង់ដោយសារអ្វី? វាមានរឿងដែលធ្វើស្រុកលិចលង់នោះ? តើវាបណ្តាលមកពីអ្វី?

បើសិនជា អង្គការសហប្រជាជាតិ ឬមួយប្រទេសផ្តល់អំណោយផ្សេងៗថានឹងផ្តល់អំណោយយ៉ាងណាដល់ជនរងគ្រោះ ខ្ញុំគិតថា ទំហំបរិមាណមនុស្សដែលទទួល ដែលក្នុងនាមជាជនរងគ្រោះច្រើនណាស់ រាប់លាននាក់ ។ ដូច្នេះបរិមាណថវិកាហ្នឹងខ្ពស់ណាស់ ខ្ញុំបាទមិនសង្ឃឹមថា ចង់បានជាថវិកាសម្រាប់អ្វី សម្រាប់ផ្ទាល់ខ្លួន ដើម្បីជួសជុលផ្លូវចិត្ត ដែលបានរំជួលដោយការបាត់បង់កូន បាត់បង់ប្អូន ដោយសារការបាត់បង់ក្រុមគ្រួសារប្អូនថ្ងៃនេះទេ ។ ប៉ុន្តែសង្ឃឹមថាថ្ងៃណាមួយ ដែលមានឱកាសមកថ្លែងទីនេះ នៅអង្គសវនាការទីនេះ ជម្រាបអង្គតុលាការ ហើយដែលទាំងអស់គ្នារង់ចាំតែយុត្តិធម៌នេះយូរមកហើយ ។ សង្ឃឹមថាយុត្តិធម៌នេះបានផ្តល់ទៅដល់ជនរងគ្រោះទាំងវិញ្ញាណក្ខន្ធ អ្នកស្លាប់បាត់បង់ទៅទាំងវិញ្ញាណក្ខន្ធសាច់ញាតិដែលនៅរស់ទាំងអស់គ្នា ក៏ជាយុត្តិធម៌មួយសម្រាប់អង្គតុលាការដែរ ក៏ជាយុត្តិធម៌មួយសម្រាប់ខាងចុងចោទផងដែរ ។ ជាពិសេសថ្ងៃនេះ និងថ្ងៃខាងមុខទៀត ដែលជាទីបញ្ចប់របស់តុលាការ ។»

សូមបញ្ជាក់ថា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការ ស្តាប់ការថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤រូប ។ ទី១ គឺលោក នូវ ហ៊ាន់ ទី២ លោកស្រី សូផាន់ សូវណ្ណី ទី៣ លោក យិន រំដួល និងទី៤ គឺលោកស្រី ប៉ូ ឌីណា ។

### ២៦) ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី ដើម្បីស្តាប់នូវសេចក្តីថ្លែងទុក្ខសោក និងការទទួលរងព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី មានអាយុ៥៧ឆ្នាំ មានទីកន្លែងកំណើតនៅសង្កាត់លេខ១ ក្រុងភ្នំពេញ ។ សព្វថ្ងៃមានមុខរបរជាកសិករ ។ បច្ចុប្បន្នរស់នៅភូមិបន្ទាយដីក្រោយ ឃុំបន្ទាយដី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ ។ ឪពុកឈ្មោះ សូផាន់ សូផៃ និងម្តាយឈ្មោះ លឹម គីមសាយ និងស្វាមី ឈ្មោះ ង៉ែត វណ្ណដេត មានកូន៣នាក់ ។

នៅពេលដែលខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី សូវណ្ណី ត្រូវយោធាខ្មែរក្រហមប្រាប់ឲ្យចាកចេញពីផ្ទះដោយពុំចាំបាច់រៀបចំឥវ៉ាន់ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់ថា ទិដ្ឋភាពនៅពេលនោះមានសភាពរញ៉េរញ៉ៃ មនុស្សច្រើនកកកុញណែនណាន់តាន់តាប់ និងក៏មានដែរអ្នករងរបួស ។ អ្នកដែលចាកចេញ ត្រូវបានបង្ខំឲ្យដើរទៅមុខមិនឲ្យត្រឡប់ក្រោយជាដាច់ខាត ។ ទិដ្ឋភាពនៅសងខាងផ្លូវមានសភាពស្មោកគ្រោកជាខ្លាំង មានទាំងលាមក និងសាកសពដែលប្រទះឃើញស្លាប់នៅតាមដងផ្លូវ ។ ក្រុមគ្រួសាររបស់លោកស្រីមានបំណងធ្វើដំណើរទៅខេត្តកំពង់ធំ ប៉ុន្តែឈ្លបខ្មែរក្រហមទាំងនោះពុំអនុញ្ញាតឲ្យក្រុមគ្រួសាររបស់លោកស្រីធ្វើដំណើរបន្តទៅមុខទៀតឡើយ ។ បន្ទាប់មកក្រុមគ្រួសាររបស់លោកស្រីត្រូវអង្គការដាក់ទិសដៅឲ្យទៅធ្វើស្រែនៅខេត្តពោធិ៍សាត់ និងបាត់ដំបង ។

នៅពេលទៅដល់ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ អ្នកគ្រប់គ្រងសហករណ៍នៅទីនោះបានតម្រូវឲ្យគ្រួសារលោកស្រីកាប់ព្រៃធ្វើទីលំនៅដោយខ្លួនឯង និងទទួលបានរបបអង្ករ១កំប៉ុងសម្រាប់គ្នា៥នាក់ ។ នៅទីនោះហើយ ដែលឪពុក និងបងប្អូនលោកស្រីចំនួន៤នាក់ផ្សេងទៀតបានស្លាប់បាត់បង់ជីវិត ដោយសារជំងឺ និងការអត់ឃ្លាន ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូផាន់ សូវណ្ណី នៅចំពោះមុខអង្គជំនុំជម្រះ ៖

*«ឆាកជីវិតខ្ញុំសែនកំសត់មែនទែន ព្រោះអត់ឪពុកហើយអត់បងប្អូនទៀត ខ្ញុំនៅជាមួយម្តាយនៅផ្ទះបាយ ខ្ញុំនៅសមរភូមិ ខ្ញុំទទួលដំណឹងថា ម្តាយខ្ញុំឈឺធ្ងន់ទៀត ហើយខ្ញុំរត់ពីសមរភូមិ ខ្ញុំលួចរត់ សុទ្ធតែលួចរត់ លួចរត់ពេលយប់ ។ ខ្ញុំលែងខ្លាចស្លាប់ហើយ ខ្ញុំរត់មកមើលម្តាយខ្ញុំ ។ ខ្ញុំឮគេប្រាប់ថា ម្តាយខ្ញុំហ្នឹងគេឲ្យថ្នាំពេទ្យ ពេទ្យហ្នឹងគេឲ្យត្រកួនទែក ។ ហ៊ឺះ! ដាំត្រកួនទែក ឲ្យម្តាយខ្ញុំហូប ម្តាយខ្ញុំហូប ត្រកួនទែកហ្នឹងហើយ រាកដេកផ្ទាល់នឹងកន្ទេលហ្នឹង ខ្ញុំមិនដឹងថា គេហេតុអី គេឲ្យដាំត្រកួនទែកឲ្យម្តាយ ខ្ញុំហូបទេចាស៎ ។ គាត់រាកដល់ស្លាប់ ។ ខ្ញុំអស់ឪពុកម្តាយ ខ្ញុំអស់បងប្អូន អស់ទីពឹង អស់ស្អីៗរលីងពីក្នុងខ្លួន ។ ខ្ញុំគ្មានស្អីទៀតទេ ទុក្ខវេទនារបស់ខ្ញុំ ខ្ញុំមិនអាចរៀបរាប់ប្រាប់អស់លោកថា ពេលហ្នឹងខ្ញុំលំបាក ប៉ុនណា ។ ខ្ញុំវេទនាប៉ុនណា ខ្ញុំអត់អាចនិយាយបាន» ។*

## ២៧) ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល

នៅក្នុងសវនាការដែលបានប្រព្រឹត្តធ្វើឡើងនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះ បានបន្តស្តាប់នូវសេចក្តីថ្លែងទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល ។

ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល មានអាយុ៤៨ឆ្នាំ មុខរបរជាមន្ត្រីរាជការ មានទីកន្លែងកំណើតនៅសង្កាត់លេខ៥ ក្រុងភ្នំពេញ ។ បច្ចុប្បន្នរស់នៅភូមិសាលាកន្សែង សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប ។ ឪពុកឈ្មោះ យិន ស៊ីផារ៉េត, ម្តាយឈ្មោះ គឹម ឈន និងមានកូន២នាក់ ។

នៅមុនពេលចាប់ផ្តើមរៀបរាប់អំពីព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានបញ្ជាក់ជូនអង្គសវនាការថា នៅពេលនោះគាត់នៅជាកុមារ ដែលទើបតែមានអាយុ១០ឆ្នាំ កំពុងស្ថិតក្រោមការបីបាច់ថែរក្សា ពីសំណាក់ឪពុកម្តាយ និងកំពុងស្ថិតក្នុងការសិក្សា ។ ប៉ុន្តែព្រឹត្តិការណ៍នៃការចូលមកដល់នៃយោធាខ្មែរក្រហម និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បានបំផ្លាញសុភមង្គលក្នុងក្រុមគ្រួសាររបស់លោក ដោយលោកត្រូវបាត់បងឪពុក និងម្តាយ ហើយត្រូវរស់នៅជាក្មេងកំព្រា ក្រោយពេលរបបខ្មែរក្រហមដួលរលំ ។ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានរំឭកអំពីការស្លាប់បាត់បង់ជីវិតរបស់ម្តាយរបស់លោក ដោយពិពណ៌នាថា ក្រោយពីបានពិភាក្សាជាមួយម្តាយរកមធ្យោបាយដើម្បីរត់គេចចេញពីគុក ។ ពេលនោះម្តាយរបស់លោកបានផ្តល់យោបល់ឲ្យរត់គេចខ្លួន ដោយនិយាយថា *«បើសិនជាកូនទៅ កូនអាច មានសំណាងនឹងរស់»* ។ ពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានសម្រេចចិត្តលួចរត់នៅពេលយប់ ប៉ុន្តែ នៅប៉ុន្មានថ្ងៃក្រោយមក លោកបានទទួលដំណឹងថា ម្តាយរបស់លោកត្រូវបានខ្មែរក្រហមយកទៅសម្លាប់ នៅយប់ថ្ងៃដែលលោកលួចរត់ចេញពីគុក ។ ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល បានបង្ហាញ

ពីអារម្មណ៍ ឈឺចាប់របស់ខ្លួនថា "ក្នុងឋានៈជាកូនម្នាក់.....ពេលនោះហើយ ដែលខ្ញុំទទួលនូវសោកនាដកម្មយ៉ាង កំសត់ក្នុងឋានៈជាកូនខ្មែរម្នាក់ ហើយជាកុមាររងគ្រោះ ដែលដឹកនាំដោយលោក ខៀវ សំផន, អៀង សារី, ប៉ុល ពត និង នួន ជា នេះ ។ ខ្ញុំចុកចាប់ណាស់!" ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីសេចក្តីឈឺចាប់ និងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី យិន រំដួល នៅចំពោះមុខអង្គជំនុំជម្រះ៖

"អង្គសវនាការទាំងមូលជាទីគោរព! អ្វីៗដែលខ្ញុំបានស្តែងឡើងនៅថ្ងៃនេះ ខ្ញុំសូមជម្រាប ទៅអង្គសវនាការ និងជនរួមជាតិ និងប្រជាជននៅលើពិភពលោកឲ្យបានជ្រាបថា សោកនាដកម្មនៅក្នុងរបប ប៉ុល ពត គឺឃោរឃៅព្រៃផ្សៃជាងសត្វតិរច្ឆានទៅទៀត ។ ខ្ញុំចុកចាប់ណាស់ ខ្ញុំបាត់បង់ឪពុក បាត់បង់ម្តាយ បាត់បង់ឪពុកមាជាទីស្រឡាញ់របស់ខ្ញុំ ។ ខ្ញុំចង់ឲ្យគាត់សងមកវិញនូវអ្វីដែលគាត់ជំពាក់ខ្ញុំ ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ ។ គាត់ត្រូវតែហ៊ានទទួលខុសត្រូវចំពោះទង្វើដ៏លាមករបស់គាត់ ។ គាត់ត្រូវតែបើកកកាយនូវទំព័រប្រវត្តិសាស្ត្រសម្រាប់ប្រជាជាតិកម្ពុជា និងប្រជាជនពិភពលោកឲ្យគេដឹងថា អំពីអាក្រក់របស់គាត់ដែលបង្កឡើងដោយរបបខ្មែរក្រហមនេះវាឃោរឃៅប៉ុនណា ក្នុងឋានៈជាមេដឹកនាំរដ្ឋមួយ ។

អ្វីៗទាំងអស់មកទល់ថ្ងៃនេះ ខ្ញុំរង់ចាំ៣៨ឆ្នាំហើយ ពីកុមារភាព ខ្ញុំបានចងចាំទុកក្នុងខួរក្បាលខ្ញុំថា ខ្ញុំនឹងបើកកកាយនូវអំពើអាក្រក់របស់គាត់ បើសិនជាខ្ញុំមានឱកាស ។ បើសិនជា ខ្ញុំមានឱកាស ខ្ញុំនឹងបើកកកាយនូវទង្វើដ៏លាមក និងអាក្រក់របស់គាត់ឲ្យប្រជាជាតិនៅលើពិភពលោក និងប្រជាជនខ្មែរដែលរងគ្រោះដោយការកាប់សម្លាប់របស់គាត់បានជ្រាប បានដឹងនូវអ្វីដែលគាត់បានបង្កឡើង ។

សោកនាដកម្មដ៏ចុកចាប់នេះ គាត់មកធ្វើចំពោះខ្ញុំជាកូនក្មេងបំបែកបំបាក់ខ្ញុំ ពីឪពុក ម្តាយខ្ញុំ មិនឲ្យខ្ញុំរៀនសូត្រ មិនឲ្យខ្ញុំសិក្សា តើសីលធម៌ជាមេដឹកនាំនៅត្រង់ណា? លោក ខៀវ សំផន ពិចារណាទៅ! លោក នួន ជា ពិចារណាទៅ! ក្នុងឋានៈជាបញ្ញាជនជាន់ខ្ពស់ម្នាក់ លោកពិចារណាទៅ! លោកត្រូវតែហ៊ានបកស្រាយការពិតចំពោះមុខជាតិ និងប្រជាជាតិទាំងមូល លោកមិនត្រូវសោកស្តាយ ឬមានវិប្បដិសារីក្នុងការបកស្រាយទេ ។ ខ្ញុំចុកចាប់ណាស់ ។ ថ្ងៃនេះខ្ញុំសូមទោស អង្គសវនាការទាំងមូល ។ ខ្ញុំសូមបញ្ចេញនូវទស្សនៈនូវភាពចុកចាប់របស់ខ្ញុំ ចិញ្ចើមរបស់ខ្ញុំស្នាមរហូតដល់កូនរបស់ខ្ញុំ និងចៅរបស់ខ្ញុំតាមរយៈការវាយនឹងដំបងរបស់លោក ក្រុមរបស់លោកបក្ខពួករបស់លោក ក្នុងឋានៈលោកជាមេដឹកនាំ ។ លោកអត់បានស្រឡាញ់ជាតិរបស់ខ្លួនទេ លោកបំផ្លាញជាតិរបស់ខ្លួន លោកធ្វើឲ្យជាតិរបស់ខ្លួនរងគ្រោះវេទនា អាប់ឱនកិត្តិយសនៅក្នុងពិភពលោកនេះ ។ គេគ្រាន់តែនិយាយថាខ្មែរគេខ្លាចតាមរយៈបញ្ញាជនដ៏ពុំគួរឲ្យគោរពសរសើរនេះ ។ លោកពិចារណាចុះ!"

## ២៨) ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ អង្គជំនុំជម្រះ បានបន្តស្តាប់នូវសេចក្តីថ្លែងទុក្ខសោកវេទនា និងស្ថានភាពព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា ។

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា អាយុ៦០ឆ្នាំ មុខរបរបោកអ៊ុតសំលៀកបំពាក់ មានទីកន្លែងកំណើតនៅឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ។ បច្ចុប្បន្នរស់នៅភូមិកាប់ទូក សង្កាត់កណ្តាលដុំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ ។ ឪពុកឈ្មោះ កុយ ប៉ូ និងម្តាយឈ្មោះ ប្រែង រ៉េន និងស្វាមីឈ្មោះ សៅ សារិន មានកូន១នាក់ ។

ដើមបណ្តឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានរៀបរាប់ថា ក្រោយពេលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញនៅព្រឹកថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានចូលក្នុងផ្ទះដែលលោកស្រីបានស្នាក់អាស្រ័យជាមួយ ។ បន្ទាប់មកយោធាខ្មែរក្រហមទាំងនោះបានស្រែកសួររកម្ចាស់ផ្ទះ ប៉ុន្តែ លោកស្រីបានឆ្លើយប្រាប់យោធាខ្មែរក្រហមវិញថា ខ្លួនពុំមែនជាផ្ទះទេ គឺគ្រាន់តែជាអ្នកយាមផ្ទះឲ្យគេតែប៉ុណ្ណោះ ។ យោធាខ្មែរក្រហមពុំជឿការបញ្ជាក់នេះទេ និងបានចូលលុកលុយបោកប្រាស់សម្ភារធ្វើការ និងទ្រព្យសម្បត្តិនៅគេហដ្ឋាននោះចោលតែម្តង ។ បន្តិចក្រោយមកយោធាខ្មែរក្រហមបានឃើញ ស្វាមីរបស់លោកស្រីដែលស្ថិតនៅក្នុងផ្ទះជាមួយគ្នា និងបានវាយធ្វើបាបយ៉ាងឃោរ

យោដោយសារពុំជឿថាលោកស្រី និងប្ដីជាអ្នកយាមផ្ទះ ។ ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានពិពណ៌នាថា នៅតាមផ្លូវដំណើរអំឡុងពេលនៃការជម្លៀស លោកស្រីបានឃើញដោយផ្ទាល់ភ្នែកនូវទិដ្ឋភាពនៃការចាប់ចងទាហាន លន់ នល់ ទាំងរ៉ែងៗ ដោយយោធាខ្មែរក្រហមបណ្ដើរតាមផ្លូវ ប៉ុន្ដែពុំដឹងថាអ្នកទាំងនោះត្រូវនាំយកទៅទីណា ។

ក្រោយមក ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា និងគ្រួសារត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តពោធិ៍សាត់ ។ នៅទីនោះ ដើមហើយបានស្លាប់បាត់បង់ជីវិតដោយការអត់ឃ្លាន ។ បន្ទាប់ពីបាត់បង់កូន ម្ដាយរបស់លោកស្រីបានស្លាប់ដោយសារជំងឺ ។ ក្រោយពីម្ដាយ ស្វាមី និងកូនបានស្លាប់បាត់បង់ជីវិត ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា ត្រូវបានខ្មែរក្រហមបង្ខំឲ្យយកគ្រួសារថ្មី ប៉ុន្ដែលោកស្រីបានបដិសេធ ។ ការបដិសេធនេះបានធ្វើឲ្យខ្លួនត្រូវទទួលរងការធ្វើទារុណកម្ម និងត្រូវដាក់គុក

នៅក្នុងគុក ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានបញ្ជាក់ថាខ្លួនបានឃើញហេតុការណ៍ប្លែកៗជាច្រើន ដូចជាការធ្វើទារុណកម្ម



គម្រោងលើកទំនប់-ថតនៅពេលដែលកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមធ្វើដំណើរទស្សនកិច្ចទៅកាន់តំបន់នេះ
([illegible] មជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ដឹងរដ្ឋប្បវេណីបានអះអាងថា ពុំមានស្បៀងអាហារហូបចុកគ្រប់គ្រាន់ និងគ្មានទីជម្រកស្នាក់នៅច្បាស់លាស់ ។ មួយរយៈក្រោយមកប្ដីរបស់លោកស្រីត្រូវខ្មែរក្រហម ហៅទៅរៀនសូត្រ ដោយខ្មែរក្រហមសង្ស័យថា ប្ដីលោកស្រីជាអតីតទាហានស័ក្ដិ ៥ក្នុងរដ្ឋការនៃរបប លន់ នល់ ។ ចាប់តាំងពីពេលនោះមកប្ដីលោកស្រីពុំដែលត្រឡប់មកវិញឡើយ ។ ចំណែកឯលោកស្រីជាប្រពន្ធត្រូវខ្មែរក្រហមតាមដាន និងបង្ខំឲ្យធ្វើការគ្មានពេលសម្រាក ។

បន្ទាប់ពីប្ដីបាត់ខ្លួន កូនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ូ ឌីណា បានធ្លាក់ខ្លួនឈឺដោយសារអត់ចំណីអាហារហូបចុកគ្រប់គ្រាន់លើរូបអ្នកទោស ការដាក់ខ្នោះដែកជាប់នឹងជើងជាដើម ។

នៅមុនពេលបញ្ចប់ លោកស្រី ប៉ូ ឌីណា បានរៀបរាប់អំពីទុក្ខសោករបស់ខ្លួនថា ៖

*«ពេលនោះនាងខ្ញុំបាត់បង់អ្វីៗទាំងអស់ បាត់បង់បងប្អូន ម៉ែឪ ស្វាមី ព្រមទាំងកូនអស់ហើយ ។ ឥឡូវហ្នឹង ទឹកចិត្តរបស់ខ្ញុំមានការតក់ស្លុត មានការឈឺចាប់ អារម្មណ៍របស់នាងខ្ញុំនេះ វាដូចចង្កួត ដូចវិកលចរិតហើយ ។ ភ្លេចមុខ ភ្លេចក្រោយ គ្មានគិតអ្វីដឹងទាំងអស់ ដោយសារអាឡោះអាល័យ ក្រុមគ្រួសារដែលបានបាត់បង់ជីវិត»* ។

### ២៩) ដើមបណ្ដឹងរដ្ឋប្បវេណី បេ សុផានី

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សេចក្តីថ្លែងទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី ដែលបានបាត់បង់កូនៗ ដោយសាររបបខ្មែរក្រហម ។

ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី មានអាយុ៦៧ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង ។ សព្វថ្ងៃរស់នៅរដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ អ៊ុយ ងឹម ម្តាយឈ្មោះ សៀង សៀន ប្តីឈ្មោះ បេ សារិត និងមានកូនបីនាក់ ប្រុសម្នាក់ និងស្រីពីរនាក់ ។

នៅមុនថ្ងៃទី១៧ ខែមេសា ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី មានមុខរបរជាគ្រូបង្រៀន (ចំណែកប្តីរបស់លោកស្រីជាជំនួយការរបស់ភរិយា លោក សេនាប្រមុខ លន់ នល់ ។ នៅឆ្នាំ១៩៧៤ ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានរដ្ឋាភិបាល លន់ នល់ បញ្ជូនទៅបន្តការសិក្សាជាទាហានជាន់ខ្ពស់ នៅសហរដ្ឋអាមេរិច ចំណែកលោកស្រីបានរស់នៅជាមួយកូនទាំងបីនាក់នៅទីក្រុងភ្នំពេញ ។

នៅថ្ងៃទី១៧ ខែមេសា កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ដោយមានកាំភ្លើងគ្រប់ដៃ និងមានទឹកមុខមាំ ។ យោធាទាំងនោះបានបាញ់កាំភ្លើងឡើងលើដើម្បីបណ្តេញប្រជាជនឲ្យចេញពីទីក្រុង ព្រមទាំងប្រាប់ថា សហរដ្ឋអាមេរិចនឹងទម្លាក់គ្រាប់បែក ។ ដើមបណ្តឹងរដ្ឋប្បវេណីបានប្រញាប់ប្រញាល់នាំកូនទាំងបីនាក់ចាកចេញពីផ្ទះ ព្រោះខ្លាចខ្មែរក្រហមចូលមកដល់ផ្ទះ ដោយសារមានឯកសណ្ឋានទាហាន និងមានរូបថតជាច្រើនដែលថតជុំគ្នាជាមួយ លន់ នល់ ។

ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី បានរៀបរាប់ថា ក្នុងពេលធ្វើដំណើរនៅតាមផ្លូវ មានការលំបាកជាខ្លាំង ដោយសារមានមនុស្សច្រើនកកកុញ ហើយត្រូវដើរជាមួយកូនតូចៗទាំងថ្ងៃក្តៅ និងឃើញមានសាកសពទាហាន លន់ នល់ និងប្រជាជនទាំងចាស់ទាំងក្មេង ជនពិការ និងស្ត្រីមានផ្ទៃពោះ បានស្លាប់ជាច្រើននាក់នៅតាមដងផ្លូវ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ដោយសារគ្មានជម្រកស្នាក់ អាស្រ័យ លោកស្រី និងកូនតូចៗបានទៅរកស្លឹកត្នោតមកបាំងដើម្បីស្នាក់នៅ ។ នៅពេលនោះ ទារកតូចរបស់លោកស្រីមានជំងឺគ្រុនក្តៅកាន់តែខ្លាំង ដោយត្រូវបង្ខំចិត្តយកចិញ្ចៀនមួយវង់ដែលភរិយារបស់សេនាប្រមុខ លន់ នល់ ចងដៃក្នុងថ្ងៃរៀបអាពាហ៍ពិពាហ៍ ទៅដូរនឹងអង្ករពីប្រជាជនមូលដ្ឋានបានចំនួន២៥កំប៉ុង ដើម្បីយកអង្ករខ្លះទៅដូរនឹងថ្នាំអាស្ពីរីនឲ្យកូនលេប ។ ប៉ុន្តែថ្នាំនោះមិនអាចជួយកូនគាត់បានទេ ។ បន្ទាប់មកសុផានី បាននាំកូនទាំងបីនាក់ទៅរកពេទ្យ ហើយបានជួបនឹងអ្នកភូមិម្នាក់ ដែលប្រាប់ឲ្យគាត់ទៅរកពេទ្យយោធាខ្មែរក្រហម ។ ក្រោយពេលធ្វើដំណើរប្រហែលជា៤ ទៅ៥គីឡូម៉ែត្រ ដើមបណ្តឹងរដ្ឋប្បវេណីបានទៅដល់មន្ទីរពេទ្យខ្មែរក្រហម ហើយជួបនឹងពេទ្យបុរសម្នាក់ និងបានសំពះសុំឲ្យបុរសនោះជួយ ។ បន្ទាប់មកលោកស្រីបានយកកូនតូចទៅដាក់លើគ្រែ ហើយបុរសនោះ បានយកថ្នាំម្យ៉ាងមកចាក់នៅលើក្បាលរបស់កូនតូចរបស់លោកស្រី ។ គ្រាន់តែដកម្ជុលចេញភ្លាមកូនតូចនោះក៏ប្រកាច់ស្លាប់ភ្លាមតែម្តង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា លោកស្រីបានស្រែកយំខ្លាំងៗ ស្ទើរតែក្លាយទៅជាមនុស្សឆ្កួត ដោយសារបាត់បង់កូនៗ ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីសេចក្តីឈឺចាប់ និងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី នៅចំពោះមុខអង្គជំនុំជម្រះ ៖

*“ចាស! សូមជម្រាបលោកប្រធាន និងជម្រាបអង្គប្រជុំ ។ ពេលដែលខ្ញុំជួបជាមួយប្តីខ្ញុំ ហើយនៅឆ្នាំ១៩៨៣ ក្នុងសភាពប្តីខ្ញុំជាជនពិការ ។ ដោយសារការទុក្ខព្រួយ ទុក្ខសោកពីរបប ប៉ុល ពត នេះហើយ ដែលធ្វើឲ្យខ្ញុំមានវិបត្តិផ្លូវចិត្តមានជំងឺនៅក្នុងខ្លួន ។ ឧទាហរណ៍ ដូចជា ឈឺក្បាល វិលមុខ យល់សប្តិអាក្រក់ មិនដែលយល់សប្តិល្អទេ ។ ជួនកាលខ្ញុំដេកមើមមាយស្រែកនៅពេលយប់ ។ ខ្ញុំភ័យ ខ្ញុំមានការតក់ស្លុតដោយសារការដែលខ្ញុំទទួលទុក្ខសោកពីរបបខ្មែរក្រហមនេះហើយ រហូតមកដល់សព្វថ្ងៃនេះក៏ខ្ញុំនៅតែមានជំងឺមើមមាយដេកយល់សប្តិអាក្រក់ពីសង្គម ប៉ុល ពត ឃើញតែពួកយោធា ខ្មែរក្រហម ប៉ុល ពត ដេញតាមចាប់ដេញតាមសម្លាប់ខ្ញុំគ្មានឈប់ឈរ ។ ជំងឺនេះ គឺអន្ទោលតាមប្រាណខ្ញុំជានិច្ច ញាំញីអារម្មណ៍ខ្ញុំ ព្រោះអ្វី? ព្រោះនៅសហរដ្ឋអាមេរិកដែលខ្ញុំមកដល់ ខ្ញុំឃើញ ក្រឡេកមើលកូនគេដែលបានទទួលការសិក្សាខ្ពង់ខ្ពស់ ។ ខ្ញុំនឹកទៅដល់កូនខ្ញុំ ស្រណោះកូនខ្ញុំដែលគ្មានវាសនានឹងគេ ត្រូវពួកខ្មែរក្រហមធ្វើបាបសម្លាប់អស់រលីង ។*

*រូបភាពកូនខ្ញុំទាំងប៉ុន្មានគឺបានថតជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ ។ ខ្ញុំនៅចាំជានិច្ចមុខមាត់ ពាក្យសម្តីកូនខ្ញុំតាំងប៉ុន្មាន គឺខ្ញុំនៅចាំទាំងអស់ ។ ពេលខ្ញុំនឹករឿងហ្នឹងឡើង ខ្ញុំឈឺចាប់ ខ្ញុំណែនទ្រូង ខ្ញុំអួលដើមក ទឹកភ្នែកខ្ញុំនៅតែស្រក់នៅឡើយ ពេលណាដែលខ្ញុំនឹកឃើញរឿងទាំងអស់នេះ នឹកឃើញរឿងកូនខ្ញុំដែលត្រូវសម្លាប់យ៉ាងវេទនាបំផុតដោយសារស្នាដៃខ្មែរក្រហម ។*

*ខ្ញុំសូមជម្រាបថា ការឈឺចាប់របស់ខ្ញុំនៅជាប់ក្នុងខ្លួនខ្ញុំ ទឹកភ្នែកខ្ញុំនៅស្រក់ ។ ដូច្នេះ ខ្ញុំដាក់ពាក្យប្តឹងផ្នែករដ្ឋប្បវេណី ដើម្បីចង់បានយុត្តិធម៌មួយដ៏ត្រឹមត្រូវ ដ៏ពិតប្រាកដឲ្យកូនខ្ញុំ ឲ្យឪពុកខ្ញុំ ឲ្យគ្រួសារខ្ញុំ ដែលត្រូវបានខ្មែរក្រហមសម្លាប់ទាំងពូជគ្មានសល់អ្វី គ្មានសេសសល់អ្វីនោះ ។ កាលបើខ្ញុំពុំបានឃើញ មិនឃើញនូវពន្លឺយុត្តិធម៌នោះ ខ្ញុំស្លាប់ទៅខ្ញុំបិទភ្នែកមិនជិតទេ ព្រោះខ្ញុំមិនបានបំពេញភារកិច្ចជាមាតា ជាកូនដែលត្រូវរកយុត្តិធម៌ឲ្យឪពុកម្តាយ ឲ្យកូនជាទីស្នេហារបស់ខ្ញុំ ។ ខ្ញុំសូមយុត្តិធម៌មួយដ៏ពិតប្រាកដ ។ ដូច្នេះហើយ ថ្ងៃនេះជាថ្ងៃដែលខ្ញុំមានវាសនាខ្ពស់បានជួបលោកប្រធានជួបអស់លោកទាំងអស់នៅក្នុងអង្គប្រជុំ ដើម្បីយុត្តិធម៌ដែលជាថ្ងៃដែលខ្ញុំទន្ទឹងជាយូរថ្ងៃឆ្នាំខែណាស់មកហើយ ដែលបានឃើញក្នុងថ្ងៃនេះ ។ ថ្ងៃនេះជាថ្ងៃដែលខ្ញុំចង់បាន ។ សូមជម្រាបលោកប្រធាន និងអស់លោកទាំងអស់សូមមេត្តាជ្រាប» ។*

*សូមបញ្ជាក់ថា នៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីចំនួន៣រូប ។ ទី១ គឺលោកស្រី បេ សុផានី ទី២ លោក សឿន សុវណ្ណឌី និងទី៣ លោកស្រី សេង សុីវត្ថា ។*

## ***៣០) ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណឌី***

*នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សេចក្តីថ្លែងទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ណឌី ជាខ្មែរកម្ពុជាក្រោម ។*

*ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុវណ្ឌឌី មានអាយុ៥៧ឆ្នាំ មានស្រុកកំណើតនៅម្តុំផ្សារដើមគ ទីក្រុងភ្នំពេញ ។ សព្វថ្ងៃរស់នៅភូមិបឹងវែង ឃុំរាំងឫស្សី ស្រុកសង្កែ ខេត្តបាត់ដំបង និងមានមុខរបរជាកសិករ ។ ដើមបណ្តឹងរដ្ឋប្បវេណីមាន ឪពុកឈ្មោះ ម៉ក់ ចេន ម្តាយឈ្មោះ គឹម លាង ប្រពន្ធឈ្មោះ សុង សុផៃ និងមានកូនម្នាក់ ។*

*ដើមបណ្តឹងរដ្ឋប្បវេណី សុវណ្ឌឌី បានរៀបរាប់ថា នៅអំឡុងពេលនៃរបបខ្មែរក្រហម លោកត្រូវបានបង្ខំឲ្យធ្វើការងារ ទាំងគ្មានអាហារគ្រប់គ្រាន់ ដោយទទួលរងនូវការតិះដៀលថា ជាពួកភ្នំពេញ ពួកដេកសុី ពួកសក្តិភូមិ មិនចេះធ្វើការងារ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ខ្មែរកម្ពុជាក្រោម ជាច្រើនត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់ដោយចោទប្រកាន់ថាជាយួន ។*

*ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញរូបថតក្រុមគ្រួសារ ដែលថតនៅមុនពេលនៃរបបខ្មែរក្រហម ដែលនៅក្នុងរូបនោះមានឪពុកម្តាយ មីង ពូ និងប្អូនៗខ្លួនទាំង៤នាក់ ប៉ុន្តែក្រោយមកទាំងដែលស្ថិតក្នុងរូបថតនោះបានបែកបាក់គ្នា ខ្លះស្លាប់ និងខ្លះទៀតបានបាត់ខ្លួន ។*

*ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីសេចក្តីឈឺចាប់ទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សឿន សុណ្ណឌី នៅចំពោះមុខអង្គជំនុំជម្រះ ៖*

*«រឿងការឈឺចាប់ហ្នឹង ឥឡូវនេះខ្ញុំវាដូចថា ពីដើមដូចមានការឈឺចាប់ជាខ្លាំង ដល់ពេលមកឥឡូវនេះ ដូចថាវារំសាយបន្តិចម្តងៗដែរ ពីព្រោះនឹកឃើញថា រយៈកាលកន្លងមកដូចជាវាកាលនោះ ព្រៃផ្សៃ បើសិនជាគាត់ក្តីភ្លាមៗហ្នឹង គឺអាចបាន ។ តែណ្ហើយចុះ ប៉ុណ្ណឹងក៏បានហើយ បើការឈឺចាប់ខ្ញុំវារំសាយបន្តិចម្តងៗដែរ ។ បើសិនជាកាលណាធ្វើនូវអ្វីមួយដែលមិនគប្បីនោះ គឺវាត្រូវតែបន្តសង្គ្រាមតទៅទៀត វាមិនអាចឈប់ឈរបានទេ ។ ការសងសឹកនោះ ខ្មែរឃើញតែសម្លាប់ខ្មែរ មិនដឹងថាមូលហេតុអ្វី? មិនដែលថាជនបរទេសណាមកនេះផង ដូចថាកាលសម័យយៀកកុងៗមិនឃើញយៀកកុងឯណា? ឃើញតែខ្មែរវៃ លន់ នល់ វៃខ្មែរក្រហម គ្មានឃើញយៀកកុងផង ។ ការសំណង ហ្នឹងសុំឲ្យដូចអស់លោកដឹងស្រាប់ហើយ ដូចថាសំណងនោះដូចខ្ញុំ រសាយការឈឺចាប់ ។ សំណងនោះគឺ សុំឲ្យថាឲ្យមកជាសាលារៀន ផ្លូវថ្នល់ ហើយនៅតាមវត្តសុំធ្វើចេតិយមួយសម្រាប់តាំងធ្វើជាកន្លែងគោរពវិញ្ញាណក្ខន្ធរបស់ខ្មែរកម្ពុជាក្រោម ដែលបានចែកឋានទៅនោះ ដែលអត់ដឹងរឿងអីនោះ ។*

*សូម្បីតែកូននៅកន្ទេល ពនឹងដៃ ក៏យកទៅបោកនឹងគល់ឈើដែរហ្នឹង ហើយគ្នាដឹងអី ហើយសាច់ឈាមដ៏រថា កម្ពុជាក្រោមហ្នឹងយកទៅបោកនឹងគល់ឈើលេងទោសម្ងាប់ឪពុកម្តាយ ។ អាហ្នឹងហើយសងសឹក បើតាមខ្ញុំយល់ឃើញ» ។*

## ៣១) *ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា*

នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣ បន្ទាប់ពីស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី បេ សុផានី និង សឿន សុវណ្ណឌី អង្គជំនុំជម្រះសាលាដំបូងបន្តស្តាប់សេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា ជាជនរងគ្រោះនៃរបបខ្មែរក្រហម ដែលទទួលរងការពិការភ្នែក ។

ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា មានអាយុ៤៧ឆ្នាំ រស់នៅក្នុងភូមិពោធិ៍ស្រុកគិរីវង្ស ខេត្តតាកែវ ។ ឪពុកឈ្មោះ ព្រំ ថន ម្តាយឈ្មោះ ម៉ៅ ដាន ប្តីឈ្មោះ ជា ធឿន និងមានកូនបួននាក់ ។ ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា បានទទួលរងពិការភាពទាំងសងខាង ។

ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា បានរៀបរាប់អំពីមូលហេតុដែលនាំឲ្យលោកស្រីពិការភ្នែកថា នៅក្នុងរបបខ្មែរក្រហម នៅពេលមានអាយុ១១ឆ្នាំ ខ្មែរក្រហមបានចាត់តាំងឲ្យទៅកើបដីអាចម៍ជ្រូក មួយថ្ងៃម្តេចក្តីពីក្នុងអន្លង់យ៉ាងជ្រៅ ។ ដោយសារតែគ្មានអាហារហូបចុកគ្រប់គ្រាន់ រួមនឹងការធ្វើការងារធ្ងន់ធ្ងរ មានការនឿយហត់ផង បានធ្វើឲ្យលោកស្រីដួលធ្លាក់ចូលក្នុងរណ្តៅ ពេលនោះខ្មែរក្រហមក៏យកដងរែកមកវាយ ។ បន្ទាប់មក ខ្មែរក្រហមបានចាប់លោកស្រីយកទៅចងនឹងដើមគ្រាច រួចវៃនឹងខ្សែគោត្រូវចំភ្នែកខាងឆ្វេង ។ ស្ថានភាពភ្នែកនោះកាន់តែធ្ងន់ធ្ងរឡើងៗ ។ ក្រោយពេលរបបខ្មែរក្រហម បានដួលរលំដើមបណ្តឹងរដ្ឋប្បវេណីបានចូលរៀននៅក្នុងសាលា ប៉ុន្តែភ្នែកខាងឆ្វេងដែលត្រូវរបួស មើលអក្សរពុំច្បាស់ទេ ធ្វើឲ្យក្មេងៗដែលរៀនជាមួយគ្នាតែងតែដៀលដេរថា«មីខ្វាក់» ។ នៅក្នុងឆ្នាំ ១៩៨២ លោកស្រីបានរៀបអាពាហ៍ពិពាហ៍ ខណៈពេលដែលភ្នែកខាងឆ្វេងលែងមើលឃើញ ហើយភ្នែកខាងស្តាំក៏កាន់តែព្រិលខ្លាំងឡើងៗ ។ រហូតដល់ឆ្នាំ២០០៨ ភ្នែកខាងស្តាំរបស់លោកស្រីបានងងឹតសូន្យឈឹងតែម្តង ។

ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ទាំងទឹកភ្នែកថា ស្វាមីរបស់លោកស្រីបានសុំបែកគ្នា ព្រោះលោកស្រីក្លាយជាមនុស្សពិការភ្នែក ។ ចំណែកកូនទាំងបួននាក់ ត្រូវឈប់រៀនដើម្បីជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ ។

ខាងក្រោមនេះ ជាសេចក្តីថ្លែងរៀបរាប់អំពីសេចក្តីឈឺចាប់ទុក្ខសោក និងសំណើសុំសំណងរបស់ដើមបណ្តឹងរដ្ឋប្បវេណី សេង ស៊ីវត្ថា នៅចំពោះមុខអង្គជំនុំជម្រះ ៖

*«ចាស! នៅនាទីចុងក្រោយនេះ ខ្ញុំទន្ទឹងឲ្យតុលាការកាត់ក្តីសាលាក្តីខ្មែរក្រហមនេះ សូមឲ្យបានលឿនជាទីបំផុត ហើយខ្ញុំក៏សប្បាយចិត្តដែរ ដែលខ្ញុំបានលើកឡើងមកសវនាការនេះ ។ ហើយមួយទៀត ខ្ញុំក៏ចង់បញ្ជាក់ថា ពេលដែលខ្ញុំធ្លាក់ខ្លួនពិការភ្នែកមើលអ្វីមិនឃើញនេះ ដោយក្នុងរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃ ។ ខ្ញុំចង់បញ្ជាក់ថា តើបានអ្នកណាជួយចិញ្ចឹមខ្ញុំ បើខ្ញុំរងទុក្ខលំបាកវេទនាដោយក្តីលំបាករកទីបំផុតគ្មានបែបនេះ ។*

*សព្វថ្ងៃខ្ញុំមានជំងឺធ្ងន់នៅក្នុងខ្លួន ។ ទី១ ត្រចៀករបស់ខ្ញុំមានអាការៈស្រៀវមកសរសៃភ្នែក មកពីសរសៃក្បាលហ្នឹង ស្រៀវៗជាប្រចាំ ហើយដួនក៏ហឹង ដួនក៏ស្រៀវ ហើយធ្វើឲ្យខ្ញុំពិបាកដកដង្ហើម ។ ពេលដង្ហើមខ្ញុំដកដុតៗ ដកអត់ដល់គ្នាធ្វើឲ្យខ្ញុំរៀងស្វះៗ ហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំពិបាកនឹងរស់មែនទែន ពេលដែលខ្ញុំបាត់បង់ភ្នែក ។ ពេលដែលខ្ញុំបាត់បង់អ្វីៗគ្រប់យ៉ាង ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំលែងចង់រស់ ខ្ញុំសម្រេចចិត្តទិញថ្នាំកណ្តុរទិញថ្នាំដង្កូវមកសម្លាប់ខ្លួន ។ ប៉ុន្តែខ្ញុំបានបងស្រី និងម្តាយគាត់បានណែនាំថា មិនឲ្យខ្ញុំធ្វើបែបនេះរស់ដើម្បីមើលថែកូន ។ អីចឹងហើយខ្ញុំសម្រេចចិត្ត ថាទ្រាំរស់តទៅទៀតនៅក្នុងសភាពវេទនា ហើយការឈឺចាប់របស់ខ្ញុំនេះ សព្វថ្ងៃខ្ញុំមិនអាចមានសមត្ថភាពទៅពេទ្យព្យាបាល ឬទៅទិញថ្នាំអ្វីមកព្យាបាលជំងឺខ្ញុំដែរ ។ គ្និតអីខ្ញុំឈឺនេះ បើតាមពិតទៅមិនដឹងឈឺបែបណា ។ បើយប់ឡើងខ្ញុំដេកតែងតែយល់សប្តិអាក្រក់ៗ ហើយដូចជាចេះតែធ្លាក់ថ្លើម ។ សូម្បីតែសំឡេងបើកទ្វារខ្លាំងក៏ខ្ញុំធ្លាក់ថ្លើមគ្គុក ហើយញ័រសាច់ដួនកាលមានអារម្មណ៍អត់ល្អធ្វើឲ្យខឹងកូន អាចវៃកូន បើមិនវៃដូចថាអារម្មណ៍របស់យើងអត់ស្ងប់» ។*

# តើសំណងអ្វីខ្លះដែលដើមបណ្ដឹងរដ្ឋប្បវេណីអាចនឹងទទួលបាន សម្រាប់សំណុំរឿង០០២/០១?

*លឹម ជ័យឫទ្ធ*

## *សេចក្ដីផ្ដើម*

វិធាន២៣ស្ទួនបួន នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ បានចែងថា “*នៅពេលដែលអង្គជំនុំជម្រះរកឃើញអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចសម្រេចផ្ដល់តែសំណងផ្លូវចិត្ត និងជាសមូហភាព ដល់ភាគីដើមបណ្ដឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ*” ។ នៅក្នុងបរិបទនៃការជំនុំជម្រះក្ដីលើអតីតមេដឹកនាំខ្មែរក្រហម អង្គជំនុំជម្រះពុំមានសមត្ថកិច្ចផ្ដល់សំណងជាប្រាក់ក្នុងលក្ខណៈជាបុគ្គលទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីដូចជាករណីតុលាការជាតិឡើយ ។

នៅក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង០០២/០១ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់ឯកសារជូនអង្គជំនុំជម្រះសាលាដំបូង ស្ដីពីគម្រោងសំណងដែលទាមទារដោយដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឲ្យអង្គជំនុំជម្រះទទួលស្គាល់គម្រោងទាំងអស់នោះថាជាសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ។ គម្រោងសំណងដែលដាក់ជូនដោយសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមានចំនួន៣ជំពូក និងត្រូវបានបែងចែកជា១៣គម្រោងសំខាន់ៗ ។

ជំពូកទាំងបីនោះរួមមាន ទី១) ការរំឭក និងការគោរពវិញ្ញាណក្ខ័ន្ធ ទី២) ការស្ដារនីតិសម្បទា និងទី៣) ការចងក្រងឯកសារ និងការអប់រំ ។

គម្រោងសំណង ដែលស្នើសុំដោយដើមបណ្ដឹងរដ្ឋប្បវេណីនាពេលនេះ ពុំមែនបង្កើតឡើងក្នុងន័យឆ្លើយតបទៅនឹងការទាមទារសំណងប្រឆាំងនឹងជនជាប់ចោទទេ ក៏ប៉ុន្តែដើម្បីធានាថា សំណងជាក់ស្ដែង ដែលឧបត្ថម្ភថវិកាដោយប្រភពខាងក្រៅ ទទួលស្គាល់ព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានអនុវត្តដោយឆាប់រហ័ស បន្ទាប់ពីសាលក្រមចូលជាស្ថាពរ ។ គម្រោងសំណង



អ្នកភូមិតម្រង់ជួរដើម្បីចូលមើលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសាលាក្ដីខ្មែរក្រហម
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

មួយចំនួនកំពុងត្រូវបានអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាល ទោះបីជាពុំទាន់មានសាលក្រមស្ដាពរពីអង្គជំនុំជម្រះក៏ដោយ ។ ប៉ុន្តែគម្រោងសំណងទាំងនោះនៅពុំទាន់ក្លាយជាសំណងនៅឡើយទេ ដោយត្រូវរង់ចាំការទទួលស្គាល់ជាផ្លូវការពីសំណាក់អង្គជំនុំជម្រះជាមុនសិន ដើម្បីឲ្យគម្រោងសំណងទាំងអស់នោះអាចក្លាយទៅជាសំណងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ។

ដើម្បីទទួលបានសំណងដែលស្នើសុំអង្គជំនុំជម្រះបានតម្រូវឲ្យសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីធានាថា គម្រោងសំណងទាំងអស់ដែលដាក់ជូនអង្គជំនុំជម្រះឲ្យទទួលស្គាល់ថាជាសំណង ផ្លូវការសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវមានលក្ខណៈប្រាកដប្រជាតាមបច្ចេកទេស និងមានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់អនុវត្ត ។ បន្ថែមពីលើនេះ គម្រោងសំណងត្រូវបង្ហាញពីភ័ស្តុតាងនៃការយល់ព្រម និងកិច្ចសហការរបស់ភាគីទីបីណាមួយ និងត្រូវផ្ដល់ព័ត៌មានបន្ថែមចាំបាច់នានា ដូចជាសេចក្ដីពិពណ៌នាលម្អិត គម្រោងប្លង់ ឬរូបភាព និងផែនការថវិកាសម្រាប់សំណើសុំទាំងនោះ ។ បើពុំដូច្នោះទេ គម្រោងសំណង ដែលស្នើឡើងអាចនឹងត្រូវបដិសេធចោលដោយអង្គជំនុំជម្រះសាលាដំបូង ។

ទោះបីជាយ៉ាងណា នៅក្នុងវិធានផ្ទៃក្នុងក៏បានចែងដែរថា នៅពេលដែលអង្គជំនុំជម្រះរកឃើញពីពិរុទ្ធភាពរបស់ជនជាប់ចោទ អង្គជំនុំជម្រះអាចបង្គាប់ឲ្យពិរុទ្ធជនចេញថ្លៃសោហ៊ុយក្នុងការអនុវត្តសំណង ដែលដើមបណ្ដឹងរដ្ឋប្បវេណីទាមទារ ។ ក៏ប៉ុន្តែប្រសិនបើជនជាប់ចោទទទួលមរណភាពនៅមុនពេលចេញសាលក្រម ដំណើរការនីតិវិធីបណ្ដឹងរដ្ឋប្បវេណីនៅមុខអង្គជំនុំជម្រះចំពោះជនជាប់ចោទរូបនោះនឹងត្រូវបញ្ចប់ ។ ត្រង់ចំណុចនេះមានភាពខុសប្លែកគ្នាពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា២៤ ដែលចែងថា *"ដើមបណ្ដឹងរដ្ឋប្បវេណីអាចសុំឲ្យមានការជួសជុលព្យសនកម្មពីសិទ្ធិវន្តនៃជនជាប់ចោទបាន ប្រសិនបើជនជាប់ចោទនេះទទួលមរណភាពនៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ។ ថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការនៅតែមានសមត្ថកិច្ចដើម្បីសម្រេចលើបណ្ដឹងរដ្ឋប្បវេណីដែលធ្វើឡើងដោយសិទ្ធិវន្តទាំងនោះ"* ។ ប៉ុន្តែ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពុំបានអនុញ្ញាតឲ្យមានការប្ដឹងប្រឆាំងនឹងសិទ្ធិវន្តនៃជនជាប់ចោទពីសំណាក់ដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពេលជនជាប់ចោទបានទទួលមរណភាពឡើយ ។

រហូតមកដល់បច្ចុប្បន្ននេះ ពុំទាន់មានការទទួលស្គាល់ជាផ្លូវការណាមួយចំពោះគម្រោងសំណង ដែលស្នើសុំនៅឡើយទេ ហើយគម្រោងដែលស្នើសុំមួយចំនួនត្រូវបានអង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា នៅខ្វះសេចក្ដីពិពណ៌នាលម្អិតគ្រប់គ្រាន់ ឬខ្វះការបង្ហាញពីភ័ស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបីណាមួយ ។ នៅក្នុងឯកសារមួយផ្ញើជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា គម្រោងសំណងដែលមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ អាចនឹងមិនត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះនោះទេ ។

ខាងក្រោមនេះ ជាគម្រោងសំណងជាក់លាក់ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំឲ្យមានការទទួលស្គាល់ពីសំណាក់អង្គជំនុំជម្រះ ដើម្បីប្រែក្លាយគម្រោងទាំងអស់នោះទៅជាសំណងផ្លូវការសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ ។

## ជំពូកទី១ ការរំឭក និងការគោរពវិញ្ញាណក្ខន្ធ

ជំពូកនេះមានគោលដៅគោរពវិញ្ញាណក្ខន្ធដល់អ្នកដែលបានស្លាប់បាត់បង់ជីវិត ជនរងគ្រោះ និងអនុញ្ញាតឲ្យអ្នកដែលនៅរស់រានមានជីវិត ជាពិសេសដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចជាយុវជនជំនាន់ក្រោយ បានពិចារណាអំពីអ្វីដែលបានកើតឡើង និងប្រារព្ធពិធីនានាតាមជំនឿ និងសាសនារបស់ខ្លួន ។ ជំពូក ការរំឭក និងការគោរពវិញ្ញាណក្ខន្ធនេះ មានគម្រោងសំណងចំនួន៤ ៖

១) គម្រោងទិវាជាតិនៃការចងចាំ

២) គម្រោងសាងសង់ចេតិយ ស្តូប ឬបូជនីយដ្ឋានសាធារណៈ

៣) គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រំឭកដល់ជនរងគ្រោះ និង

៤) គម្រោងកសាងស្តូបនៅប្រទេសបារាំងសម្រាប់ជនជាតិខ្មែរដែលរស់នៅទីនោះ

### ១) គម្រោងទិវាជាតិនៃការចងចាំ

គម្រោងទិវាជាតិនៃការចងចាំ ជាគម្រោងសំណងដែលស្នើ

សុំ ដោយ ដើមបណ្តឹងរដ្ឋប្បវេណីក្នុងគោលបំណងស្វែងរកការបង្កើតឲ្យមានថ្ងៃចងចាំជាផ្លូវការ ដែលជាថ្ងៃឈប់សម្រាកមួយផ្សេងពីថ្ងៃឈប់សម្រាកដែលមាននាពេលបច្ចុប្បន្ន ។ ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំយកមកធ្វើជាទិវាជាតិនៃការចងចាំរួមមាន ថ្ងៃ១៧ ខែមេសា ឬថ្ងៃ២០ ខែឧសភា ឬថ្ងៃ៣០ ខែមីនា ។ ទិវានេះ អាចនឹងប្រារព្ធនៅទូទាំងប្រទេស ដើម្បីទទួលស្គាល់ជាផ្លូវការនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបខ្មែរក្រហម ។

គោលបំណងនៃការបង្កើតឲ្យមានទិវានៃការចងចាំ គឺធ្វើឡើងក្នុងគោលបំណងស្តារកិត្តិយសដល់ជនរងគ្រោះនៃរបបខ្មែរក្រហមទាំងអ្នកដែលបានស្លាប់ និងអ្នកដែលនៅរស់ រំឭកនូវការឈឺចាប់ និងឧទ្ទិសដល់បុគ្គលដែលជាទីស្រឡាញ់របស់ខ្លួន និងលើកតម្កើងការចងចាំនូវឧក្រិដ្ឋកម្មប្រព្រឹត្តក្នុងអំឡុងពេលរបបខ្មែរក្រហមជួយផ្សះផ្សានូវរបួសផ្លូវចិត្ត និងស្តារកិត្តិយសរបស់ជនរងគ្រោះ ។ ម្យ៉ាងវិញទៀត ទិវាជាតិនៃការចងចាំនេះ និងដើរតួនាទីសំខាន់ក្នុងការអប់រំ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតមានសាជាថ្មីម្តងទៀតក្នុងប្រទេសកម្ពុជា ។ គម្រោងនេះនឹងបានជាប្រយោជន៍សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជាប្រជាជនកម្ពុជាអាចជួបជុំគ្នា និងរៀបចំពិធីបុណ្យនានា ។

គម្រោងនេះត្រូវបានរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានឯកភាព និងផ្តល់ការអនុញ្ញាតជាគោលការណ៍តាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរួចរាល់ហើយ និងបានកំណត់យកថ្ងៃទី២០ ខែឧសភា ជាទិវាជាតិនៃការចងចាំនៅក្នុងប្រតិទិនឈប់សម្រាកប្រចាំឆ្នាំ ។ រាជរដ្ឋាភិបាលនឹងចេញអនុក្រឹត្យនាពេលខាងមុខស្តីពីការបង្កើតទិវានេះ ព្រមទាំងអាចចេញសារាចរណែនាំ ឬសេចក្តីជូនដំណឹងទៅអាជ្ញាធរពាក់ព័ន្ធនឹងការអនុវត្តគម្រោងនេះ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ដោយសារតែគម្រោងសំណងនេះពុំត្រូវការចំណាយថវិកា ដូច្នេះការអនុវត្តសំណងនេះអាចអនុវត្តបានគ្រប់ពេលវេលាទាំងអស់ ។

**២) គម្រោងសាងសង់ចេតិយ ស្តូប ឬបូជនីយដ្ឋានសាធារណៈ**

គម្រោងសំណងទាក់ទងនឹងការកសាងស្តូបសាធារណៈ ជាគម្រោងដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នៅក្នុងសំណុំរឿង០០២/០១ ។ គម្រោងសាងសង់ស្តូបសម្រាប់រំឭកជាសាធារណៈបង្កើតឡើងសម្រាប់តម្កល់អដ្ឋិធាតុរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ ជនដៃដល់ និងសាធារណជនមានឱកាសអុចធូប ធ្វើបុណ្យឧទ្ទិសដល់ជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ក្នុងលក្ខណៈយូរអង្វែង និងជាសមូហភាព ។

គម្រោងសំណងនេះ បង្កើតឡើងក្នុងគោលដៅដើម្បីស្តា



គណៈប្រតិភូរបស់របបកម្ពុជាប្រជាធិបតេយ្យទស្សនកិច្ច

កិត្តិយស សេចក្តីថ្លៃថ្នូរ ប៉ះប៉ូវការឈឺចាប់ផ្លូវចិត្ត និងផ្នែកសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណី រំឭកដល់អ្នកដែលបានបាត់បង់ជីវិតលើកកម្ពស់ការយល់ដឹង និងការស្វែងយល់រួមគ្នាពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ បន្ថែមពីលើនេះ គម្រោងនេះនឹងផ្សព្វផ្សាយដល់សហគមហ៍មូលដ្ឋានអំពីអង្គហេតុនៅក្នុងសំណុំរឿង០០២/០១ និងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសក្នុងការនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួន ក៏ដូចជាបទពិសោធន៍ជូរចត់ក្នុងរបបខ្មែរ

ក្រហម ។ ការសាងសង់ស្តូបសាធារណៈនឹងចូលរួមចំណែកលុបបំបាត់ការបែងចែកដែលបណ្តាលមកពីរបបខ្មែរក្រហមក្នុងគោលដៅផ្សះផ្សាសង្គម និងទប់ស្កាត់អំពើឃោរឃៅកុំឲ្យកើតមានឡើងជាថ្មីទៀត ។ ទោះបីជាយ៉ាងណាគម្រោងនេះពុំទាន់មានថវិកាគ្រប់គ្រាន់ដើម្បីអនុវត្តនៅឡើយ ។

### ៣) គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ

គម្រោងសាងសង់បូជនីយដ្ឋានសម្រាប់រំឭកចំពោះជនរងគ្រោះ ជាប្រភេទគម្រោងសិល្បៈ “ជូនចំពោះអ្នកដែលបានបាត់



ប្រទេសចិន (បណ្ណសារ : មជ្ឈមណ្ឌលឯកសារកម្ពុជា)

បង់ជីវិត” និងជាគំនិតដែលផ្តួចផ្តើមដោយសិល្បៈករសូនរូបខ្មែរ-បារាំងមួយរូប ឈ្មោះ សេរា ។ សេរា ជាសិល្បៈករមួយរូបដែលត្រូវបានចាត់ចំណាត់ថ្នាក់ថា ជាសិល្បៈករប្រសើរបំផុតនៅប្រទេសបារាំងប្រចាំឆ្នាំ២០០២-២០១២ ។ គម្រោងនេះមានគោលដៅរំឭកឡើងវិញអំពីព្រឹត្តិការណ៍ជាក់ស្តែងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលជាចំណុចចាប់ផ្តើមនៃវិនាសកម្មលើប្រជាជនកម្ពុជា ។ ការចាកចេញពីភ្នំពេញដោយការបង្ខិតបង្ខំពីសំណាក់ខ្មែរក្រហម បានបង្កើតនូវអនាគតមួយដែលមិនប្រាកដប្រជា និងរងទុក្ខវេទនាបំផុតនៅទីបញ្ចប់ ។ ទីតាំងដែលត្រូវសាងសង់ និងតម្កល់រូបចម្លាក់ គឺនៅទល់មុខស្ថានទូតបារាំង ត្រង់វង់មូលជិតស្ពានជ្រោយចង្វារ ។ ការជ្រើសរើសយកទីតាំងនៅមុខស្ថានទូតបារាំងជាទីកន្លែងសម្រាប់តម្កល់រូបចម្លាក់ទាំងនេះ ដោយសារទីតាំងនោះ គឺជាចំណុចមួយនៃទីក្រុងភ្នំពេញ និងជាច្រកចេញនៃប្រជាជនជាច្រើន ដែលត្រូវបានជម្លៀសចេញ និងព្រមទាំងជាទីកន្លែងដែលមនុស្សរាប់ពាន់នាក់បានទៅជ្រកកោននៅទីនោះ រួចចាកចេញពីក្រុងក្រោយគេបង្អស់ ។ ដើមបណ្តឹងរដ្ឋប្បវេណី ជាជនរងគ្រោះនៃការជម្លៀស និងដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលមានសាច់ញាតិត្រូវបានជម្លៀសនៅពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនឹងមានកន្លែងមួយ និងរូបចម្លាក់សម្រាប់គោរពបូជា និងធ្វើពិធីនានាតាមប្រពៃណីសាសនា និងជំនឿ ។ គម្រោងនេះទទួលបានការគាំទ្រថវិកា ពីសំណាក់រដ្ឋាភិបាលប្រទេសបារាំង និងបុគ្គលផ្សេងៗទៀត ហើយគម្រោងសំណងនេះអាចអនុវត្តបាននៅគ្រប់ពេលវេលា ។

### ៤) គម្រោងកសាងស្តូបរំឭកដល់ជនរងគ្រោះរបបខ្មែរក្រហម សម្រាប់ប្រជាជនខ្មែរនៅប្រទេសបារាំង

គម្រោងនេះស្នើឡើងដោយប្រជាជនខ្មែររស់នៅប្រទេសបារាំង ដើម្បីអាចឲ្យពួកគាត់គោរពវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ហើយប្រជាជនទូទៅក៏អាចទៅទីកន្លែងនោះដើម្បីបន់ស្រន់ និងឧទ្ទិសបានគ្រប់ពេលវេលា ។ បន្ថែមពីលើនេះ ស្តូបរំឭកវិញ្ញាណក្ខន្ធនឹងក្លាយជាទីកន្លែងជួបជុំរបស់ខ្មែរសម្រាប់ធ្វើបុណ្យ និងរំឭកវិញ្ញាណក្ខន្ធប្រចាំឆ្នាំ ហើយស្តូបនេះរឹតតែសំខាន់ថែមទៀត ដោយសារប្រជាជនកម្ពុជាភាគច្រើនពុំអាចស្វែងរកឆ្អឹងសាច់ញាតិដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ។ គម្រោងសំណងប្រភេទនេះ នឹងអនុញ្ញាតឲ្យជនរងគ្រោះអាចរំឭកជាអចិន្ត្រៃយ៍ និងសមូហភាព នូវអនុស្សាវរីយ និងធ្វើឲ្យក្មេងជំនាន់ក្រោយ និងសាធារណជនមានការចាប់អារម្មណ៍ចំពោះអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ បច្ចុប្បន្ន គម្រោងនេះទទួលបានការឯកភាពពីសាលាក្រុងប៉ារីស

នៃប្រទេសបារាំងរួចហើយ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក្តី គម្រោងនេះកំពុងស្ថិតនៅដំណាក់កាលស្វែងរកថវិកាដើម្បីយកមកអនុវត្តនៅឡើយ ។

### ជំពូកទី២ ការស្តានីតិសម្បទា

នៅក្នុងជំពូកទាក់ទងនឹងគម្រោងសំណងស្តានីតិសម្បទា មានការបែងចែកចេញជាពីរគម្រោង គឺគម្រោងចងក្រងសក្ខីកម្ម និងគម្រោងស្តីពីក្រុមជួយខ្លួនឯង ។ គម្រោងទាំងពីរនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះ ដោយសារអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។

### ១) គម្រោងប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់នៅក្នុងឯកសារស្នើសុំសំណង ដែលដាក់ជូនអង្គជំនុំជម្រះសាលាដំបូងថា ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនបានស្នើសុំសំណងជាការព្យាបាលការឈឺចាប់ផ្នែកផ្លូវចិត្ត ដោយអ្នកជំនាញចិត្តសាស្ត្រ ចំពោះការទទួលរងរបួសផ្លូវចិត្តដោយសារអំពើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ គម្រោងសំណង «ការប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងសក្ខីកម្ម» នឹងធ្វើឡើងដោយការនិយាយរៀបរាប់ពីរឿងរ៉ាវដែលកើតឡើងចំពោះជនរងគ្រោះ សមាជិកគ្រួសារ និងសាច់ញាតិជាសាធារណៈ អំពីការឈឺចាប់ និងការទទួលរងរបួសផ្លូវចិត្ត ដោយសារអំពើឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហម ។ ការរៀបរាប់របស់របស់ជនរងគ្រោះនឹងត្រូវបានចងក្រងជាឯកសារជាលាយលក្ខណ៍អក្សរ ដែលការចងក្រងនេះត្រូវបានហៅថា សក្ខីកម្ម ។ ក្នុងដំណាក់កាលបន្ទាប់ សក្ខីកម្ម ទាំងនោះនឹងត្រូវអានឮៗក្នុងអំឡុងពេលពិធីបុណ្យជាសាធារណៈទូទាំងប្រទេស ដោយធ្វើឡើងនៅជិតទីកន្លែងរស់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ពិធីបុណ្យទាំងនោះ នឹងអាចរាប់បញ្ចូលទាំងអ្នកដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម សមាជិកគ្រួសារ សមាជិកក្នុងសហគមន៍ អ្នកដឹកនាំសាសនា អ្នកនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ។ បន្ទាប់ពីពិធីបុណ្យ សក្ខីកម្មទាំងអស់នោះនឹងត្រូវប្រគល់ជូនដើមបណ្តឹងរដ្ឋប្បវេណី ។

គម្រោងសំណងប្រភេទនេះ នឹងជួយលើកកម្ពស់ការព្យាបាល និងការបង្រួបបង្រួមជាតិតាមរយៈការផ្តល់សំណងសមូហភាព និងផ្លូវចិត្ត និងបង្កើតសេវាសុខភាពផ្លូវចិត្ត និងរូបកាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលរងការឈឺចាប់ ឬក៏មានជំងឺដោយសារមូលហេតុនៃឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងសម័យខ្មែរក្រហម ។ ម្យ៉ាងវិញទៀត គម្រោងសំណងនេះនឹងជួយធ្វើឲ្យប្រសើរឡើងនូវសុខមាលភាពផ្លូវចិត្តរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ដោយស្តារនូវសេចក្តីថ្លៃថ្នូរ ភាពជឿជាក់ ថាមពល និងសមត្ថភាព និងអនុញ្ញាតឲ្យពួកគាត់ស្វែងរកនូវគុណភាពនៃអារម្មណ៍ និងដើម្បីគ្រប់គ្រងអតីតកាល និងការពិបាកខាងផ្នែកផ្លូវចិត្តដែលមានរហូតដល់បច្ចុប្បន្ន ។



នួន ជា នៅក្នុងបន្ទប់សវនាការ
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២) គម្រោងបង្កើតក្រុមជួយខ្លួនឯង

គម្រោងបង្កើតក្រុមជួយខ្លួនឯង គឺមានលក្ខណៈដូចគ្នានឹងគម្រោងនៃការព្យាបាលផ្លូវចិត្តតាមរបៀបចងក្រងសក្ខីកម្ម ។ ក្រុមជួយខ្លួនឯង គឺជាការប្រមូលផ្តុំដោយស្ម័គ្រចិត្តនៃអ្នកដែលមានបំណងជម្នះនូវការឈឺចាប់របស់ខ្លួន ស្វែងយល់ និងគ្រប់គ្រងអារម្មណ៍របស់ខ្លួនតាមរយៈការផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមក ។ គម្រោងនេះ មានគោលបំណងផ្តល់លទ្ធភាពឲ្យដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃការជម្លៀសដោយបង្ខំ នៅក្នុងសំណុំរឿង០០២ រៀបរាប់អំពីការឈឺចាប់

របស់ខ្លួនក្នុងពេលជួបប្រជុំគ្នា ហើយតាមរយៈការរាប់រៀបនេះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងអាចចាប់ផ្តើមដំណើរការព្យាបាលការឈឺចាប់ដែលបានទទួលរងគ្រោះ ។ គម្រោងនេះ ជាមធ្យោបាយក្នុងការបំបែកភាពឯកោ និងមនោសញ្ចេតនាបន្ទុំរំងខ្លួនឯង តាមរយៈការបង្កើតឲ្យមានទំនាក់ទំនងជាមួយអ្នកដទៃ ។

ទាំងគម្រោងប្រើប្រាស់វិធីព្យាបាលតាមរបៀបចងក្រងជាសក្ខីកម្ម និងគម្រោងបង្កើតក្រុមជួយខ្លួនឯង ទទួលបន្ទុកអនុវត្តដោយអង្គការចិត្តសង្គមអន្តរវប្បធម៌ (ធី.ភី.អូ) ដែលមានរយៈពេល១៦ខែ ដោយទទួលថវិកាមួយផ្នែកពីរដ្ឋាភិបាលអាល្លឺម៉ង់



មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បេនី យេ
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងសប្បុរសជនមួយចំនួនទៀត ។

**ជំពូកទី៣ ការចងក្រងឯកសារ និងការអប់រំ**

គម្រោងសំណងនៅក្នុងជំពូកទី៣ ទាក់ទងនឹងការចងក្រងឯកសារ និងការអប់រំ ត្រូវបានបញ្ជាក់ ដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា គម្រោងសំណងនេះមានគោលដៅរក្សា និងជំរុញឲ្យមានការយល់ដឹងអំពីប្រវត្តិសាស្ត្រនៅក្នុងសម័យខ្មែរក្រហម និងបទពិសោធន៍នីមួយៗរបស់ជនរងគ្រោះ ។ ជំពូក ការចងក្រងឯកសារ និងការអប់រំនេះ មានគម្រោងសំណងជាក់លាក់ចំនួន៧ ដែលជាគម្រោងសំណងស្នើសុំដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រោយពីបានស្តាប់ការចង់បានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះនៃរបបខ្មែរក្រហម ។ គម្រោងសំណងទាំងនោះរួមមាន ៖

១) គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍
២) គម្រោងតាំងពិព័រណ៍ចល័ត
៣) គម្រោងតាក់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ
៤) គម្រោងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព
៥) គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង០០២/០១
៦) គម្រោងបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប
៧) គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**១) គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍**

គម្រោងសំណងនេះ ត្រូវបានទាមទារដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២ ដែលនៅក្នុងនោះ មួយចំណែកធំបានរងគ្រោះដោយសារការជម្លៀសដោយបង្ខំ ដែលបានកើតឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃបន្តបន្ទាប់ ។ ការជម្លៀសនេះ គឺជាកម្មវត្ថុនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។

គម្រោងនេះមានគោលដៅថែរក្សា លើកតម្កើងរឿងរ៉ាវ និងបទពិសោធន៍ដែលកើតមាននៅអំឡុងពេលនៃរបបខ្មែរក្រហម ដោយថែរក្សានូវភស្តុតាងគ្រប់ប្រភេទនៅក្នុងទីតាំងជាក់លាក់ ហើយការថែរក្សាភស្តុតាងក្នុងរយៈពេលវែងនឹងចូលរួមក្នុងការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រ ។ គម្រោងនេះ រៀបចំឡើងដើម្បីជាការឧទ្ទិសទៅដល់ជនរងគ្រោះ និងជាមធ្យោបាយសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីអាចផ្តល់នូវបទពិសោធន៍សម្រាប់មនុស្សជំនាន់ក្រោយ និងសាធារណជនជាតិ និងអន្តរជាតិ ។

គម្រោងនេះ ក៏មានគោលដៅអប់រំ ដោយបង្ហាញពីបទ

ពិសោធន៍ដែលមាននៅក្នុងអតីតកាល និងផ្សព្វផ្សាយទៅកាន់មនុស្សជំនាន់ក្រោយសម្រាប់ទុកជាចំណេះដឹង និងចូលរួមនៅក្នុងការផ្សះផ្សាជាតិ។ បន្ថែមពីលើនេះ គម្រោងនេះនឹងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះជាច្រើនផ្សេងទៀត ចងក្រង វែកញែក និងយល់ដឹងអំពីរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហម ហើយគម្រោងនេះក៏នឹងបង្កើតឲ្យមានកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រមួយ និងធ្វើឲ្យរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្សព្វផ្សាយទៅដល់សាធារណជនទូទៅដែរ។

គម្រោងតាំងពិព័រណ៍អចិន្ត្រៃយ៍ ជាគម្រោងដែលនឹងត្រូវអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលនឹងត្រូវបំពេញភារកិច្ចយ៉ាងជិតស្និតជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ជាបឋមការតាំងពិព័រណ៍អចិន្ត្រៃយ៍នឹងត្រូវធ្វើនៅសារមន្ទីរនៃខេត្តចំនួន៥ ដោយជាបឋមចាប់ផ្តើមពីខេត្តបាត់ដំបង និងបន្ទាយមានជ័យ បន្ទាប់មកនឹងមានការរៀបចំដូចគ្នានៅខេត្តកំពង់ធំ តាកែវ និង ស្វាយរៀង។ ការជ្រើសរើសយកបណ្តាខេត្តទាំងនេះដើម្បីអនុវត្តគម្រោង ដោយសារដំណើរការ និងរចនាសម្ព័ន្ធនៃសារមន្ទីរនៅមានលក្ខណៈល្អច្រើន។ បន្ថែមពីលើនេះ ទីតាំងដែលត្រូវជ្រើសរើសយកមកធ្វើពិព័រណ៍ទាំងអស់នេះ មានភាពជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០១ ដោយមានជនរងគ្រោះដោយសារការជម្លៀសត្រូវបានបញ្ជូនទៅទីកន្លែងទាំងនោះ។ ទោះបីជាខ្លឹមសារនៃការតាំងពិព័រណ៍ អាចផ្តោតលើបញ្ហាផ្សេងៗនៃប្រវត្តិសាស្ត្រខ្មែរក្រហម ប៉ុន្តែប្រធានបទជាដំបូង



កុមាររៀនអំពីការដាំដុះស្រូវ (បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងក្របខណ្ឌនៃការថែរក្សា និងអភិវឌ្ឍសារមន្ទីរចំនួន២៤ខេត្ត-ក្រុង នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានឯកភាពដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការចូលរួមបង្កើតបណ្តាញថែរក្សា និងលើកតម្កើងវប្បធម៌ ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជានឹងចូលរួមក្នុងការរៀបចំឯកសារ និងការតាំងពិព័រណ៍អំពីរបបខ្មែរក្រហមនៅគ្រប់ខេត្ត-រាជធានី នៃព្រះរាជាណាចក្រកម្ពុជា។

នឹងផ្តោតជាសំខាន់ទៅលើការជម្លៀសដោយបង្ខំនៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ ព្រមទាំងអង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។

គម្រោងនេះនឹងត្រូវអនុវត្តក្នុងរយៈពេល១៦ខែ ដោយចាប់ផ្តើមពីខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ខែធ្នូ ឆ្នាំ២០១៤។ ចន្លោះពីខែកញ្ញា ឆ្នាំ២០១៣ រហូតដល់ខែមេសា ឆ្នាំ២០១៤ ជាដំណាក់កាល រៀបចំសម្ភារ និងការតាំងពិព័រណ៍ ហើយការបើកដំណើរការ

ជាក់ស្តែងនៃការតាំងពិព័រណ៍ គឺចាប់ផ្តើមពីខែឧសភា រហូតដល់ខែធ្នូ ឆ្នាំ២០១៤ ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួននឹងចូលរួមក្នុងការរៀបចំការតាំងពិព័រណ៍នេះ ហើយពួកគាត់នឹងរៀបរាប់អំពីរឿងរ៉ាវរបស់ខ្លួនសម្រាប់ការចងក្រង និងចូលរួមចែករំលែកអំពីអ្វីដែលគាត់បានជួបប្រទះក្នុងរបបខ្មែរក្រហម រួមទាំងដំណើរការកាត់ក្តីផង ។

ការតាំងពិព័រណ៍អចិន្ត្រៃយ៍នេះ នឹងក្លាយជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ។ មូលនិធិសម្រាប់ការអនុវត្តគម្រោងសំណងនេះទទួលបានពីរដ្ឋាភិបាលអាល្លឺម៉ង់ ។

## ២) គម្រោងតាំងពិពរណ៍ចល័ត

គម្រោងសំណងទាក់ទងនឹងការតាំងពិព័រណ៍ចល័ត មានគោលបំណងជំរុញឲ្យមានការទទួលស្គាល់ជាសាធារណៈនូវការទទួលរងទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ជាពិសេសទាក់ទងនឹងការជម្លៀសដោយបង្ខំ និងដើម្បីពង្រឹងការចូលរួមរបស់ប្រជាជនកម្ពុជាក្នុងការឆ្លុះបញ្ចាំងពីអតីតកាលក្នុងរបបខ្មែរក្រហម និងធ្វើយ៉ាងណាដើម្បីទប់ស្កាត់កុំឲ្យមានអំពើបែបនេះកើតឡើងសាជាថ្មីម្តងទៀត ។ បន្ថែមពីលើនេះ គម្រោងតាំងពិព័រណ៍ចល័តត្រូវបានរំពឹងថានឹងចូលរួមក្នុងការលើកតម្កើងវប្បធម៌សន្តិភាព និងការផ្សះផ្សាជាតិតាមរយៈការផ្តល់សំណងផ្លូវចិត្ត និងសមូហភាព ។ ដើមបណ្តឹងរដ្ឋប្បវេណីនឹងទទួលបានការឧបត្ថម្ភផ្នែកសម្ភារក្នុងអំឡុងពេលនៃការតាំងពិព័រណ៍ និងអាចចូលរួមក្នុងការរចនាការតាំងពិព័រណ៍ និងសកម្មភាពអប់រំផ្សេងៗចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលពុំទាន់មានពាក់ព័ន្ធនឹងសកម្មភាពផ្សព្វផ្សាយ ដូចជា ដើមបណ្តឹងរដ្ឋប្បវេណីជាស្ត្រី និងក្រុមជនជាតិភាគតិច ក៏នឹងត្រូវអញ្ជើញឲ្យចូលរួមក្នុងការតាំងពិព័រណ៍នេះដែរ ។

គម្រោងតាំងពិព័រណ៍ចល័តនេះ ជាគម្រោងដែលនឹងត្រូវអនុវត្តដោយអង្គការយុវសន្តិភាព និងអង្គការក្តីករុណា នៅលើទីតាំងចំនួន៦កន្លែង ដែលត្រូវបានជ្រើសរើសសម្រាប់ជាគោលដៅនៃការអនុវត្តគម្រោងសំណងនេះ ។ ការអនុវត្តគម្រោងនេះត្រូវបានបែងចែកជាពីរដំណាក់កាល ។ ដំណាក់កាលទី១ មានដូចជា ការរៀបចំរចនាអំពីគំនិតនៃការពិព័រណ៍ ការផលិតឯកសារវីដេអូ ការតាំងពិព័រណ៍តាមបន្ទះក្តារ ផលិតសម្ភារទាក់ទងនឹងការផ្តល់ព័ត៌មាន ការអប់រំ និងការទំនាក់ទំនងរៀបចំរចនាកម្មវិធីគម្រោង សម្រាប់វេទិកាសាធារណៈ សិក្ខាសាលា ការសម្តែងល្ខោន តន្ត្រី បុណ្យទាន និងការបញ្ចាំងកុន និងការផលិតឯកសារវីដេអូស្តីពីការតាំងពិព័រណ៍ ។ ដំណាក់កាលទី២ អង្គការទាំងពីរនឹងបង្កើតក្រុមការងារ ដោយឡែកៗខ្លួនដើម្បីអនុវត្តគម្រោងទាំងនេះ ។ មូលនិធិសម្រាប់អនុវត្តគម្រោងនេះទទួលបានពី រដ្ឋាភិបាលអាល្លឺម៉ង់ ។

## ៣) គម្រោងតាក់តែងជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ

គម្រោងសំណងស្តីពីការតាក់តែងជំពូកដាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់បញ្ចូលទៅក្នុងសៀវភៅបណ្តុះបណ្តាលគ្រូទទួលបន្ទុកបង្រៀនមុខវិជ្ជាពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រខ្មែរក្រហម មានគោលដៅធ្វើឲ្យមានការទទួលស្គាល់ជាផ្លូវការ និងជាអចិន្ត្រៃយ៍នៃប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ម្យ៉ាងវិញទៀត សំណងប្រភេទនេះនឹងជួយលើកតម្កើងការអប់រំ អំពីរឿងហេតុនៃប្រវត្តិសាស្ត្រ និងអប់រំយុវជនជំនាន់ក្រោយឲ្យមានគំនិតចេះទទួលខុសត្រូវដោយថ្លៃថ្នូរ ដើម្បីទប់ស្កាត់មិនឲ្យកើតមានឧក្រិដ្ឋកម្ម ដូចជាអ្វីដែលធ្លាប់កើតមាននៅក្នុងរបបខ្មែរក្រហម ។

ជំពូកនេះនឹងត្រូវរៀបចំ និងចែកចាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ព ចែកចាយ និងព្រមទាំងដាក់ឲ្យអនុវត្តសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀនរួចមកហើយ ។ ដូច្នេះ ជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ នឹងត្រូវបញ្ចូលទៅក្នុងសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ។ ជំពូកនេះ មានចំណងជើងថា *"ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអង្គហេតុវិនិច្ឆ័យក្នុងករណី០០២/០១"* ដោយចែកចេញជា៤មេរៀន និងមាន ១៦ទំព័រ ។ មេរៀនទី១ និយាយអំពីគោលនយោបាយ គោល

បំណងព្រមទាំងដំណាក់កាលផ្សេងៗនៃការជម្លៀសប្រជាជន ។ មេរៀនទី២ លើកឡើងការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងបទពិសោធន៍ដែលពួកគាត់បានជួបប្រទះ ក្នុងអំឡុងពេលនៃការជម្លៀស ។ មេរៀនទី៣ លើកឡើងអំពីផលវិបាកនៃការជម្លៀសដោយបង្ខំមកលើជនរងគ្រោះ ។ ចំពោះមេរៀនទី៤ អត្ថាធិប្បាយអំពីទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ដោយផ្តោតជាពិសេសលើស្ថានភាព និងការសម្លាប់រង្គាលនៅទីនោះ ព្រមទាំងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។

ផុយពីគម្រោងសំណងពីរផ្សេងទៀត គម្រោងសំណងស្តីពីការគាត់តែងជំពូកជាក់លាក់ស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ អាចអនុវត្តបានលុះត្រាមានសេចក្តីសម្រេចពីអង្គជំនុំជម្រះលើអង្គហេតុនៃសំណុំរឿង ០០២/០១ជាមុនសិន ។ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបញ្ជាក់ថា អង្គជំនុំជម្រះពុំទាន់ទទួលស្គាល់គម្រោងនេះជាផ្លូវការបាននៅឡើយទេ ដោយសារតែគម្រោងសំណងនេះមានពាក់ព័ន្ធនឹងអង្គហេតុដែលមិនទាន់ត្រូវបានវិនិច្ឆ័យ ។ នៅពេលរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទ និងមានសាលក្រមផ្តន្ទាទោស អង្គជំនុំជម្រះនឹងមានធាតុផ្សំគ្រប់គ្រាន់សម្រាប់ទទួលស្គាល់គម្រោងនេះថាជាសំណង ។

## ៤) គម្រោងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព

គម្រោងសំណងសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព ត្រូវបានស្នើឡើងក្នុងគោលដៅអភិវឌ្ឍន៍ ការពិចារណា និងបែបបទសម្រាប់ថែរក្សាដំណើរការសន្តិភាព និងអភិបាលកិច្ចល្អ និងអនុញ្ញាតឲ្យមានការឆ្លើយឆ្លងរវាងជនរងគ្រោះ និងយុវជន ដើម្បីជំនួយដល់ការពិចារណារបស់យុវជនជំនាន់ក្រោយ និងទប់ស្កាត់មិនឲ្យកើតមានសាជាថ្មីនូវអំពើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើហិង្សាធ្ងន់ធ្ងរ ។ គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងខេត្តបាត់ដំបង ។ ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវអញ្ជើញឲ្យចូលរួមចែករំលែកអំពីបទពិសោធន៍ដែលធ្លាប់បានជួបប្រទះពាក់ព័ន្ធនឹងការជម្លៀស និងការធ្វើទុក្ខបុកម្នេញលើជនរងគ្រោះ ។ ជាពិសេសពាក់ព័ន្ធនឹងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក្នុងក្របខណ្ឌនៃការចងក្រងឯកសារ និងមានពន្យល់អំពីអង្គហេតុដែលបានកើតឡើង រួមជាមួយនឹងដំណើរការវិវឌ្ឍន៍នៅសាលាក្តីខ្មែរក្រហមដែរ ។ មជ្ឈមណ្ឌលនេះនឹងក្លាយជាទីកន្លែងមួយសម្រាប់ចងក្រង ផ្សព្វផ្សាយ បណ្តុះបណ្តាល ពិភាក្សា និងអប់រំ ។

ចំពោះទីកន្លែងសម្រាប់សាងសង់មជ្ឈមណ្ឌលនេះ នឹងត្រូវធ្វើនៅអតីតកន្លែងសម្លាប់មនុស្សរួម នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបច្ចុប្បន្នជាដីរបស់សហគមន៍ ។ សកម្មភាពផ្សេងទៀតរបស់គម្រោងនេះ មានដូចជា ការបណ្តុះបណ្តាលសមត្ថភាព និងអភិបាលកិច្ចល្អ ការរៀបចំវេទិកាសាធារណៈមួយលើកសម្រាប់មនុស្ស១០០នាក់ បណ្តុំការងារហត្ថកម្ម ការបង្កើត និងកែលម្អប្រព័ន្ធគ្រប់គ្រងបណ្ណាល័យ ការបោះដំរុំរបស់យុវជន និងការចងក្រងឯកសារអំពីទីកន្លែងសម្លាប់មនុស្ស ។

គម្រោងនេះនឹងអនុវត្តដោយអង្គការយុវសន្តិភាព ដោយមានរយៈពេល២ឆ្នាំ គិតចាប់ពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែសីហា ឆ្នាំ២០១៥ ដោយមានជំនួយហិរញ្ញវត្ថុពីអង្គការស៊ីវសម្រាប់ការអភិវឌ្ឍ ។

## ៥) គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង ០០២/០១

គម្រោងសំណងនេះ ត្រូវបានស្នើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបោះពុម្ពជាកូនសៀវភៅដែលមានប្រើប្រាស់ពាក្យពេចន៍សាមញ្ញ និងងាយយល់ព្រមទាំងមានគំនូរ និងរូបភាពជាច្រើន ដែលអាចឲ្យយល់បានដោយងាយអំពីដំណើរការវិវឌ្ឍន៍នៅសាលាក្តីខ្មែរក្រហម ។ សៀវភៅនេះនឹងជួយឲ្យបុគ្គលម្នាក់ៗស្គាល់ពីព្រឹត្តិការណ៍នៃរបបកម្ពុជាប្រជាធិបតេយ្យ និងយល់ពីប្រវត្តិសាស្ត្រ ដើម្បីជាមូលដ្ឋានក្នុងការពិចារណា ។ កូនសៀវភៅនេះក៏ជាការឧទ្ទិសដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានចូលរួមក្នុងនីតិវិធីតុលាការក្នុងនាមឲ្យជនរងគ្រោះទាំងឡាយ ។

គម្រោងបោះពុម្ពកូនសៀវភៅពីដំណើរការនៃសំណុំរឿង ០០២/០១ នឹងត្រូវអនុវត្តដោយអង្គការគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា ហៅកាត់ថា "CHRAC" ដែលជាបណ្តុំអង្គការ និងសមាគមចំនួន២១រួមគ្នា ដោយ

ទទួលបានការផ្តល់ថវិកាពីអង្គការសហប្រតិបត្តិការអាល្លឺម៉ង់ ។

**៦) គម្រោងបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប**

ចំពោះគម្រោងសំណងទាក់ទងនឹងការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមទាំងមូល និងជាសង្ខេប ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គជំនុំជម្រះចាត់ទុកគម្រោងនេះថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានស្នើឲ្យផ្នែកកិច្ចការសាធារណៈរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាអ្នកអនុវត្តគម្រោងនេះ ដោយបោះពុម្ព និងចែកចាយសាលក្រមទាំងមូល និងសាលក្រមសង្ខេបនៃសំណុំរឿង០០២/០១ ចែកជូនដើមបណ្តឹងរដ្ឋប្បវេណី សាធារណជន និងអ្នកវិជ្ជាជីវៈផ្នែកច្បាប់ ។

គម្រោងសំណងនេះនឹងចូលរួមចំណែកលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីកិច្ចដំណើរការនីតិវិធីរបស់តុលាការ និងចូលរួមចំណែកផ្សះផ្សាជាតិ ។ ទោះបីជាយ៉ាងក្តី ថវិកាសម្រាប់យកមកបោះពុម្ពផ្សាយសាលក្រមនេះ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយទេ ។

គម្រោងនេះនឹងត្រូវចំណាយពេលអនុវត្តរយៈពេល៤ខែ បន្ទាប់ពីមានការទទួលស្គាល់ពីសំណាក់អង្គជំនុំជម្រះថាជាសំណង ។

**៧) គម្រោងផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

គម្រោងសំណងស្តីពីការផ្សព្វផ្សាយឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងគេហទំព័ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបង្ហាញអំពីការចូលរួម និងលើកតម្លៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងកិច្ចដំណើរការរបស់តុលាការ ។ ការផ្សាយនេះមានរួមបញ្ចូលទាំងឈ្មោះជាភាសាខ្មែរអក្សរឡាតាំង លេខដើមបណ្តឹងរដ្ឋប្បវេណីដែលចេញដោយអង្គភាពគាំពារជនរងគ្រោះ និងធាតុចាំបាច់ផ្សេងទៀត ដែលងាយស្រួលក្នុងការស្វែងរកឈ្មោះ ។

គម្រោងនេះនឹងត្រូវចំណាយពេលអនុវត្តរយៈពេល៣ខែ បន្ទាប់ពីមានសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមានការសហការរវាងអង្គភាពគាំពារជនរងគ្រោះ និងផ្នែកកិច្ចការសាធារណៈនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**ការកត់សម្គាល់របស់អង្គជំនុំជម្រះលើគម្រោងសំណងដែលស្នើសុំ**

ដូចបានបញ្ជាក់ គម្រោងសំណងទាំងអស់ដែលរាប់រៀបខាងលើពុំទាន់ក្លាយជាសំណងផ្លូវការសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី



គណប្រតិភូមកពីប្រទេសស៊ុយអែត កំពុងបរិភោគអាហារជាមួយកម្មាភិបាលខ្មែរក្រហម ក្នុងខែសីហា ឆ្នាំ១៩៧៨
(បណ្ណសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

វេណីនៅឡើយទេ ។ ការរៀបរាប់លម្អិតអំពីគម្រោងនីមួយៗ របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនាពេលនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីជូនដំណឹង និងធានាអំពីវិសាលភាព និងប្រសិទ្ធភាពនៃគម្រោងសំណងដែលបានស្នើសុំ និងដើម្បីទុកឱកាសឲ្យអង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពពិនិត្យមើល និងផ្តល់ការណែនាំថា តើសំណងដែលបានស្នើសុំនោះស្របជាមួយក្របខ័ណ្ឌ គតិយុត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬយ៉ាងណា ។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិនិត្យឃើញថា គម្រោងសំណងដែលស្នើសុំពុំមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ដើម្បីអនុវត្តទេ គម្រោងសំណងទាំងនោះនឹងពុំត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ឡើយ ។

អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា គម្រោងសំណងមួយចំនួននៅពុំទាន់មានលក្ខណៈច្បាស់លាស់គ្រាន់គ្រប់ដើម្បីអាចយកទៅអនុវត្តបាននៅឡើយ ដោយសារនៅខ្វះសេចក្តីពិពណ៌នាលម្អិត ឬខ្វះការបង្ហាញពីភ័ស្តុតាងនៃការយល់ព្រម និងសហប្រតិបត្តិការរបស់ភាគីទីបី ។ គម្រោងទាំងនោះមានដូចជាគម្រោងស្នើសុំស្តូបរំឭកជាសាធារណៈ និងគម្រោងសាងសង់បូជនីយដ្ឋាន ដែលនៅពុំទាន់មានការបញ្ជាក់ច្បាស់អំពីថវិកា និងគម្រោងប្លង់ ឬគំរូបំព្រួញ និងជាពិសេស ពុំទាន់មានឯកសារបង្ហាញអំពីការអនុញ្ញាតរបស់អាជ្ញាធររាជធានីភ្នំពេញឲ្យសាងសង់បូជនីយដ្ឋាននៅលើទីតាំងដែលបានស្នើសុំ ដែលជាទ្រព្យសម្បត្តិសាធារណៈនៅឡើយ ។

អង្គជំនុំជម្រះបានបញ្ជាក់ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា អង្គជំនុំជម្រះមិនអាចធ្វើការយល់ព្រមលើគម្រោងសំណងណាមួយដែលមានការធានាមូលនិធិត្រឹមតែមួយផ្នែកនោះទេ និងថា គម្រោងសំណងដែលមិនមានលក្ខណៈច្បាស់លាស់គ្រប់គ្រាន់ អាចនឹងពុំត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះទេ ។ ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱកាស និងពេលវេលាបន្ថែមជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបំពេញលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុងចំពោះគម្រោងសំណង ដែលអង្គជំនុំជម្រះសាលាដំបូងយល់ថានៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់ក្នុងការយកទៅអនុវត្ត រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ។ ព័ត៌មានណាមួយដែលផ្តល់ជូននៅក្រោយកាលបរិច្ឆេទនេះ អង្គជំនុំជម្រះបញ្ជាក់ថានឹងមិនយកមកពិចារណានោះទេ ។

ដើម្បីធានាថាគម្រោងសំណងទាំងអស់ដែលស្នើសុំ នឹងត្រូវទទួលយកដោយអង្គជំនុំជម្រះ ទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ ចាំបាច់ត្រូវខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាពក្នុងការស្វែងរកកិច្ចសហប្រតិបត្តិការទាំងផ្នែកបច្ចេកទេស និងថវិកាបន្ថែមទៀត ពីភាគីទីបីណាមួយ ។

## សន្និដ្ឋាន

ជាការពិត គម្រោងសំណងមួយចំនួននៅពុំទាន់មានមូលនិធិគ្រប់គ្រាន់ដើម្បីយកទៅអនុវត្តនៅឡើយ ប៉ុន្តែអង្គជំនុំជម្រះពុំគួរបដិសេធគម្រោងសំណងណាមួយដែលស្នើសុំដោយដើមបណ្តឹងរដ្ឋប្បវេណី នៅមុនពេលមានសេចក្តីសម្រេចអំពីពិរុទ្ធភាពរបស់ជនជាប់ចោទទេ ។ អង្គជំនុំជម្រះអាចបង្គាប់ឲ្យពិរុទ្ធជន ចេញថ្លៃសោហ៊ុយក្នុងការអនុវត្តគម្រោងសំណងដែលនៅពុំទាន់មានថវិកាគ្រប់គ្រាន់ ក្នុងករណីដែលអង្គជំនុំជម្រះរកឃើញថាជនជាប់ចោទពិតជាមានពិរុទ្ធភាព ដូចមានចែងក្នុងវិធាន២៣ស្ទួនបួន(៣) នៃវិធានផ្ទៃក្នុង ។

ប្រសិនបើ អង្គជំនុំជម្រះរកឃើញថា ពិរុទ្ធជនជាជនក្រីក្រគ្មានលទ្ធភាពក្នុងការចេញសោហ៊ុយ អនុវត្តគម្រោងសំណងដែលស្នើសុំ អង្គជំនុំជម្រះអាចសម្រេចប្រគល់ភារកិច្ចអនុវត្តគម្រោងសំណងទាំងនោះ ទៅឲ្យតតិយជនដែលមានថវិកាគ្រប់គ្រប់ និងស្ម័គ្រចិត្តទទួលយកទៅអនុវត្ត ។ ចំណែកឯ គម្រោងសំណងដែលពុំទាន់មានថវិកាគ្រប់គ្រាន់ អង្គជំនុំជម្រះអាចទុកលទ្ធភាពឲ្យអង្គភាពគាំពារជនរងគ្រោះស្វែងរកថវិកាបន្ថែមពីដើម្បីយកទៅអនុវត្ត ។

ដូច្នេះ អង្គជំនុំជម្រះគួរតែសម្រេចទទួលស្គាល់គម្រោងសំណងទាំងអស់ដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ថាជាសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០១ ។

# ពន្យល់ពាក្យសំខាន់ៗ

*ជនរងគ្រោះ* : *សំដៅទៅលើរូបបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងព្យសនកម្មដោយសារអំពើឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ ។*

*ដើមបណ្តឹងរដ្ឋប្បវេណី* : *សំដៅទៅលើជនរងគ្រោះដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ត្រូវបានប្រកាសទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។*

*ជនជាប់ចោទ* : *សំដៅទៅលើបុគ្គល ដែលត្រូវចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ ។*

*ភាគី* : *សំដៅទៅលើសហព្រះរាជអាជ្ញា ជនត្រូវចោទជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។*


មជ្ឈមណ្ឌលឯកសារកម្ពុជា

*ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា*

*ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥*

*ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨*

*អ៊ីម៉ែល : dccam@online.com.kh*

*គេហទំព័រ : www.dccam.org ឬ www.cambodiatribunal.org*

*គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ*

*Bereau of Democracy, Human Rights, and Labor,*

*U.S. Department of State*


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | ឡុង រិទ្ធ | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



***លឹម ជ័យច័ត្ត***

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ចពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិ ទទួលបានពានរង្វាន់មេដាយមាសក្នុងការប្រកួតសវនាការប្រឌិត ឆ្នាំ២០១០ ។



***ខួន ឡៃហុល***

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***ឌី សុជាតា***

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



***ចាន ប្រាថ្នា***

បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



និស្សិតតម្រង់ជួរដើម្បីចូលមើលដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសាលាក្តីខ្មែរក្រហម
(បណ្ណសារ  :  មជ្ឈមណ្ឌលឯកសារកម្ពុជា)